ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៩

ខែ្ស ១, ២, ៣, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្តេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៩

គ. ស. ១៩៣៧

ក្រុមជំនុំទំនៀមទំលាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


ទំព័រ

១ ខេមាខេមសរណកថា លទ្ធិជេនសាសនា ព្រះមហាពិទូរក្រសេម រៀបរៀង (ត) ១១

២ វិធីបង្ការរោគ ប្រែចេញពីភាសាបារាំងសែសរបស់ដុកទ័រ ឡូរង្ស . . . . . . . . . ១៨

៣ វិធីបង្កក់ឆ្អប ក្នុងកិច្ចសម្រាលកូន ព្រះមហាពិទូរក្រសេម រៀបរៀង . . . . . . . ៣៥

៤ ធនញ្ជយបណ្ឌិត រឿងខ្មែរ . . . . . . . . . . . . . . . . . . . . . . ៤១

៥ រឿងពស់កេងកង រឿងព្រេងខ្មែរ . . . . . . . . . . . . . . . . . . . ៥៣


# រូបក្រៅរឿង


១ ចេតិយទឹបមាស នៅវត្តសូលេ កណ្ដាលក្រុងរ៉ាំងគូន ប្រទេសភូមា . . . . . . . ៧

២ ពួកឧបាសកឧបាសិកា ជើងវត្តស្វេតគ្គុំ (ភូមា) ទៅបូជាព្រះពុទ្ធរូប . . . . . . ១៧

# TABLE DES MATIÈRES

I. Khemā-Khema Saranakathā ou Religion, refuge des hommes par Préas Maha Pitou Krasem à la Bibliothèque Royale........................................ 11

II. Hygiène........................................ 19

III. Cérémonie de purification par la sage-femme............ 35

IV. Histoire de Thananh-Chaya............................ 41

V. Conte cambodgien inédit:

Le serpent Keng-Kâng.............................. 53

## HORS TEXTE:

I. L'Édicule doré — Pagode de Sulé-Rangoon — Birmanie... 7

II. Pagode de Shwedagon — Jour de pleine lune........... 17



ចេតិយទីបមាស នៅវត្តស្វូលេ នៅកណ្ដាលក្រុងរាំងគូន ស្រុកភូមា
វេលាយប់អុចភ្លើងអគ្គិស្សនី ។

ខេមាខេមសរណគាថា

ព្រះមហាពិទូរ ក្រសេម គន្ធៈបទបណ្ឌិត្យ

រៀបរៀង (ត)

## លទ្ធិជេនសាសនា

ក្នុងសម័យមុនពុទ្ធកាល ៣ ឆ្នាំ មានសាស្ដា ១ នាក់ ឈ្មោះ ជិន ឬ ជិនវឌ្ឍមាន ហៅមួយយ៉ាងទៀតថា មហាវីរ ជាឱរសក្សត្រិយ៍សិទ្ធត្ថ មាតាឈ្មោះត្រិសលា កើតនៅស្រុកកុណ្ឌលគ្រាម ក្នុងដែនគរវេសាលី កាលមហាវីរអាយុ ៣៥ ឆ្នាំ មាតាបិតាអនិច្ចកម្មអស់ហើយ ក៏ចេញបួសជាជីព្រៃពនេចរ បំពេញវត្តនៅក្នុងព្រៃបាន ១២ ឆ្នាំសំគាល់ខ្លួនថាជាព្រះអរហន្ត លំដាប់នោះព្រះមហាវីរក៏ចេញមកតាំងខ្លួនជាសាស្ដាប្រដៅលទ្ធិធម៌របស់ខ្លួនដល់ប្រជាជនទាំងឡាយតាំងអំពីនោះមកបានជាង ៣០ ឆ្នាំ, ប្រទេសដែលមហាវីរបានទៅប្រកាសសាសនា គឺប្រទេសកោសល វិទេហ មគធៈអង្គៈ(ឱធ) នឹងមណ្ឌលបេតិរហុតវិហារ, អស់សង្ខារអនិច្ចកម្មនៅនគរបាវា លទ្ធិនេះមានពួកនិគ្រន្ថតិរ្ថិយរាប់អានច្រើន បានជាសរណៈរបស់មហាជនជាច្រើននគរ ។

ពាក្យប្រដៅរបស់លោកនេះហៅថា ជេនសាសនា ប្រែថាសាសនារបស់ព្រះជិន មានគោលសំខាន់គឺប្រដៅឲ្យចៀសចេញចាកសំសារទុក្ខ ទីដែលនឹងរួចចាកទុក្ខបានហៅថា មោក្ខ

ផ្លូវដែលនឹងទៅដល់មោក្ខ ក៏គឺអាស្រ័យកែវ ៣ ប្រការ ១- សម្មាទស្សនៈ សេចក្ដីឃើញប្រពៃ គឺ ឃើញគុណសម្បត្តិរបស់ព្រះជិនដោយច្បាស់លាស់ហើយជឿយ៉ាងស្និទ្ធមិនមានប្រែប្រួល (ធៀបយ៉ាងតថាគតពោធិសត្វ) ២- សម្មាញាណ សេចក្ដីដឹងប្រពៃ គឺដឹងគោលនៃពាក្យប្រដៅដែលព្រះជិនសំដែងទុក, ៣- សម្មាចរិត សេចក្ដីប្រព្រឹត្តប្រពៃ ក្នុងខនេះសំដៅយកធម៌ ២ ប្រការ គឺអនាគារធម៌ ធម៌សម្រាប់បព្វជិត (ធៀបយ៉ាងអនាគារវិន័យ) និងអគារធម៌ ធម៌សម្រាប់គ្រហស្ថ (ធៀបយ៉ាងអគារវិន័យ) បើចង់ជ្រាបសេចក្ដីពិស្ដារក៏ចូរមើលសៀវភៅរបស់លទ្ធិនេះ ពាក្យប្រដៅក្នុងសាសនានេះ សំដែងភូមិធម៌ទាំងជាន់ទាប ជាន់កណ្ដាល ជាន់ខ្ពស់ ប្រហែលគ្នានឹងពុទ្ធសាសនា តែគ្មានធម៌សំខាន់គឺអរិយសច្ច ៤ និងអនត្តានុបស្សនា ហើយរៀងលំដាប់ធម៌ក៏នៅមិនទាន់រៀបរយរហូត ថែមទាំងមានអត្តកិលមថានុយោគ (ការទ្រមានរាងកាយឲ្យបានសេចក្ដីលំបាកទទេ) លាយលំផងជាច្រើនខ ឃើញថាជារងព្រះពុទ្ធសាសនា តែខ្ពស់ជាងលទ្ធិដទៃៗ ។ បំណែកឯព្រះជិន

នោះក៏មិនមែនជាព្រះអរហន្តដូចដែលខ្លួនសំគាល់ តែដោយហេតុបញ្ញត្តិសាសនាបានល្អប៉ុណ្ណោះ ទើបធ្វើឲមនុស្សនឹករាប់អានយកជាសរណៈច្រើន តែវេលានេះរៀវរោយជិតសាបសូន្យ ហើយព្រោះមកដល់សម័យកណ្ដាល មនុស្សទាំងឡាយបែរទៅរាប់អានលទ្ធិសាសនាព្រាហ្មណ៍វិញជាច្រើន ។

## លទ្ធិគ្រិស្តសាសនា

លទ្ធិនេះឧបត្តិឡើងក្នុងប្រទេសប៉ាលេសទៃន៍ ក្នុងកាលក្រោយពុទ្ធសករាជ ៥៤៣ សាស្ដាចារ្យអ្នកប្រកាសលទ្ធិនេះមាននាមថា "យេស៊ូ" (ជារូបសរណៈ) ជាតិជាហេបរូ ឬយីវ សម្ភពក្នុងស្រុកបេថលេហេម ក្រុងយេរូស ប្រទេសប៉ាលេសទៃន៍ កាន់តាមលទ្ធិនៃព្រះជាម្ចាស់ដ៏មាននាមថា "ព្រះយេហូវ៉ា" (ជាអរូបសរណៈ) ព្រះអង្គជាអ្នកសាងនឹងជាអ្នកគ្រប់គ្រងសកលលោក ទ្រង់ប្រទានព្រះបុត្ររបស់ព្រះអង្គ គឺយេស៊ូ ឲ្យអន្ទោលមកយោនយកកំណើតជាមនុស្សក្នុងមនុស្សលោក ឲ្យសមតាមពាក្យទំនាយរបស់ព្រះពុទ្ធសាស្ដាចារ្យសឹង

ព្យាករទុកអំពីព្រេងនាយ ដ៏មានប្រាកដនៅក្នុងគម្ពីរចាស់ដ៏ជាដើមគម្ពីរប៊ីព្លើស ដើម្បីនឹងលោះលាបាបរបស់មនុស្សជាតិដែលជាទាយាទមានបាបជាប់តមកអំពី អាដាំ និងនាង អេវ គឺប្រុសស្រីមួយគូដំបូង ដែលព្រះជាម្ចាស់ទ្រង់សាងឡើង តែល្មើសព្រះបញ្ញត្តិរបស់ព្រះអង្គ ក៏តោងត្រូវបណ្ដាសាជាំទីងមកកើតជាមនុស្ស, ព្រះអង្គជាមហាទេព ប្រកបដោយមហាករុណាប៉ីដូចជាបិតា ហើយនឹងគ្រប់គ្រងសកលចក្រវាឡ ជាធម្មទេពតែមួយព្រះអង្គ គ្មានទេពដទៃធំជាង ។ អ្នកប្រាថ្នាយកព្រះអង្គជាសរណៈ គាប្បីបង្អោនចិត្តជ្រះថ្លាបូជាព្រះអង្គ និងប្រព្រឹត្តតាមបញ្ញត្តិដែលបានប្រទានដល់ " ព្រោហ្វេត " គឺសាស្ដាព្យាករ ។

លុះព្រះយេស៊ូឧបត្តិមកក្នុងលោក បំរើនរីយេឡើងល្បីកិត្តិ-គុណថាជាអ្នកឆ្លាសយ៉ាងមហាអស្ចារ្យ បន្ទះភូមិជាព្រះគ្រិស្ទប្រ-ដៅឱ្យនិករជនប្រព្រឹត្តសេចក្ដីល្អ មានមេត្តាករុណាដល់អ្នកដ-ទៃនឹងប្រដៅឱ្យមានសេចក្ដីភក្ដីគោរពដល់ព្រះយៈហោវ៉ាជាម្ចាស់ប្រកាសលទ្ធិថ្មីមួយយ៉ាងទៀតក្នុងលោក អាងថាខ្លួនជាបុត្រនៃ

ព្រះជាម្ចាស់សួគ៌ តែជនជាតិយូរមិនជឿ មិនជ្រះថ្លានឹងព្រះយេស៊ូ ព្រោះប្រកាន់តាមសំដីដើមថា មេស្ស៊ីអះ ដែលព្រះយ៉ៈហោវ៉ា ទ្រង់ទទួលប្ដេជ្ញាថានឹងប្រទានព្រះបុត្រឲ្យចុះមកកើតជួយជាតិខ្លួនឲ្យរួចអំពីទុក្ខភ័យ ដោយមកកម្រាបសត្រូវឲ្យបាក់បបខ្លបខ្លាបរាបទាំងលោក ឲ្យជាតិយូរបានជាម្ចាស់លោកនោះ តោងជាមហាបុរសដ៏ក្លាហាន មានឫទ្ធិតេជះដ៏មហិមា ក៏ឯព្រះយេស៊ូគ្រាន់តែជាកូនអ្នកជនបទមួយនាក់ គ្មានឫទ្ធិតេជះដែលមុខគួរសំបើមត្រង់ណាសោះ ថែមទាំងប្រដៅមនុស្សទាំងពួងឲ្យលើកទោសសត្រូវរបស់ខ្លួន នឹងប្រដៅឲ្យមានសេចក្ដីមេត្តាករុណាដ៏ទទឹងទាស់នឹងសេចក្ដីប្រព្រឹត្តរបស់លោក នេះឯងជាហេតុឲ្យព្រះយេស៊ូត្រូវឆ្កាងជាប់នឹងឈើឆ្កាង (រូបឆ្កាងនេះគេធ្វើទុកជាអនុសាវរីយ៍នៅទីវត្តក្នុងលទ្ធិនេះ អ្នកត្រូវការចង់ឃើញក៏ចូលទៅមើលចុះ) ការដែលត្រូវឆ្កាងដូច្នេះ តាមលទ្ធិគ្រិស្តត្រឡប់ទៅជាគាន់ថា ព្រះជាម្ចាស់សួគ៌ទ្រង់ព្រះមហាករុណាដល់មនុស្សលោក ប្រទានព្រះបុត្ររបស់ព្រះអង្គឲ្យមកទទួលបាបរបស់មនុស្សលោក ដោយពលីជីវិតបុត្ររបស់ព្រះអង្គជំនួសឲ្យ ១ នេះជាសេចក្ដីកែមុខគួរស្ដាប់ដែរ ។

វេលាក្រោយមក លទ្ធិគ្រិស្តបានផ្សាយទៅប្រទេសយូរុពបានញែកជានិកាយធំ ៗ បីនិកាយ គឺ រោម៉ាំងកាតូលិក គ្រិកនិកាយ និងប្រោតេស្តង់ តែក្នុងទីនេះនឹងនិយាយតែក្នុងរោម៉ាំងកាតូលិកនិកាយ ព្រោះជានិកាយដែលមានមនុស្សរាប់អានច្រើនក្នុងប្រទេសបារាំងសែស ឥតាលី អាល្លឺម៉ង់ខាងក្រោម អេស្ប៉ាញ ពរទុយគេស អង់គ្លេស ។ មានសេចក្ដីតាមលទ្ធិនេះថាបាបគឺសង្ឃនាយកក្នុងក្រុងរោម ប្រទេសឥតាលីជាអ្នកទទួលកាន់កាប់លទ្ធិនេះ អំពីពីតើរអគ្គសាវករបស់ព្រះយេស៊ូ មានអំណាចនឹងបែមបញ្ញត្តិផ្សេង ៗ ឡើងទៀតបន្ថែមក៏បាន ដើម្បីនឹងដាក់ឲ្យនិករជនទទួលរាប់អានបដិបត្តិតាម សេចក្ដីអត្ថាធិប្បាយនឹងច្បាប់បញ្ញត្តិនេះហៅថា "ព្រះសម័យ" ព្រះសម័យនេះសំដែងរួមទាំងខ្លួននៃសាធុជន អ្នកបដិបត្តិក្នុងលទ្ធិនេះផងមានពិធីដែលត្រូវធ្វើក្នុងលទ្ធិនេះ ៧ ប្រការ លទ្ធិកម្ម ៧ ប្រការជាពិធីដែលគេធ្វើដោយច្រើន តែម្ដងប៉ុណ្ណោះគឺ

(នៅតទៅទៀត)



នៅថ្ងៃពេញបូណ៌មី ពួកឧបាសកឧបាសិកាជើងវត្តស្វេតគួន នៅរ៉ាំងគូន (ភូមា) នាំគ្នាយកផ្កាទៅបូជា ព្រះពុទ្ធរូប ។

# វិធីបញ្ឈរភេត

## ព័ណ៌ន៏មាន

វិធីបង្ការរោគនេះ ជាសេចក្តីពន្យល់យ៉ាងប្រសើរមួយផ្នែក ដែលលោកឡឺដុកទ័រ ឡូរ៉ង្ស ចាងហ្វាងចាស់ ក្រសួងពេទ្យប្រទេសលាវ បានរៀបរៀងទុកមក ។

យើងមានអំណរគុណលោកឡឺរេស៊ីដង់ម៉ែរ នៅវៀងចន្ទន៍ ប្រទេសលាវ ដែលបានអនុញ្ញាតឲ្យយើងប្រែរឿងនេះចេញជាភាសាខ្មែរ បោះពុម្ពផ្សាយ ដើម្បីឲ្យជនជាតិខ្មែរយល់នូវវិធីនេះ ហើយប្រតិបត្តិតាម នឹងបានទទួលនូវផលប្រយោជន៍ដ៏ប្រសើរនេះផង ។

## វិធីបង្ការរោគ

( នៅទីភូមិលំនៅ )

ភាពផ្ទះខ្មែរ ដែលខ្មែរយើងសង់នៅសព្វថ្ងៃនេះ មានជើងសសរខ្ពស់ស្រោងស្រឡះ ត្រូវតាមលក្ខណវិធីបង្ការរោគជាស្ថានដែលស្រួលនឹងថែទាំសំអាត បើជាបេះថែរក្សាឲ្យស្អាតហ្មត់ហ្មងហើយ ឃើញថានឹងបាននូវសេចក្ដីសុខសម្រានប្រាសចាកជម្ងឺរោគាពាធដោយពិត ។

លក្ខណផ្ទះដែលដូនតាយើងធ្វើទុកជាប់ជាទំនៀមមកដល់សម័យនេះមានរូបរាងខ្ពស់ស្រឡះក្រោម ងាយស្រួលនឹងបង្ការរោគប្រការខ្លះ កុំឲ្យកកើតឡើងបាន តែពួកយើងក្នុងជាន់នេះឃើញហាក់ដូចជាមិនសូវដឹងមិនសូវយល់ប្រយោជន៍នេះឃើញធ្វេសប្រហែសក្នុងការថែសំអាតផ្ទះសំបែងភូមិលំនៅ ធ្វើឲ្យខូចខាតប្រយោជន៍ដែលត្រូវបានអំពីទីលំនៅស៊ុនពេកណាស់ ។

## សមុដ្ឋាននៃរោគ

ហេតុដែលបណ្ដាលឲ្យកើតរោគ មកពីមានបសុសត្វ គឺ សត្វដែលគេចិញ្ចឹមច្រើន ដូចយ៉ាង មាន់ ទា ជ្រូក គោ ក្របី សេះ ជាដើម ដែលជាសត្វគេដាក់ទ្រុង ដាក់ក្រោល- ឃ្នង បង្ខាំងនៅក្រោមផ្ទះ ឬនៅខាងផ្ទះ សត្វអំបាលនោះក៏ជុះនោម លាយគ្នាច្របល់ខ្វល់ខ្វក់ កើតជាទីជំរំ-សំអុយ ដែលជាចំណី អាហារយ៉ាងគាប់ចិត្តរបស់សត្វរុយ ។ សត្វរុយក៏មករោម ហើយពងដាក់នៅរបស់សំអុយអំបាលនោះ ហើយក៏ហើរមកទំ នៅអាហារផ្សេងៗ ដែលមនុស្សបរិភោគ ក៏បណ្ដាលកកើត ទៅជារោគឆ្លងដល់ពួកមនុស្ស ធ្វើឲ្យមនុស្សវិនាសទៅមុខគួរ ស្ញែង សត្វរុយនេះហើយដែលជាមេព្រាយធំ ធ្វើឲ្យកូនចៅ អ្នកស្រុកស្លាប់រង្គាលតែរាល់ឆ្នាំ ។

ជាមួយនឹងសត្វរុយ នៅមានសត្វមូសមួយពួកទៀត ជាសត្វឧត្បាទចង្រៃបែបដូចគ្នានោះ ។ មូសនេះជាមេចំឡង រោគគ្រុនលោះដល់មនុស្សយើង ធ្វើឲ្យយើងសម្រាកសម្រាន

យប់ពុំបាន ដោយវាមកយាយីដល់រូបកាយយើង យើងត្រូវដឹងថាវាទាំងពីរ គឺរុយនេះ១ មូសនេះ១ ជាសត្រូវដល់សេចក្ដីសុខសម្រានរបស់យើង ។ មូសនេះវាតែងកើតនៅទីជុំវិញផ្ទះយើង គឺវាតែងពងដាក់ទៅទីដែលដក់ទឹកជ្រាំ ទឹកសំអុយ ទឹកភ្លៀង ដូចយ៉ាងប្ដឹក អណ្ដូង ត្រពាំង និងជ្រលងជានជើង គោក្របីជាដើម ដែលមាននៅជិតខាងផ្ទះយើង កាលវាធំឡើងហើយក៏វាហើរទៅរកទីកៀនកោះដែលងងឹតៗក្នុងផ្ទះរបស់យើងខ្លះ នៅទីម្លប់ស្មៅម្លប់ឈើ ស៊ុបទ្រុបសុំទ្រុម ដែលមាននៅជុំវិញផ្ទះយើងខ្លះ ជាទីជ្រកខ្យល់ ជ្រកពន្លឺកំដៅថ្ងៃ សត្រូវធំរបស់វា ក៏គឺពេលថ្ងៃ វាខ្លាចរស្មីថ្ងៃណាស់ មិនហ៊ានចេញវាលទេ លុះដល់យប់វាទើបចេញពីទីលំនៅរបស់វា ហើរឆ្លៀតឆ្នាត់មកទំបុបជញ្ជក់យកឈាមរបស់យើងជាអាហារ ធ្វើឲ្យយើងព្រួយអំពល់កង្វល់នឹងវាពុំមានស្រាកស្រាន ក្នុងខណៈដែលវាមកជញ្ជក់យកឈាមយើងនេះហើយ ដែលវាជំរុះចំឡងមេក្រូពិសគ្រុនទុកឲ្យយើង ដូច្នេះត្រូវយើងប្រុងប្រៀបធ្វើសឹកកម្ចាត់បរុយនឹងមូសដែលជាសត្វសត្រូវនឹងសេចក្ដីសុខសម្រានរបស់យើងឲ្យមែនទែន ។

វិធីកំចាត់វាទាំងពីរដូច្នេះ គោ ក្របី សេះ ។ ល ។ ត្រូវបញ្ចូលក្រោលប្នេងនៅទីវាលក្រោមភូមិ បើមិនមានទីដូច្នោះទេនឹងបងនៅក្នុងភូមិក៏បានដែរ តែត្រូវថែសំអាតបោសប្រាស កើបអាចម៍វា នឹងអាចម៍ មាន់ ទា ជ្រូក នឹងរបស់ស្មោកគ្រោកទាំងពួងទៅចាក់ចោលនៅទីវាលស្រែក្រៅ ឬនៅទីដែលផុតឆ្ងាយអំពីភូមិលំនៅ ក្រោមផ្ទះត្រូវសំអាតឲ្យស្ងួតជានិច្ច កុំឲ្យមានភក់ជ្រាំដក់នៅក្រោមផ្ទះឬនៅខាងផ្ទះរបស់យើង វិធីនេះហើយដែលធ្វើឲ្យរុយនឹងមូសវិនាសខ្ចាត់ខ្ចាយទៅ ១ យ៉ាង ទាំងជាឧបការៈធ្វើឲ្យស្រែស្រូវរបស់យើងចំរើនផលបរិបូណ៌ផង ។

១ យ៉ាងទៀត បសុសត្វធំៗដូចយ៉ាង ជ្រូក-គោ ក្របី-សេះ កុំលែងបណ្តោយឲ្យវាដើររុករានក្នុងភូមិ វានឹងឈ្លីសដីឬដើរជាន់ឲ្យកើតជាថ្លុក ក្រហេងក្រហូងដក់ទឹកសំអុយ សឹងជាហេតុឲ្យមូសមកអាស្រ័យកើតដូចពោលហើយ ។ ទីដីក្នុងភូមិបើមានជាថ្លុកជង្ហុកក្រហេងក្រហូងត្រូវប្រាបបង្រាបឲ្យរាប ត្រូវធ្វើឲ្យមានប្រឡាយគន្លងសម្រាប់ទឹកហូរចេញទៅក្រៅភូមិ ឈើព្រៃដែលដុះស៊ុបទ្រុបនៅជិតខាងផ្ទះ ត្រូវជំរះកាប់ឆ្ការឲ្យវាលរលីង

ស្រឡះ ។ យើងត្រូវចាំទុកថា ខ្យល់និងពន្លឺព្រះអាទិត្យជាជំនួយ សេចក្ដីសុខសម្រាប់ឲ្យដល់មនុស្សទាំងពួង ហើយជាសត្រូវនឹងសត្វមូស ហេតុនោះមនុស្សយើងអ្នកត្រូវការសេចក្ដីសុខ ទើបត្រូវបើកបំហាវឲ្យខ្យល់ដើរ និងឲ្យពន្លឺព្រះអាទិត្យចូលចាំងសព្វសាយក្នុងភូមិក្នុងទីកន្លែងគ្រប់អន្លើ ។

ក្នុងភូមិលំនៅរបស់យើង ត្រូវទុកតែឈើណាដែលមានស្លឹកមិនស្កូវក្រាស់ ដូចយ៉ាង ដើមក្របធ្នារ ក្របសើប ក្របថ្លុង គូលែន ដូង ស្លា ជាដើម ។ ដើម្បីបេកនេះ១ ជាទីពំនាក់នៅរបស់មូស មិនត្រូវដាំជិតផ្ទះ នៅទីជុំវិញផ្ទះបើត្រូវការដាំ គប្បីដាំដើមបន្លែនឹងគ្រឿងសម្លដូចយ៉ាងជីរ-ខ្ទឹមជាដើមទុកសម្រាប់ស្លបានឥតមានទាស់ ។

ក្នុងផ្ទះក៏ត្រូវថែសំអាតដែរ និយាយតាមទំនៀមជាភារៈលើកូនស្រីជាអ្នកថែសំអាត គឺបោសច្រាសកុំឲ្យរាយ កុំឲ្យមានផង់ធូលី ហើយបេះផ្កាស្រស់ផ្សេងៗមកដោតដាក់នៅជើងផ្កាឬជើងពាន ហើយដាក់ដិកល់លើតុ ឬលើអាសនៈព្រះ បូជាថ្វាយព្រះ ។ ផ្កាទាំងអំបាលនេះហើយជាគ្រឿងសំអាងផ្ទះឲ្យល្អ

មើល ហើយជាគុណគ្រឿងអំណោយសេចក្ដីសប្បាយរីករាយ ដល់ភ្នែកនឹងដួងចិត្តនៃអ្នកដែលបានឃើញ ផ្កាភ្ញីនេះហើយ ដែលពួកអ្នកកាន់ព្រះពុទ្ធសាសនាគេនិយមថា ជាគ្រឿងបូជាយ៉ាងប្រសើរ គេតែងបូជាដល់ព្រះពុទ្ធ ។ ស្រុកអូរុពគេច្រើនរៀបទទួលភ្ញៀវនឹងជូនភ្ញៀវដែលមកលេងផ្ទះ ។

ទឹកផឹកនឹងអាហារដែលបរិភោគត្រូវសំអាតនឹងប្រយ័ត្នជាបំផុត ។ អ្នកណាៗក៏ដឹងបានហើយថា រុយជាសត្វចូលចិត្តផ្ដេកផ្ដិតស្និទ្ធស្នាលនឹងសំរុយ របស់ស្មោកគ្រោកទាំងពួងដែលនៅខាងផ្ទះ កាលវាទៅទំទៅពាមហើយៗក៏ហើរមកទំលើបំណាំអាហារដែលយើងបរិភោគ វានឹងជំរុះមេក្រមុំមេរោគដែលជាប់នៅជំពុសមាត់វានឹងនៅជើងវា ទុកនៅបំណាំអាហារនោះ កាលយើងយកបំណាំអាហារនោះមកបរិភោគ នឹងបង្កើតទៅជារោគដង្កាពោះ ដូចរោគបុះវាក-បុះក្អួត-មួល គ្រុនក្ដៅ ។ ល ។ ដូច្នេះ បំណាំអាហារទាំងប៉ុន្មានដែលយើងត្រូវបរិភោគ គប្បីសំ-អាតឲ្យស្អាត កុំឲ្យប្រឡាក់ក្អែលល្អងធូលីរបស់មិនស្អាតទាំងពួង វេលាបំអិនរួចហើយគប្បីប្រញាប់គ្របដោយគម្របមាន

សាជី ឬកញ្ច្រែងឬស្សីដែលគេសម្រាប់គ្របជាដើម កុំឲ្យរុយ
វាមកទំបាន ។

ទឹកដែលផឹក ត្រូវសំអាតនឹងប្រយ័ត្នបោះជាប ។

ក្នុងរដូវដើមឆ្នាំ ដែលមានភ្លៀងធ្លាក់ ៣-៤ ដងហើយ
នោះអ្នកស្រុកខ្មែរយើងនេះ បំណាំតែមានរោគជម្ងឺឈឺពោះ ដូច
យ៉ាងរោគមួល រោគបុះរាក រោគគ្រុនក្ដៅក្នុង, ក្នុងមួយឆ្នាំៗ
មានមនុស្សស្លាប់រាប់រយ ដោយហេតុក្នុងរដូវប្រាំងជាច្រើនខែ
នោះ ទឹករីងស្ងួតអស់ទៅហើយ រមែងមានលាមកមនុស្សនឹង
សត្វ នឹងគម្រង់សត្វ របស់ស្មោកគ្រោកទាំងពួង នៅរាត់រាយ
ពាសលើផែនដី កាលដល់រដូវភ្លៀងធ្លាក់មក ទឹកភ្លៀងក៏ហូរ
បន្សាត់យករបស់មិនស្អាតអំបាលនោះ នឹងកំទេចធូលីទម្លាក់ទៅ
ក្នុងទំនាប មានថ្លុក-ត្រពាំងជាដើម មេក្រុមដែលកើតអំពីសំ-
អុយ ក៏នៅបាចសាចពាសពេញក្នុងទីនោះ កាលយើងទៅ
ដងទឹកនោះមកផឹក ផឹកដោយជាតិរបស់មិនស្អាត ដោយមេ
ក្រុមចូលទៅ ក៏កើតជារោគដូចពោលហើយ គប្បីចាំទុកបុះ
រោគប្រភេទនេះច្រើនកើតក្នុងរដូវដើមឆ្នាំជាងរដូវដទៃ ។

ក្រោយអំពីនោះទៅ គឺកាលភ្លៀងធ្លាក់ច្រើនពេញទីកន្លែងដែលទឹកត្រូវដក់នៅបាន គប់អន្លើហើយ រហូតវេលាទៅដល់ខែប្រាំងវិញ ទឹកលែងហូរចុះឡើងហើយ ទឹកក៏នឹងដោយទីកន្លែងហើយ កករធូលីនឹងរបស់ស្មោកគ្រោកទាំងពួង ក៏ធ្លាក់ចុះទៅបាតត្រពាំង បាតព្រែក ។ ល ។ អស់ហើយ ទឹកក៏រងថ្លា ពេលនោះយើងនឹងផឹកឬងូតបាន មិនមានទោសអ្វីទេ តែត្រូវប្រយ័ត្នកុំចុះទៅងូត ឬកញ្ជ្រោកបោកបាចឲ្យកករទឹកនោះអណ្តែតឡើងមកលើវិញ ។

កិច្ចរក្សាសេចក្តីស្អាតក្នុងប្រការនេះ ជាភារៈលើមេឃុំ មេភូមិ ឬរាស្ត្រអ្នកស្រុក ក្នុងស្រុកក្នុងភូមិនីមួយ ៗ ជួយគ្នារក្សាទឹកផឹកឲ្យស្អាត ដោយរក្សាទីទឹកដែលមានស្រាប់ហើយ ឬ ដោយជីកជាអណ្តូងជាស្រះ ហើយរក្សាការពារមិនឲ្យមានអាចម៍មនុស្សអាចម៍សត្វរបស់ស្មោកគ្រោក ឬធូលីសម្រាមហូរចូលទៅបាន ។ បើនឹងបង្កើតឲ្យមានទីដាក់ទឹកថ្មីឡើង ត្រូវរើសយកទីខាងលើភូមិ ដែលមានដីខ្ពស់ជាងភូមិ ឬទីដែលទឹកមិនអាចនឹងហូរចូលទៅបាន កាលរកទីដូច្នោះបានហើយ នឹង

ដីកជាអណ្ដូងក្ដី ជាស្រះក្ដី ត្រូវធ្វើភ្លឺ ធ្វើទំនប់កុំឲ្យរបស់ស្មោកគ្រោកហូរចូលទៅបាន ។

ប្រការមួយទៀតដែលយើងនឹងរក្សាសេចក្ដីសុខ ឲ្យផុតអំពីអន្ដរាយអំបាលនេះ យើងត្រូវពន្យល់គ្នាថា ទឹកដែលយើងប្រើផឹកសព្វថ្ងៃ យើងត្រូវដាំឲ្យពុះទុកផឹក ហើយប្រយ័ត្នកុំឲ្យរុយមមុងជាដើម ធ្លាក់ចូលក្នុងទឹកនោះ យើងត្រូវនាំគ្នាប្រតិបត្តិដូច្នោះ ទំរាំតែរាជការ ឬអ្នកស្រុកណាមួយ រិះគិតធ្វើជំរងទឹកដែលស្អាតឲ្យយើងបរិភោគ ដូចយ៉ាងម៉ាស៊ីនទឹកជាដើម ។

យើងត្រូវពន្យល់គ្នាថា មុននឹងចាប់កាន់របស់ដែលត្រូវបរិភោគ យើងត្រូវលាងដៃឲ្យស្អាតជាមុនសិន ដើម្បីការពារកុំឲ្យមេក្រុម មេរោគជាប់ដោយទៅនឹងអាហារ ព្រោះមេក្រុមមេរោគនោះសឹងមានជាសពាស យើងមិនអាចនឹងមើលឃើញថា វានៅត្រង់ណាខ្លះនោះទេ យើងត្រូវតែប្រយ័ត្នជាដរាប ។

ការបង្ការរោគដែលត្រូវធ្វើក្នុងឃុំ ជាដើម ។

ការរក្សាសេចក្ដីស្អាតនេះមិនចំពោះតែក្នុងផ្ទះរបស់យើងទេ ត្រូវចាត់ការរក្សាសំអាតពាសពេញទៅទាំងភូមិទាំងឃុំ រឿង

នេះជាភារៈលើមេឃុំ មេភូមិ គប្បីហាត់ការឲ្យលុបទីទំនាបដែល មានទឹកដក់ ឬនឹងបង្ហូតទឹកឲ្យរីងស្ងួតទៅក៏បាន ត្រូវលុបប្លុក ផង្ហុកទំនាបឬត្រពាំងទឹកដែលមិនត្រូវការប្រើឲ្យរាបស្មើ ដើម្បី កាត់ផ្លូវកុំឲ្យមូសវាមកអាស្រ័យកើតបាន ។ មេឃុំ ឬមេភូមិត្រូវ បង្គាប់ឲ្យរាស្ត្រកាប់ឆ្កាស្មៅព្រៃ ក្នុងភូមិនឹងជុំវិញភូមិនីមួយ ៗ ឲ្យរាលស្រលះ កុំឲ្យមូសវាមកជ្រកកោនបាន ។ ត្រូវហាម កុំឲ្យបាក់អាចម៍មនុស្ស-សត្វ សម្រាម ស្លឹកឈើ ។ ល ។ រាយផ្ដេសផ្ដាស ដើម្បីកុំឲ្យរុយវាមកអាស្រ័យកើត ។

និយាយដោយខ្លី មេឃុំ ឬមេភូមិ ត្រូវថែសំអាតក្នុងឃុំ ក្នុងភូមិឲ្យស្អាតជានិច្ចគ្រប់អន្លើ ដូចយ៉ាងលោកសង្ឃលោកថែ ទាំសំអាតវត្តអារាមរបស់លោកដូច្នោះ ។ អ្នកណាក៏ចូលចិត្ត នឹងមើលនឹងឃើញ ភូមិ ឬវត្តដែលគេបោសច្រាសថែសំអាត នេះតែរាល់រូប សូម្បីតែទេវតាក៏ចូលចិត្ត រុក្ខទេវតាតែងនៅរក្សា តែផ្ទះភូមិដែលស្អាត ៗ ទាំងព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ប្រដៅឲ្យរក្សា សេចក្ដីស្អាត នឹងទ្រង់សរសើរសេចក្ដីស្អាតជាច្រើនអន្លើ ដើម្បី កំចាត់រោគ នឹងដើម្បីជាទីជ្រះថ្លាដល់អ្នកដែលបានមកឃើញ ដូចពោលហើយ ។

ពួកខ្មោចបិសាច អាបព្រាយ រមែងអាស្រ័យនៅក្នុងភូមិ កខ្វក់កខ្វក់ដែលមានសំអុយមានគម្រង់សត្វ ហើយក៏បណ្ដាល ធ្វើឲ្យអ្នកស្រុកមានជម្ងឺឈឺជាច្រើន ។

ដើម្បីនឹងប្រតិបត្តិតាមព្រះពុទ្ធដីការបស់ព្រះពុទ្ធជាម្ចាស់នោះ ត្រូវតែយើងថែសំអាតភូមិលំនៅរបស់យើងឲ្យស្អាត ឲ្យគួរជាទីស្ថិតនៅរបស់រុក្ខទេវតាដែលជាសម្មាទិដ្ឋិ ដើម្បីឲ្យជួយបំរុងបំរើនយើងឲ្យមានសេចក្ដីសុខ ត្រូវកាត់ផ្លូវទៅមករបស់ខ្មោចបិសាចអាបព្រាយកុំឲ្យវាទៅមកបៀតបៀនបាន គប្បីយកដម្រាប់តាមលោកសង្ឃដែលលោកថែសំអាតវត្តអារាមរបស់លោកឲ្យស្អាតជានិច្ចដូច្នោះ ។

## វិធីបង្កាត់ភ្លើង

ប្រពៃណីជនជាតិខ្មែរ អំពីដើមគេធ្វើមង្គលកិច្ចដល់បុត្តធីតាតាំងអំពីសម្រាលហើយ ដរាបដល់អាយុ ៧ ឆ្នាំមាន ៥ ដង គឺក្នុងវេលាសម្រាលហើយនេះម្តង ហៅតាមភាសាមគធៈថា បសូតិមង្គល ប្រែថាមង្គលក្នុងវេលាសម្រាលហើយ ។ វេលាសម្រាលហើយបាន ៧ ថ្ងៃម្តង ហៅថា នាមគ្គហណមង្គល[1] ប្រែថា មង្គលក្នុងវេលាឲ្យឈ្មោះ ។ ក្នុងវេលាបេះដើរម្តង ហៅថា បទសាគមនមង្គល ប្រែថា មង្គលក្នុងវេលាបេះដើរ ។ ក្នុងវេលាបេះស្លៀកសំពត់ម្តង ហៅថា ទុសគ្គហណមង្គល ប្រែថា មង្គលក្នុងវេលាបេះស្លៀកសំពត់ ។ ក្នុងវេលាកាត់សក់ជុកម្តង ហៅថា ចូឡាពោបនមង្គល ប្រែថា មង្គលក្នុងវេលាកាត់ជុក[2] ។

ទំនៀមខ្មែរយើងអំពីដើម ជាដូច្នេះដែរឬទេ មិនអាចដឹងបាន តែសព្វថ្ងៃនេះមានធ្វើតែក្នុងវេលាសំរាលហើយបាន ៣

---

១ កាលព្រះពុទ្ធអង្គប្រសូតបាន ៧ ថ្ងៃព្រះពុទ្ធបិតាក៏បានធ្វើពិធីនាមគ្គហណមង្គលនេះ ។

២ អ្នកខ្លះគេហៅថា សក់កំប៉ោយ ។

ថ្ងៃម្តង ជាការតូចបន្តិចបន្តួច នឹងកោរសក់ព្រៃកាត់ជុក ក្រោយអំពីកាត់ជុកហើយមានដល់ចូលម្លប់ នឹងអាវាហវិវាហមង្គលតែម្តង ។ កិច្ចដែលយើងរៀបបង្កក់ឆ្មបក្នុងវេលាសម្រាលហើយបាន ៣ ថ្ងៃនោះ បើនឹងធៀបដោយមង្គលរបស់គណ្ឋៀ អាចត្រូវនឹងបសូតិមង្គលក៏បាន នាមគ្គហណាមង្គលក៏បាន ។

របៀបដែលគេបង្កក់ឆ្មប សឹងពោលតាមតម្រាចាស់នោះ ដូច្នេះ តាមប្រក្រតីគេអាំងភ្លើងតែត្រឹម ៣ ថ្ងៃប៉ុណ្ណោះហើយលាប់អាំង ហៅថា ទម្លាក់បង្ក្រាន ក្នុងថ្ងៃទី ៣ នោះវេលាព្រឹក ឆ្មបត្រូវទៅឯផ្ទះអ្នកសម្រាលកូន ដើម្បីនឹងធ្វើកិច្ចប្រការខ្លះបង្ហើយ ហើយនឹងទទួលយករបស់កំណាល់ ។ ខណៈឆ្មបមកដល់អ្នកម្ចាស់ការត្រូវយកបាយសំឡ ១ ចាំសលើកមកប្រគល់ឲ្យឆ្មប ហើយនឹងកូនខ្ចីនោះផង ឆ្មបក៏យកទឹកខ្មៅដុស ឬទឹកខ្មៅសរសេរធម្មតានេះ មកគូរជាចិញ្ចើមនឹងជើងសក់ឲ្យកូនខ្ចីនោះ ឲ្យមានទ្រង់ល្អ ហើយរៀបល្អហើយ ៗ ដែលធ្វើដូចនេះជាប្រផ្នូលដើម្បីឲ្យទារកនោះមានចិញ្ចើមនឹងជើងសក់ល្អ លំដាប់នោះឆ្មបយកកន្ត្រៃកាត់សក់ត្រង់បង្ហើយ ១ ដុំបេញ ហើយទំពាពន្លៃ

ប្អូនកាលមានថ្នាំងទៀតលាយផង ឲ្យម៉ដ្ឋហើយយកទៅបិទត្រង់ដែលកោរនោះ ជាថ្នាំរក្សាកុំឲ្យធ្លាក់សំបោរកុំឲ្យផ្កាសាយ និងដើម្បីការពារខ្មោច ១ យ៉ាងដែលគេហៅថា ម្ដាយដើម កុំឲ្យវាមកបៀតបៀន ដោយទម្លាប់គេកាន់មកថា ខ្មោចនោះខ្លាចពន្លៃ ហើយត្រូវបិទបង្ហូតទៅទាល់តែទារកនោះរឹងដៃរឹងជើងទ្រើសបន្តិចឡើង ។ បើជាកូនស្រីគេបោះត្រចៀកក្នុងវេលានេះផងក៏មាន ។ អ្នកខ្លះគេទុកយូរបន្តិចទៅទើបបោះក៏មាន ។ ស្រេចហើយក៏សែនព្រេន ដោយបាយសំឡនោះជាប្រយោជន៍ដល់គ្រូធ្មប់ដើមថា " ឥឡូវនេះគេបានកាត់សក់បង្កក់ធ្មប់ហើយ សូមសែនក្រយានេះដល់គ្រូធ្មប់ សុំឲ្យកូននេះសុខសប្បាយព្រមទាំងម្ដាយក៏ឲ្យធូរដៃធូរជើងស្រួលអំពីថ្ងៃនេះទៅ " ហើយចាប់យកម្ហូបបន្តិច ៗ គ្រប់មុខ នឹងបាយនិងសក់ដែលកាត់នោះដាក់បុះក្នុងកន្ទោង អុបធូប ៣ សរសៃដោតនឹងកន្ទោង ឲ្យមនុស្សម្នាក់នាំយកទៅដាក់នៅជើងរបង ។ ក្នុងវេលានោះប្អូនកាលគេតាំងឈ្មោះឲ្យកូននោះផង អ្នកឲ្យឈ្មោះនោះប្អូនកាលមាតាបិតាឲ្យខ្លួនឯង ជួនកាលគេរើសយកបុគ្គលដែលគួរគោរព ដូច

យ៉ាងជាគ្រូជាអាចារ្យឬអ្នកមានបណ្ដាស័ក្តិណាមួយ សន្មតិឲ្យ ។ ប៉ុណ្ណោះឈ្មោះថា ស្រេចកិច្ចរបស់ធ្មបហើយ ។

លំដាប់នោះ អ្នកម្ចាស់ការត្រូវចាត់រៀបអាហារយកមកលៀងធ្មប កាលធ្មបបរិភោគហើយត្រូវលើកយករបស់កំណាល់ធ្មបដែលរៀបទុកពីថ្ងៃមុន នឹងរបស់ដែលថែមថ្មី ២ មុខទៀត គឺមាន់ស្ងោ ១ ប្រាក់ ១ រៀលមកជូនធ្មប ហើយសាមីខ្លួន គឺអ្នកសម្រាលកូនត្រូវមកសុំស្មាលាទោសនឹងធ្មប ក្នុងការដែលធ្មបជួយដោះទុក្ខធុរៈបានសួរសេចក្ដីឡើយហាត់ កុំឲ្យមានទោសពៀរដល់ខ្លួន ។

ធ្មបនោះវិលទៅផ្ទះវិញ ត្រូវយកដីក្នុងចង្ក្រានដែលអាំងភ្លើង ២-៣ ដុំទៅផង ជាគ្រឿងសំគាល់ថាបានទម្លាក់ចង្ក្រានហើយ ។ អ្នកម្ចាស់ការត្រូវចាត់ឲ្យជួយនាំយករបស់កំណាល់ទៅឲ្យដល់ផ្ទះធ្មប ។

រណ្ដាប់បង្កក់ធ្មបដែលពោលមកនេះ កំណត់តាមប្រក្រតីដែលគេតែងធ្វើជាធម្មតា មិនមែនជាកំណត់ទៀងទាត់ត្រូវតែមានដូច្នេះទេ បើអ្នកសាមីខ្លួនមានសម្បត្តិស្ដុកស្ដម្ភ គេអាចឲ្យ

ច្រើនជាងនេះទៅក៏បាន អ្នកទ័លក្របុះមក គេឲ្យតែបន្តិចបន្តួច ឬឲ្យតែរបស់ខ្លះក៏បាន ប្រសិនជាគ្មានរបស់ទ្រព្យសោះដូចយ៉ាងទៅសម្រាលតាមផ្លូវតាមព្រៃ ធ្នូបក៏ត្រូវតែជួយសង្គ្រោះ ។

របស់នឹងកិរិយាដែលធ្វើក្នុងរឿងបង្កក់ធ្នូបនោះ ដើម្បីប្រយោជន៍អ្វី បានអធិប្បាយមកខ្លះហើយក្នុងផ្ទៃរឿង ក្នុងទីបំផុតនេះនឹងអធិប្បាយអំពីស្រូវនឹងអង្ករ ។ ស្រូវដែលគេដាក់ឲ្យធ្នូបជាគ្រឿងសំគាល់ថា គេបានពូជ ពោលគឺកូនគោះហើយប្រៀបដូចជាបានស្រូវពូជ គង់ជានឹងកើតកាលបំរើនតទៅ ស្រូវនោះត្រូវឲ្យទៅធ្នូប ព្រោះជាអ្នកជួយជ្រោមជ្រែងការកើតរូបកាយ ។ ឯអង្ករ ១ ចាន ប្រាក់ ៤ ប៉ៃ ឬ ៤ សេន ទៀនស្នែងក្របីជម ៤ នោះជារបស់ថ្វាយដល់គ្រូធ្នូបដើម កាលគ្រូធ្នូបមិនយកទៅក៏ត្រូវបានដល់ធ្នូបជាកូនសិស្ស ។ របស់ក្រៅអំពីនេះ គ្មានអាថ៌ប្រស្នាអ្វីទេ គេដាក់ទៅបំពោះដើម្បីឲ្យធ្នូបប៉ុណ្ណោះ ។

# រឿងធនញ្ជ័យបណ្ឌិត

(៣)

លុះឯក្រោយទៀត ស្តេចស្រុកខ្មែរទ្រង់ព្រះចិន្តាគិតដល់សេចក្តីធនញ្ជ័យឆ្លាញ់ប្រាជ្ញជាច្រើន ហើយក្រែងធនញ្ជ័យនៅជិតវាំងដណ្តើមយករាជសម្បត្តិ ដ្បិតធនញ្ជ័យនេះមានប្រាជ្ញាច្រើនណាស់ ស្តេចមានព្រះបន្ទូលត្រាស់ថា អាឯងឯងនៅស្រុកនេះមិនបានទេ អញឲ្យអាឯងទៅនៅឯទន្លេ មានស្រុកណានៅប្របទន្លេទៅនៅចុះតាមចិត្តអាឯង កុំនៅក្នុងស្រុកនេះឡើយ ។ ធនញ្ជ័យស្តាប់ព្រះបន្ទូលហើយ ក្រាបថ្វាយបង្គំលាទៅដល់ផ្ទះហើយនិយាយប្រាប់ម្តាយថា លួងមានព្រះបន្ទូលប្រើឲ្យខ្ញុំទៅនៅឯមាត់ទន្លេ ឲ្យធ្វើស្រែរកស៊ីតាមចិត្ត ឯទន្លេនោះឲ្យជារបស់ខ្ញុំហើយ, ម្តាយស្តាប់ហើយក៏ថាបើដូច្នោះកូនទៅនៅតាមព្រះបន្ទូលចុះ ឯខ្ញុំម្តាយនៅផ្ទះនេះហើយ, ធនញ្ជ័យស្តាប់ម្តាយថាដូច្នោះហើយ ក៏លាម្តាយដើរទៅប្រាប់អស់នាហ្មឺននូវអស់ទាំងរាស្ត្រដែលនៅក្នុងទន្លេថា ដ្បិតលួងមានព្រះបន្ទូលឲ្យអញជាធំស្រដីក្នុងទន្លេទាំងអស់នឹងធ្វើស្រែស្រូវ ឥឡូវនេះអញប្រាប់រាល់គ្នាបើដើរជើងទឹកឲ្យប្រាប់អញ អញនឹងកត់ជាពន្ធ

ប្លៃទន្លេនឹងព្រែក ទុកដែលរកស៊ីសព្វថ្ងៃនេះជាព្រះរាជទ្រព្យ អំពីថ្ងៃនេះទៅ បើអ្នកឯណាមិនបានចូលមកប្រាប់អញ នឹងបានសេចក្ដីខុស អញនឹងធ្វើទោសតាមច្បាប់មិនប្រណីឡើយ ហើយធនញ្ជ័យយកឫស្សីដើមមកពុះជាបំរៀកតូច ៗ ត្បាញជាភ្នែកក្រូបកាត់ជា ៨ ជ្រុងហើយយកឫស្សី ១ ដើមវែងបងដាក់លើចុងឫស្សីហើយយកស្លឹកត្នោតដេរជាកណ្ដាប ហើយកាត់ជាស្លាបទង់ជ័យដោតលើចុងឫស្សី ហើយធ្វើឃ្នាងតូច ១ យកផ្ដៅធ្វើជារពាត់បងព្យួរជាមួយ នឹងភ្នែកក្រូបនោះឯង ហើយបញ្ឈរឡើង ហើយធនញ្ជ័យប្រាប់ថា នេះឈ្មោះត្របែងដៃឲ្យចូលប្រាប់គយ បើរាស្ត្រណាដើរជួញប្រែរកស៊ីឃើញត្របែងដៃគយឲ្យចូលប្រាប់ ទើបរួចទោស ប្រាមប្រាប់ដូច្នោះហើយ ក៏ចុះទូកចែវមើលតាមមាត់ទន្លេ ទីណាមានព្រែក កំពង់ណាល្មមធ្វើស្រែប្រាំងបានលុះមើលជុំវិញហើយមកកត់សំគាល់ឲ្យឈ្មោះតាមកំពង់តាមព្រែកទីនឹងធ្វើស្រែស្រូវខាងឯជើងបង្គួសមានស្ទឹង ១ ចុះមកក្នុងទន្លេឈ្មោះហៅស្ទឹងបារាយទឹកថ្លា ស្ទឹង ១ ទៀតចុះមកក្នុងទន្លេឲ្យឈ្មោះ បុងខ្មៀស មានជ្រោយ ១ ឈ្មោះជ្រោយស្លាព្រាហ្មណ៍ ទើប

មានព្រៃក ១ ឲ្យឈ្មោះឋាកំពង់ចាម មានព្រៃក ១ ឈ្មោះកំពង់ភ្លុក ព្រែក ១ ទៀតឈ្មោះស្ទឹងត្រីស្រុក ព្រែក ១ ទៀតហៅថាស្ទឹងជីក្រែង ព្រែក ១ ទៀតឈ្មោះពេជ្ឈគ្រី មានជ្រោយ ១ ទៀតឈ្មោះពេជ្ឈគ្រី មានព្រែក ១ ទៀតហៅតាមបាំង មានជ្រោយ ១ ទៀតហៅប្រទាស់ធេះ មានបន្លិប ១ ឈ្មោះបន្លិបប្រកែងនៅ បន្លិបប្រកែងនោះខាងឯមាត់ទន្លេឈ្មោះហៅនាងសៅ មានព្រែកឈ្លូងប្រទល់ ឯមាត់ទន្លេនោះឈ្មោះហៅបាយក្អែក មានកោះ ១ ទៀតឈ្មោះកោះប្លាស់ប្រើស មានព្រែក ១ ទៀតឈ្មោះព្រែកខ្សាប់ មានស្ទឹង ១ ឈ្មោះពាមសែន មានព្រែក ១ ឈ្មោះដាត់សណ្ដាយ មានព្រែក ១ ឈ្មោះព្រែកស្លត មានព្រែក ១ ទៀតឈ្មោះផ្លូវទូក មានកោះ ១ ឈ្មោះកោះក្អែ មានព្រែកពីរឈ្មោះព្រែកគូរ ១ ព្រែកក្រម៉ាល់ មានព្រែក ១ ឈ្មោះប្រឡាយមាស មានព្រែក ១ ទៀតឈ្មោះព្រែកក្បោក មានព្រែក ១ ឈ្មោះព្រែកបក្រវត្តិ មានព្រែក ១ ឈ្មោះព្រែកកំប៉ោងឃោងទឹក មានព្រែក ១ ទៀតឈ្មោះព្រះខ្សុប មានព្រែក ១ ទៀតឈ្មោះស្ទឹងពោធិ៍ មានកោះ ១ ឈ្មោះកោះសំ-

ណាញ់ មានព្រែក ១ ទៀតឈ្មោះព្រែកអារ៉ង មានកំពង់ ១ ឈ្មោះកំពង់អួរ មានកំពង់ ១ ទៀតឈ្មោះកំពង់ខ្សាប់ស មានកោះ ១ ទៀតឈ្មោះកោះកញ្ញ៉ានតូច មានកំពង់ ១ ទៀតឈ្មោះកំពង់ព្រះមាន មានកំពង់ ១ ឈ្មោះកំពង់អណ្តូង មានកោះ ១ ឈ្មោះកោះឆ្នុកទ្រូ មានព្រែក ១ ឈ្មោះព្រែកស្នាមធ្លក មានកំ-ពង់ ១ ឈ្មោះកំពង់ស្វាយក្រអៃ មានជ្រោយ ១ ឈ្មោះជ្រោយព្រះផ្តៅ មានកំពង់ ១ ឈ្មោះកំពង់ខ្សាប់ល្អិត មានកំពង់ ១ ឈ្មោះកំពង់ផ្លូវធំ មានជ្រោយ ១ ឈ្មោះជ្រោយបាហឹង មានកំពង់ ១ ឈ្មោះកំពង់ល្វង មានកំពង់ ១ ឈ្មោះកំពង់ប្រាក់ មានកំពង់ ១ ឈ្មោះកំពង់ទួល មានស្ទឹង ១ ឈ្មោះពាមព្រះស្ទឹង មានជ្រោយ ១ ឈ្មោះជ្រោយត្រដេវរីប មានកំពង់ ១ ឈ្មោះកំពង់ខ្លាឆ្លង មានជ្រោយ ១ ឈ្មោះជ្រោយផាត់សណ្តោង មានជ្រោយ ១ ឈ្មោះជ្រោយសន្លុងតូច ១ ឈ្មោះសន្លុងធំ ១ មានជ្រោយ ១ ឈ្មោះជ្រោយស្លាបស្ទាំង មានជ្រោយ ១ ឈ្មោះជ្រោយកញ្ញ៉ានធំ មានស្ទឹង ១ ឈ្មោះស្ទឹងដូនទ្រី មានស្ទឹង ១ ឈ្មោះពាមមាត់ពីរ ឲ្យជុំទន្លេហើយធនញ្ជ័យវិលមកឯកំពង់ប្រាក់វិញ ហើយមើលទី

នឹងធ្វើស្រែ ហើយដើរឡើងទៅព្រៃលើមើលស្ទឹងនោះ ល្មមនឹងធ្វើស្រែបាន ទឹកមានច្រើន បានជាឲ្យឈ្មោះបរិប្វាភិអំពីថ្ងៃនោះឯង ទើបឲ្យទួល ១ ជាឯកើតស្ទឹងខាងត្បូងឈ្មោះទួលរកា ខាងត្បូងទួលរកានោះមានវាល ១ ធំល្មមធ្វើស្រែសាបបាន ។ ជាឲ្យឈ្មោះថាវាលសាបអង្កាម ដ្បិតធនញ្ជ័យយកអង្កាមទៅសាបពេញវាលនោះឯង ឯទន្លេនោះធនញ្ជ័យហៅថាវាលភក់ ហើយយកអង្កាមទៅបាចពេញទន្លេនោះឯង ហើយគាត់ឲ្យហៅឈ្មោះទន្លេសាប ហើយធនញ្ជ័យឲ្យប្រាមថាបើនរណាបែរទូកឲ្យប្រយ័ត្នក្រែងវាខូចសំណាបអញ បើមិនស្តាប់អញនឹងចាប់ឲ្យសង ហើយលក់ជាប្រាក់ជម្លឹង ៣០ ជាប់ស្លឹលខូន ១ ទូក ១ ។

ឯអស់រាស្ត្របែរទូករកស៊ីក្នុងទន្លេនោះជាច្រើន នឹងបែរទៅឯណាឲ្យចៀសពីសំណាបនោះមិនបាន ឯធនញ្ជ័យក៏ចាប់ទូកអំបាលនោះថា បែរប៉ូលក្នុងសំណាប លក់យកប្រាក់បានទូក ១ ជាប្រាក់ ៣០ នោះឯង ឯអស់រាស្ត្រនោះខឹងហើយបបួលគ្នាឡើងទៅក្រាបទូលថា ដ្បិតធនញ្ជ័យទៅធ្វើស្រែក្នុងទន្លេនោះ

ហើយយកអង្កាមទៅបាចពេញអស់ទន្លេ ហើយប្រាមប្រាប់អស់យើងខ្ញុំថា កុំឲ្យចូលក្នុងសំណាបនោះ បើចូលនឹងចាប់លក់យកជាប្រាក់ ៣០ ជម្លឹងទុក ១ បើសេចក្ដីដូច្នោះនោះយើងពុំសុខចិត្ត សូមមេត្តាឲ្យកោះធនញ្ជ័យមកជំនុំឲ្យខានបានដឹងដំណើរ ដ្បិតយើងខ្ញុំមិនដែលឮព្រះបន្ទូលថា មានច្បាប់ចាប់លក់យកប្រាក់ហូតយកពន្ធរទេះគ្រប់ទិនិញក្នុងព្រះនគរ ដូចធនញ្ជ័យថានោះ ឯព្រះមហាក្សត្រស្ដាប់ហើយក៏គិតធ្ងល់ព្រះរាជហឫទ័យនឹងធនញ្ជ័យណាស់ ហើយត្រាស់ប្រើអមាត្យ ១ នាក់ថា អាឯងទៅហៅអាដែមកឲ្យឆាប់ កុំបង្អង់យូរឡើយ ឯអមាត្យស្ដាប់ព្រះបន្ទូលក៏ក្រាបថ្វាយបង្គំលាហើយ ដើរទៅរកធនញ្ជ័យ ឃើញហើយក៏ប្រាប់ថា ដ្បិតមានព្រះបន្ទូលពិសេស ឲ្យមកហៅធនញ្ជ័យឯង ឲ្យទៅជាមួយនឹងយើងជាព្រះរាជបម្រើនោះកុំឲ្យខានឡើយ បើខាននឹងខុសធនញ្ជ័យឯង ធនញ្ជ័យស្ដាប់ហើយស្លៀកសំពត់ពាក់អាវរួចហើយ ក៏ដើរទៅជាមួយនឹងបម្រើនោះឯង លុះទៅដល់ហើយក៏ចូលទៅក្រាបថ្វាយបង្គំគាល់ ចាំស្ដាប់ព្រះបន្ទូលស្ងៀមនៅ ។ ឯព្រះមហាក្សត្រ

ទតទៅឃើញធនញ្ជ័យមកដល់ហើយ ក៏មានព្រះបន្ទូលសួរថា អាដែអញឲ្យអាឯងទៅនៅឯទន្លេ ឲ្យរកស៊ីធ្វើស្រែយកស្រូវ ឥឡូវនេះអាឯងទៅធ្វើដូច្នេះតើអាឯងគិតដូចម្ដេច បើដូច្នេះឯងថាមកអញនឹងស្ដាប់; ទើបធនញ្ជ័យថាពុំបេះនឹងទ្រង់ព្រះមេត្តាអស់សេចក្ដីទាំងនេះទូលព្រះបង្គំជាខ្ញុំគិតឃើញថា កើតជានគរមានស្ដេចសោយរាជ្យហើយឲ្យបងជាច្បាប់ប្រាប់អស់នាម៉ឺនទូវពលឲ្យបានដឹង នេះឯងជាពន្ធព្រះរាជទ្រព្យ ឲ្យបានដឹងជាច្បាប់ជំនុំសេចក្ដីស្រដីគ្រប់មុខ ឲ្យនាម៉ឺនធំតូចដឹងជាសណ្ដាប់ប្រាប់អស់រាស្ត្រនៅស្រុកក្រៅឲ្យបញ្ចឹមចៅហ្វាយស្រុក ស្នង ក្រឡាពាសជំទប់ចៅមឿងមេស្រុក ទើបឲ្យបានដឹងអំពីខែត្រចៅហ្វាយស្រុកតូចតាមស័ក្តិយស ខ្នងពោះនាម៉ឺនក្នុងខ្នងពោះចៅហ្វាយស្រុកក្រៅឲ្យមានជាសណ្ដាប់ ប្រាប់ឈ្មោះចៅហ្វាយស្រុកមានជាដូច្នោះ ឈ្មោះខែត្រដូច្នោះ រួចហើយធនញ្ជ័យក្រាបទូលថា ខ្ញុំទូលបង្គំនឹងបង់បានជាទ្រព្យខ្លួនក៏ទេ ធ្វើដូច្នេះនេះបានជាអាការស្លួយក្នុងព្រះនគរ ដាក់ជាព្រះរាជទ្រព្យឲ្យបានដឹងតរៀងទៅ ។

សម្តេចព្រះមហាក្សត្រាធិរាជទ្រង់ស្តាប់ធនញ្ជ័យក្រាបទូលដូច្នោះហើយស្តេចមានព្រះបន្ទូលថា អាឯងថាដូច្នោះត្រូវហើយ តែដែលអាលក់រាស្ត្រនោះវាធ្ងន់ណាស់ អាយកតែបាទ ១ វិញ ។

ឯធនញ្ជ័យក៏បានទទួលព្រះបន្ទូលហើយក្រាបលាទៅយកបាត្រ ១ អំពីលោកសង្ឃហើយទៅប្រាប់អស់មនុស្ស ដែលបាប់លក់អំពីមុនថា ដ្បិតលួងមិនឲ្យយកប្រាក់ដម្លឹង ៣០ ទេ ថាវាធ្ងន់ណាស់ឲ្យអញយកបាទ ១ អំពីអស់ឯងវិញប្រាប់ហើយយកបាត្រមកវាល់ ឯអស់រាស្ត្រខ្លះនោះនឹងយកប្រាក់មកវាល់ឲ្យពេញបាត្រនោះមិនបាន, ធនញ្ជ័យក៏ប្រឹងទារ ឯអស់រាស្ត្រនោះរត់ទៅក្រាបទូលតុំបេះនឹងទ្រង់មេត្តាដ្បិតធនញ្ជ័យថា ម្ចាស់មិនឲ្យយកប្រាក់ ៣០ ដម្លឹង ឲ្យយកបាទ ១ ឥឡូវនេះគាត់យកបាត្រលោកសង្ឃមកវាល់វិញ ដូច្នេះឃើញជាធ្ងន់ណាស់ យើងខ្ញុំនឹងរកប្រាក់ឲ្យពេញបាត្រនោះមិនបានទេ, ឯព្រះមហាក្សត្រស្តាប់ហើយក៏ត្រាស់ប្រើឲ្យទៅហៅអាដែមកឲ្យឆាប់ ឯអមាត្យឮព្រះបន្ទូលប្រាប់ដូច្នោះហើយ ក៏ក្រាបថ្វាយបង្គំលាទៅហៅធនញ្ជ័យមកហើយមានព្រះបន្ទូលសួរថា អាដែអាថាអញឲ្យ

យកបាត្រទៅយកប្រាក់អំពីរាស្ត្រអង្កាល់ ឯធនញ្ជ័យក្រាបទូលថា ម្ចាស់មានព្រះបន្ទូលថាឲ្យយក ១ បាទវិញ កុំឲ្យយក ៣០ ដម្លឹងះឡើយ បានជាទូលព្រះបង្គំយកតាមព្រះបន្ទូលវិសេសនោះ ឯមហាក្សត្រស្ដាប់ហើយក៏មានព្រះបន្ទូលថា អញឲ្យយក៤ស្លឹងព្រាក់ថាយសព្វថ្ងៃនេះទេ ប៉ុន្តែគេហៅថា ១ បាទ ឥឡូវនេះអាយកតែបួនស្លឹងវិញ កុំយកបាត្រទៅរាល់នោះមិនត្រូវទេ ។

(មានតទៅទៀត)

# រឿងតាស់កោងកាង

# រឿងពស់កេងកង

នេះនឹងនិយាយព្រេងពីមុនដែលចាស់ទុំនិយាយតៗគ្នា មកថា កាលដើមនៅលើដីយើងនេះទាំងអស់គ្រប់នគរ មិនមានពស់ពិសនឹងពស់ឥតពិសអ្វីទេ មានតែពស់កេងកង ។

ថាកាលដើមមានមនុស្សប្ដីប្រពន្ធហើយមានកូនស្រីមួយ ឯប្ដីនោះមានប្រពន្ធឈ្មោះនាងរី កូននោះឈ្មោះនាងអេត ប្ដីនោះទៅជួញអង្កាំបាត់ឯអង្វែងយូរ ហើយជួនកាលមួយថ្ងៃ អស់បងប្អូនផ្ទះជិតខាង គេបបួលគ្នាទៅរកឧស ឯនាងរីឮគេបបួលទៅរកឧស ក៏ទៅជាមួយនឹងគេ ហើយហៅនាងអេត ជាកូនទៅផង លីដឹងចូលទៅក្នុងព្រៃ បានឃើញឧសមួយធំ នាងរីយកដឹងពុះឧស លុះពុះយូរបន្តិចទៅ ភារង្គោះធ្លាក់ដឹងទៅក្នុងរន្ធពស់ នាងរីមើលទៅឃើញដឹងនឹងពស់កេងកងនោះ ហើយនិយាយនឹងពស់ឲ្យហុចដឹង ឯពស់កេងកងឆ្លើយឡើងថា អើបើនាងដោយអញជាប្រពន្ធទើបអញឲ្យដឹង បើនាងមិនដោយអញជាប្រពន្ធនោះអញមិនឲ្យដឹងទេ ឯនាងរីឮ

ពស់កេងកងថាដូច្នោះហើយ ក៏ហេតុតែជាស្រីខូច ក៏ទទួលព្រមថាអើ លែងតែអ្នកឲ្យដឹងមកខ្ញុំ លុះដល់ល្ងាចសឹមខ្ញុំឲ្យមេអេតមកហៅ, ពស់កេងកងឮនាងរីថាដូច្នោះហើយ ក៏ឲ្យដឹងមកនាងរី នាងរីផ្ដាំថាដល់ល្ងាចសឹមឲ្យមេអេតមកហៅ. នាងរីក៏ទូលឧសទៅផ្ទះវិញជាមួយនឹងមេអេត លុះដល់ល្ងាចព្រលប់ហើយ នាងរីប្រើនាងអេតជាកូនទៅហៅពស់កេងកង លុះនាងអេតទៅដល់ហើយឈរនៅមាត់រន្ធពស់ថា ពស់កេងកងៗនាងរីឲ្យហៅ, ឯពស់កេងកងឮហើយក៏លូនចេញមក មេអេតឃើញហើយក៏ភ័យខ្លាចព្រឺស្ញើបអស់ទាំងខ្លួន ប៉ុន្តែខ្លាចម្ដាយប្រើមកក៏ខំសង្កត់ចិត្តហើយនាំពស់ទៅផ្ទះ, ឯពស់នោះធំណាស់លូនទៅលើឈើស្មៅបាក់រាបអស់, លុះដល់ផ្ទះហើយក៏ឡើងទៅដេកនឹងនាងរី, នាងរីនិយាយនឹងពស់កេងកងថា ខ្ញុំមានប្ដីឥឡូវនេះទៅជួញអង្កាំពីរបីឆ្នាំមកម្ដង, ពស់កេងកងសួរថាប្ដីនាងឯងនៅប៉ុន្មានថ្ងៃប៉ុន្មានខែទៀតនឹងមកដល់, នាងរីឆ្លើយឡើងថាមិនដឹងជាប៉ុន្មានខែប៉ុន្មានថ្ងៃទៀតនឹងមកដល់ទេ, ឯពស់នឹងនាងរីក៏ដេកលក់ជាមួយគ្នា លុះដល់រៀបភ្លឺហើយ ពស់

កេងកងក៏លានាងរីទៅរូងវិញ ហើយនាងរីផ្ដាំថាបើប្ដីខ្ញុំមកខ្ញុំមិនឲ្យមេអេតទៅហៅទេ អ្នកកុំមក បើប្ដីខ្ញុំមិនទាន់មកនោះខ្ញុំប្រើមេអេតជាកូនឲ្យទៅហៅអ្នក សឹមអ្នកមក នោះពស់កេងកងក៏ទៅរូងវិញ តែវេលាល្ងាចកាលណានាងរីប្រើមេអេតឲ្យទៅហៅ ឯមេអេតខ្លាចម្ដាយ ក៏ទៅហៅតាមពាក្យម្ដាយប្រើ ប៉ុន្តែក្នុងចិត្តខ្លាចពស់នោះណាស់ ដ្បិតពស់នោះធំហើយវែងផង, ១ទៀតខឹងក្នុងចិត្ត ដ្បិតម្ដាយសហាយនឹងពស់ នាងអេតទៅដល់មាត់រូងហើយហៅថាពស់កេងកង ៗ នាងរីឲ្យហៅ ឯពស់កេងកងឮហើយក៏លូនចេញមកឆ្លើយថា អេតៗអើយបើអញនឹងទៅ អាពុកអេតនៅកាត់កអញដាច់ នាងអេតឆ្លើយថា អាពុកអញទៅជួញអង្កាំពីរបីឆ្នាំមិនទាន់មកដល់, ឯពស់កេងកងឮនាងអេតប្រាប់ដូច្នោះហើយ ក៏លូនចេញអំពីរន្ធមកតែសព្វថ្ងៃដូច្នេះឯង ឯនាងរីសហាយនឹងពស់កេងកង លុះត្រាតែដើមដល់យូរបន្តិចទៅប្ដីនាងរីមកពីជួញអង្កាំ ហើយឃើញនាងរីពោះធំបន្តិចនឹកសង្ស័យ សួរមេអេតជាកូនមេអេតប្រាប់ឪភាថាម៉ែគាត់សហាយនឹងពស់កេងកង តែវេលាព្រលប់កាលណា, ឲ្យ

ខ្ញុំទៅហៅតែសព្វថ្ងៃដូច្នេះឯង អាពុកមេអេតឮមេអេតប្រាប់ដូច្នោះហើយ ក៏និយាយនឹងមេអេតថា ដល់ល្ងាចហាងឯងទៅហៅពស់នោះមកទៀត អញចាំកាប់នៅមាត់ទ្វារ ហើយហាងឯងកុំឲ្យម្ដាយហាងឯងដឹង, ឯមេអេតលុះដល់ព្រលប់ ក៏ទៅហៅពស់កេងកងថា ពស់កេងកងនាងរីឲ្យហៅ ពស់កេងកងឮហើយឆ្លើយថា អេតៗអើយបើអញនឹងទៅ អាពុកអេតនៅកាត់កអញដាច់ មេអេតឆ្លើយថាអាពុកអញទៅជួញអង្ករ ពីរបីឆ្នាំមិនទាន់មកដល់, ពស់កេងកងឮមេអេតប្រាប់ដូច្នោះ គិតស្មានជាអាពុកមិនទាន់មកពីជួញអង្ករមែន ហើយក៏ទៅដូចសព្វថ្ងៃ, ឯអាពុកមេអេតកាន់ដាវពួននៅមាត់ទ្វារចាំកាប់ ដល់ពស់កេងកងលូនចូលក្នុងទ្វារបន្ទប់ អាពុកមេអេតកាត់កពស់ដាច់ ហើយកាត់មួយកំណាត់កន្ទុយយកទៅដាក់លើស្អកមួយកំណាត់ក្បាលយកទៅដាក់លើមែកដើមពុទ្រា ឯកណ្ដាលខ្លួនឲ្យមេអេតយកទៅពន្លាត់ស្បែកចោលហើយផ្ដាំមេអេតថាកុំឲ្យម្ដាយហាងឯងដឹងហើយទុកសាច់ស្លឲ្យម្ដាយហាងឯងស៊ី, ឯអាពុកមេអេតលាងឈាមពស់ជ្រះអស់មិនឲ្យមានសល់,

នាងវីពុំបានដឹងជាប្ដីកាប់ពស់ជាសហាយស្លាប់ ជូននាងវីមិននៅទៅសួរបងប្អូននៅផ្ទះឆ្ងាយ លុះព្រឹកឡើងមេអេតយកសាច់ពស់មកស្ងោរទុកឲ្យនាងវីជាម្ដាយស៊ី នាងវីឃើញសំឡខ្លាញ់រលើបទាំងបានទាំងឆ្ងាញ់ហើយសួរមេអេតថា បានសាច់អ្វីស្លមេអេត ៗ ប្រាប់ថាសាច់ជ្រូក, ឯនាងវីគិតស្មានថាសាច់ជ្រូកមែនក៏ឲ្យនាងអេតដួសសំឡយកមកស៊ីបាយ, ឯនាងអេតដួសសំឡយកមកឲ្យនាងវីជាម្ដាយស៊ី, កាលនោះមានសត្វក្អែក ១ វាឃើញក្បាលពស់ដាក់លើមែកពុទ្រា វាចង់ស៊ីសាច់ពស់វាបួលថាក៏ល្ងូវ ៗ ក្លេមក្លមលេបសាច់ប្ដីឯង, នាងវីកំពុងតែស៊ីបាយឮក្អែកបួលដូច្នោះក៏មើលទៅលើដើមពុទ្រា ឃើញក្បាលពស់កេងកងលើមែកពុទ្រាហើយនាងវីនឹកអាណិតស្រក់ទឹកភ្នែក, តែនាងវីពុំហ៊ានយំព្រោះខ្លាចប្ដីអង្គុយស៊ីបាយជាមួយគ្នាប្ដីឃើញនាងវីស្រក់ទឹកភ្នែក ក៏សួរថាថ្វីបានជាស្រក់ទឹកភ្នែកនាងវីឆ្លើយថាស៊ីបាយក្ដៅសំឡក្ដៅ រលឹកកូនចោរលោងទឹកភ្នែក ឯក្អែកនោះបេះតែបួលថាក៏ល្ងូវ ៗ ក្លេមក្លមលេបសាច់ប្ដីឯងក្បាលដាក់លើមែកពុទ្រា កន្ទុយដាក់លើស្លាក នាងវីមើលទៅ

លើស្អាកឃើញកន្ទុយពស់កេងកងនៅលើស្អាក, ឯប្តីនាងរីដឹង ជាប្រពន្ធសហាយនឹងពស់កេងកងពិតប្រាកដហើយ នឹកភ្នក ក្នុងចិត្តខឹងចង់សម្លាប់នាងរី ប៉ុន្តែធ្វើមិនឲ្យនាងរីដឹងខ្លួន, ឯនាងរី ផើមចាស់ផ្ទៃជិតនឹងសំរាល, ជួន១ថ្ងៃប្តីនោះបបួលប្រពន្ធទៅកក់ នៅមាត់បឹង លុះដល់មាត់បឹងហើយប្រាប់ប្រពន្ធថាឲ្យទៅ ទៀតឲ្យឆ្ងាយពីស្រុកគេ យើងទៅកក់លេងឲ្យសប្បាយតែពីរ នាក់ នាងរីមិនដឹងខ្លួនជាប្តីសម្លាប់ គិតស្មានថាទៅកក់មែន ក៏ដើរចូលទៅក្នុងព្រៃឆ្ងាយទៅឃើញកំពង់ ១ រាបស្អាតរាបល្អ ហើយប្តីប្រាប់ប្រពន្ធថាឈប់កក់នៅត្រង់នេះចុះ កំពង់នេះរាប សប្បាយ យើងឈប់នៅនេះហើយ. ឯនាងរីមិនដឹងខ្លួនជាប្តី គិតនឹងសម្លាប់ ទៅអង្គុយកក់នៅមាត់ច្រាំង, ឯប្តីនោះក៏ហូត ដាវកាប់នាងរីពីក្រោយខ្នងមិនឲ្យនាងរីដឹង ហើយកាប់នាងរី ដាច់ពាក់កណ្តាលខ្លួនស្លាប់ទៅ ឯក្នុងពោះនាងរីនោះសុទ្ធតែ កូនពស់គ្រប់ចំពូក ពស់អ្វីក៏មានទាំងអស់ ប្តីនាងរីឃើញកូន ពស់លូនចេញអំពីពោះនាងរី ក៏កាប់នឹងដាវ ខ្លះលូនចូលទៅ

ក្នុងក្រហែងដី ខ្លះមុជក្នុងទឹក ខ្លះលូនចូលទៅព្រៃកាប់មិនទាន់ក៏មាន បានជាមានពស់លុះត្រាដល់ឥឡូវនេះ ។

និយាយពីរឿងពស់កេងកងជារឿងព្រេងតៗ គ្នាមកអំពីចាស់ទុំពីដើម បើនរណាមើលហើយកុំសើចតេះដៀលឡើយ ។

ចប់រឿងពស់កេងកងតែប៉ុណ្ណោះ ។

# បញ្ជីរឿង

ទំព័រ

១ ខេមាខេមសរណកថា ព្រះមហាពិទូរក្រសេម រៀបរៀង (ត) . . . . . . . . . ៦៩

២ ល្បើកប្រាប់ក្រិត្យក្រមរបស់ព្រះគ្រូវិសុទ្ធិវង្សី ទិត វត្តសិរីសាគរ ស្រុកត្របែក ព្រៃវែង . . . . . . . . . . . . . . . . . . . . . ៨៣

៣ ទំនៀមទម្លាប់ខ្មែរ ពិធីអាវាហវិវាហមង្គល បែបពោរកត្តះលើកគ្រែ ព្រះមហាពិទូរក្រសេមរៀបរៀង . . . . . . . . . . . . . . . . . . . . . ៩៧

## រូបក្រៅរឿង

១ នាងដី ជាតិភូមា នាំគ្នាទៅនមស្សការព្រះពុទ្ធរូប . . . . . . . . . . . . ៦៧

២ រូបភាពវត្ត សេទកីអាជិហា នៅកណ្តាលក្រុង មណ្ឌលេ ភូមា . . . . . ៨១

# TABLE DES MATIÈRES


| | Page |
|---|---|
| I. Khema-Khema Saranakatha ou Religions, refuge des hommes | 69 |
| II. Lois morales (Poème) | 83 |
| III. Mœurs et coutumes cambodgiennes — (mariage sous forme de présentation des vêtements religieux aux bonzes). | 97 |


## HORS TEXTE:


| | |
|---|---|
| I. Religieuses Birmanes s'en allant en pèlerinage, arrivées à la pagode Shwethalyaung — Pégou | 67 |
| II. Pagode de Setkyathiha la plus importante de mandalay... | 81 |


5



ភិក្ខុនី (ឬជី) ជាតិភូមា នាំគ្នាទៅនមស្សការព្រះពុទ្ធរូបនៅទីបូរាណស្ថានផ្សេង ៗ
វេលានេះមកដល់វត្តស្វេតឋាល្អុង ក្រុងបាគន ដើម្បីនមស្សការព្រះពុទ្ធរូបដ៏ ១ អង្គ
ជារបស់បូរាណ ។

ខេទាខេមសរណាកជា

(គ)

១– លទ្ធិកម្មលាងបាប ព្រោះមនុស្សទាំងឡាយកើតមកមានបាបជាកម្មពន្ធ, ជាប់តមកអំពីមនុស្សពីរនាក់ដំបូង គឺអាដាំនឹងនាងអេវ ទើបតោងធ្វើពិធីជំរះលាងសេសបាបនោះចេញ (ខនេះប្រហែលគ្នានឹងពិធីសិរិភត្រីរបស់ព្រាហ្មណ៍) អ្នកដែលបានធ្វើលទ្ធិកម្មលាងបាបនេះហើយ តោងរាប់ថាជាអ្នកខ្ជាប់ខ្ជួនមាំមួនក្នុងលទ្ធិគ្រិស្តង់បរិបូណ៌ មាទពិធីធ្វើថែមលើនោះទៀត គឺលាបប្រេង (តែឃើញខ្លះដូចជាលាបទឹក) របៀបដែលលាបត្រូវលាបទំនងជារូបឈើឆ្កាងដែលគេឆ្កាងព្រះយេស៊ូនោះ គឺលាបត្រង់កណ្ដាលថ្ងាសជាមុន ហើយរាសដៃចុះក្រោមមកលាបត្រង់កណ្ដាលទ្រូង នេះប្រៀបដូចជាឈើឆ្កាងដែលត្រង់ទៅលើ, លាបត្រង់បង្គួយស្មាខាងស្ដាំ ហើយរាសដៃត្រង់ទៅលាបបង្គួយស្មាខាងឆ្វេង នេះប្រៀបដូចជាឈើឆ្កាងទទឹង ឃើញជារូបយ៉ាងជើងក្អែក ដែលលាបត្រង់កណ្ដាលថ្ងាស សូមឲ្យព្រះបិតាគឺព្រះយៈហោវ៉ាស្ដេចមកស្ថិតនៅទីនោះ លាបត្រង់ចុងដង្ហើមសូមឲ្យព្រះបុត្រគឺព្រះយេស៊ូ មកស្ថិតនៅទី

នោះ លាបស្នាធ្មេងស្អំ សូមឲ្យព្រះវិញ្ញាណរបស់ព្រះអង្គមកស្ថិតនៅទីនោះ ។

២ – លទ្ធិកម្មដើម្បីកំលាំង

៣– លទ្ធិកម្មរំលោះលាបាប គឺធ្វើដើម្បីរំលោះបាបក្នុងខ្លួនឲ្យជ្រះស្រឡះអស់ទៅ បាននឹងពិធីលុតជង្គង់ទទួលសារភាពបាបដែលខ្លួនបានធ្វើកន្លងមកហើយ ក្នុងទីចំពោះមុខបព្វជិត (គឺអ្នកបួស) ក្នុងលទ្ធិនេះ ក្នុងរោងលទ្ធិសភា (គឺក្នុងវិហារ) របស់គេ ។

៤ លទ្ធិកម្មមហាសន្និទ្ធ គឺសូមឲ្យវិញ្ញាណរបស់ព្រះជាម្ចាស់មកស្ថិតអែបនែបសន្និទ្ធក្នុងកាយរបស់ខ្លួន ពិធីក្នុងខនេះគឺស៊ីនំបុាំងនឹងផឹកទឹកទំពាំងបាយជូរដែលសែកទុក តែសម័យឥឡូវនេះពួកគ្រិហស្ថបានស៊ីតែនំបុាំងមួយយ៉ាងជាការទទួលសីលទំពាំងបាយជូរសម្រាប់លោកសង្ឃដែលជាអធិបតីក្នុងពិធីនេះបរិភោគប៉ុណ្ណោះ ។

៥ លទ្ធិកម្មក្រោយបំផុត ដើម្បីឲ្យអ្នកដែលឈឺទៀបស្លាប់ជំរះបាបដែលសេសសល់មកអំពីដើមឲ្យអស់រលីងទៅ និងឲ្យមានកំលាំងស៊ូព្លូកបិសាច ដែលមកយាយីក្នុងខណៈនឹងមរណៈនោះផង ។

៦ លទ្ធិកម្មស្ថាបនា ដើម្បីរឹងតែងតាំងអ្នកបួសជាសង្ឃរាជឬជាចៅអធិការមេវត្ត ។

៧ លទ្ធិកម្មអាពាហពិពាហ គឺពិធីរៀបអាពាហ៍ពិពាហ៍នៅទីលទ្ធិសភា ។

ក្រៅអំពីនេះនៅមានពិធីមួយយ៉ាងទៀត គឺមនុស្សដែលស្លាប់ទៅហើយ បើវិញ្ញាណមានមន្ទិលជាប់នៅខ្លះ នឹងទៅកាន់ស្ថានបុគែតោរី គឺមិនទាន់ទៅនរកឬឋានសួគ៌ វិញ្ញាណនឹងទៅស្ថិតនៅក្នុងឋានកណ្ដាល បើសូត្របំរើនភាវនាអង្វរផ្សាយកុសលទៅ វិញ្ញាណអំបាលនោះនឹងរួចពាកទុក្ខបាន, បើបាបក្រាស់គឺធ្វើដោយបំណងចេតនាក៏ទៅនរក, បើគ្មានមន្ទិលនឹងទៅឋានសួគ៌តែម្ដង ។

ក្រឹតវិន័យដែលជាពាក្យប្រដៅក្នុងលទ្ធិនេះមានតែ ១០ ប្រការ គឺ

១ កុំឲ្យមានព្រះឯទៀតមកនៅចំពោះមុខអញ

២ កុំឲ្យធ្វើរូបគោរព ឬថ្វាយបង្គំរូបព្រះណាសោះ

៣ កុំឲ្យយកព្រះនាមព្រះជាម្ចាស់របស់ខ្លួនមកនិយាយលេង

៤ ត្រូវរំឭកដល់ថ្ងៃឈប់ នឹងធ្វើឲ្យថ្ងៃនោះបានបរិសុទ្ធ

៥ ត្រូវឲ្យកោតខ្លាចម្តាយឪពុកឯង

៦ កុំសម្លាប់គេឲ្យសោះ

៧ កុំឲ្យផិតគ្នាឲ្យសោះ

៨ កុំឲ្យលួចគេឲ្យសោះ

៩ កុំទទួលធ្វើបន្ទាល់ក្លែងឲ្យសោះ

១០ កុំឲ្យមានលោភឲ្យសោះ

ខ្លឹមសំខាន់ក្នុងលទ្ធិនេះ គឺកែណ្ណាឲ្យបង្អោនចិត្តជឿក្នុងព្រះជាម្ចាស់សួគ៌តែមួយព្រះអង្គប៉ុណ្ណោះ សិងកើតឡើងមុនទឹកដី មុនអ្វីៗទាំងអស់ រកដើមកំណើតនឹងទីបំផុតគ្មានគឺមិនប្រាកដដើម-

បុង ទ្រង់ស្ថិតនៅឯស្ថានសួគ៌មិនបេះប្រែប្រួល បើអ្នកណាមិនជឿនឹងដល់នៅសេចក្ដីវិនាសយ៉ាងទម្ងន់ ត្រង់បាបកម្មនោះបើទុកជាតាំងតែកើតមកមិនដែលធ្វើសោះ ក៏គង់តែមានបាបព្រោះជាប់ពូជបាបមកអំពីអាដាំនឹងនាងអេវ មានតែផ្លូវ ១ ដែលបាបរបស់មនុស្សនឹងរលាយទៅវិញបាន គឺឈាមវិសេសរបស់ព្រះយេស៊ូដែលគេបោះដែកគោលឆ្កាងភ្ជាប់នឹងឈើឆ្កាង ឈាមនោះហូរចេញមកស្រោចស្រង់លាងបាបមនុស្ស ដោយលោកទទួលសុគតដោយព្រះអង្គឯង ជាការទទួលរងបាបជំនួសមនុស្សទាំងឡាយ ។

ស្ដាប់មើលសេចក្ដីក្នុងលទ្ធិនេះតាមដែលពណ៌នាមកហើយ ដែលមិនបាននាំមកពណ៌នាក្ដី នាំឲ្យកើតសន្ទិះសង្ស័យជាច្រើន ១ តែនឹងមិនទទួលវិនិច្ឆ័យ គ្រាន់តែនាំសេចក្ដីសង្ស័យនោះមកតាំងទុកក្នុងទីនេះខ្លះ ឲ្យអ្នកស្វែងសរណៈពិចារណាហើយវិនិច្ឆ័យខ្លួនឯងចុះ ។

១ ០– ក្នុងគម្ពីររបស់លទ្ធិនេះអាងថាព្រះជាម្ចាស់សួគ៌កើតមុនអ្វី ៗ ទាំងអស់ មុនទាំងលោកគឺដីទឹកដែលយើងអាស្រ័យ

នៅសព្វថ្ងៃនេះទៅទៀត លោកនេះក៏កើតមានឡើងជាអង្វែងសែនកោដិឆ្នាំហើយ ហេតុម្ដេចព្រះជាម្ចាស់សួគ៌ទើបនឹងឲ្យបុត្រអង្គោលមកកើតក្នុងលោកប្រដៅសាសនា អាយុគ្រិស្ដសាសនាទើបនឹងកន្លងទៅបាន ១៩០០ ប្លាយឆ្នាំប៉ុណ្ណោះ ត្រង់ដែលអ្នកអាងថា ព្រះជាម្ចាស់សួគ៌មានមេត្តាករុណាដល់មនុស្សសត្វទាំងណាស់ ម្ដេចក៏មិនគិតប្រដៅសាសនាមកអំពីដើម បណ្ដោយឲ្យមនុស្សល្ងិតល្ងង់មិនស្គាល់សាសនាយូរដល់ម្ល៉េះ បណ្ដាមនុស្សដែលកើតមុនលទ្ធិនេះកន្លងបាត់បង់ទៅហើយ ដោយមិនបានទទួលប្រតិបត្តិតាមពាក្យប្រដៅរបស់លោក តើនឹងទៅកើតនៅទីស្ថានឯណា(?) អំណាចព្រះយេស៊ូដែលកើតឡើងខាងក្រោយនឹងទៅលោះលាងបាបអ្នកអំបាលនោះបានដែរឬ(?) អ្នកអំបាលនោះនឹងបានសុខទុក្ខដូចម្ដេច(?) គ្មានឃើញនិយាយដល់សោះ ខនេះតើនឹងឲ្យស្ដាប់ដូចម្ដេច (?)

១២ — បើព្រះយេស៊ូលោកសុខចិត្តទទួលបាបកម្មរបស់មនុស្សទាំងពួងដោយសុខស្លាប់ខ្លួនឯងដូច្នោះហើយ ហេតុម្ដេចក៏តោងមានកេណ្ឌឲ្យមនុស្សយកចិត្តទុកដាក់ជឿព្រះជាម្ចាស់នឹង

បញ្ញត្តិឲ្យមនុស្សប្រតិបត្តិតាមក្រឹត្យវិន័យទាំង ១០ នោះប្តី ទៀត ។

១ ៣– តាមក្នុងគម្ពីរព្យាករណសាស្ត្រ មានសេចក្តី ព្យាករណ៍ទុកថា "នឹងមានព្រះសង្គ្រោះ ១ អង្គជាបុត្រព្រះម្ចាស់ សួគ៌ចុះមកកើតក្នុងលោក ជាអ្នកមានអានុភាពមហិមា អាច កម្រាបសឹកសត្រូវក្នុងលោកឲ្យរាបទាប នឹងប្រកាសសាសនា ឲ្យផ្សាយទៅក្នុងលោក ហើយនឹងលើកជនជាតិយិវឲ្យធំលើ សាសន៍ឯទៀតទាំងអស់ក្នុងលោក" កាលព្រះយេស៊ូឧប្បត្តិ ឡើង មើលទៅមិនសមតាមពាក្យទំនាយនោះជាច្រើនៗ ហេតុ ម្តេចក៏ជឿថា យេស៊ូជាព្រះបុត្ររបស់ព្រះម្ចាស់សួគ៌ហើយ ។

១ ៤ កាលក្នុង ១ ៣ នេះមានសេចក្តីឃ្លៀងឃ្លាតខ្លះទៅ ហើយ នោះតើនៅមានតឹកតាងអ្វីទៀតដែលនឹងឲ្យជឿបានថា ព្រះយេស៊ូនឹងចុះមកប្រោសម្តងទៀតមែនក្នុងអនាគតកាល ។

១ ៥– ត្រង់ៗដែលថា "ព្រះជាម្ចាស់ទ្រង់ព្រះមេត្តាណាស់ រមែងបែងវិលែកព្រះវិញ្ញាណដ៏បរិសុទ្ធរបស់ព្រះអង្គឲ្យមកស្ថិតនៅ ប្រចាំថែរក្សាជីវិតមនុស្សសត្វ រហូតដល់ព្រឹក្សាលតាវល្លិ ហេតុ

ម្ដេចក៏មនុស្សទាំងនោះមានអាយុមិនស្មើគ្នា ខ្លះវែង ខ្លះខ្លី មិនជាការរើសមុខទៅហើយឬ? ឬនឹងតបថា ព្រោះមនុស្សមានបាបបុណ្យមិនស្មើគ្នា អ្នកណាមានបាបធ្ងន់ មិនត្រូវបែងព្រះវិញ្ញាណឲ្យទៅនៅគ្រប់គ្រងរក្សាវា បណ្ដោយឲ្យវាស្លាប់ទៅនឹងអាលទៅសោយទុក្ខឯនរកតាមយថាកម្មរបស់វា បើតបដូច្នេះក៏វាហីទៅបុះ តែត្រង់ទ្រឹក្សាលតារល្មិស្មោ វាធ្វើបាបកម្មអ្វីដែរ ក៏បានជាមានអាយុមិនស្មើគ្នា ម្ដេចព្រះជាម្ចាស់មិនមកស្ថិតនៅជ្រោមជ្រែងរក្សាជីវិតវាឲ្យរស់នៅដូចគ្នា ធ្វើដូច្នេះមិនជាការស្អប់ស្មោខ្លះ ស្រឡាញ់ស្មោខ្លះ ទៅហើយឬ? ។

៦– ត្រង់ដែលអាងថា សព្វការងារគ្រឿងប្រើប្រាស់ដែលមនុស្សអាស្រ័យសព្វថ្ងៃនេះគ្រប់មុខគ្រប់យ៉ាង សុទ្ធតែព្រះជាម្ចាស់មកជួយជ្រោមជ្រែងសាងឡើងទាំងអស់ បើតាមតែគំ-និតដំរេះរបស់មនុស្សនឹងធ្វើមិនកើតអ្វី១ លើកតួយ៉ាងឲ្យឃើញដូចយ៉ាងនឹងធ្វើនាឡិកា បើប្រសិនជាព្រះជាម្ចាស់មិនមកជួយ

ជ្រោមជ្រែងផងក៏គង់ជាធ្វើមិនកើត អើបើពិតដូច្នេះមែន ហេតុម្តេចអ្នកខ្លះធ្វើកើត អ្នកខ្លះធ្វើមិនកើត ម្តេចព្រះជាម្ចាស់មិនមកជួយសាងឲ្យធ្វើកើតទាំងអស់គ្នាទៅ ដូច្នេះនឹងឈ្មោះថាប្រកបដោយមហាករុណាបានឬ, ឈ្មោះថាមិនប្រកបដោយអគតិបានឬ (?) ។

១៣– តាមប្រវត្តិដែលពោលក្នុងគម្ពីរប៊ីព្លើសថាព្រះយេ-ស៊ូជាបុត្រនាងម៉ារី ជាត្រកូលពានិជជាន់ធម្មតា, អ្នកណាជាបិតា គេថា ព្រះយៈហោវ៉ាជាបិតា តែបើតាមគំនិតយើងតោងថា មិនដឹងជាអ្នកណាជាបិតា ព្រោះថាដើមកាលនាងម៉ារីនៅជាព្រហ្មចារិនីនៅឡើយ មានបុរសម្នាក់ឈ្មោះយោសេហ្វមកដណ្តឹង លុះរៀបអាពាហ៍ពិពាហ៍ស្រេចហើយតែនៅមិនទាន់បានរួមសំវាសគ្នាសោះ ស្រាប់តែឃើញនាងម៉ារីមានគភ៌ទៅហើយ យោសេហ្វនឹកអៀនខ្មាសក៏គិតរកឧបាយនឹងលែងលះនាង តែទទួលយប់នោះយោសេហ្វយល់សប្តិឃើញជាទេវទូតមកប្រាប់ថា យោសេហ្វ អ្នកកុំសង្ស័យឡើយ កូនក្នុងផ្ទៃនាង

ម៉ារីនោះជាកូនព្រះម្ចាស់សួគ៌ ដល់កូននោះសម្រាលចេញមក ធំឡើង នឹងមានបុណ្យអស្ចារ្យ យោសេហ្វជឿក៏ឈប់លះលែងគ្នាទៅ ខនេះត្រូវគិតថា បើព្រះយេស៊ូជាកូនព្រះជាម្ចាស់មែន ក៏ត្រូវយល់ថា ព្រះជាម្ចាស់មកសេពនាងម៉ារី ទើបមានកូន ទាំងមិនខុសអំពីតំរាវេជ្ជសាស្ត្រផង បើព្រះជាម្ចាស់មិនបាន សេពទេ នឹងថាកូនព្រះមិនបាន ។ តាមខទាំងឡាយដែលបាន ពណ៌នាគួរឲ្យអ្នកកាន់សរណៈនឹងគប្បីពិចារណាមើល ។

(មានតទៅទៀត)



រូបភាពវត្តសេទគីអាចិបោ ជាវត្តធំបំផុតនៅកណ្ដាលក្រុងមណ្ឌលេ ជាទីក្រុង ១ ដែលប្រតិបត្តិតាមពុទ្ធសាសនាយ៉ាង
ស័ខាន់នៅស្រុកភូមា ។

## រឿងច្បាប់ក្រិត្យក្រម

៙នេះនឹងថ្លាថ្លែងចែងបារបង  លើកតាមទម្លង់ជាកាព្យ
ប្រាម្ពីរពាក្យពិតគិតប្អូនឃ្លា  បងជានិទានទុកប្រដៅ ។
អស់ទាំងកុមារក្មេងតូច ៗ  ចិត្តឯងនៅខូចច្រើនខ្លាំងខ្លៅ
ស្រើបស្រាលដោយសារខ្លួនឆោតឆៅ មិនតាមប្រដៅគ្រូខ្នាន។
កាលណោះព្រះពុទ្ធសាស្នា  កន្លងហើយណាបានពីរពាន់
ប្អូនរយចិតសិបបីគ្នេរគ្នាន់  ឯខែសោតណាកន្លងគ្មាន ។
ថ្ងៃកន្លងបានម្ភៃពីរ  នឹងគិតការញ្ញេរក្នុងបច្ចុប្បន្ន
ឆ្នាំមមីទោស័កក្នុងគម្ពួន្ន  ឧត្តរខែជេស្ឋប្រាំបីកើត ។
កោនុនាមអាត្មាភាព  បំរើនការប្រាប់ឈ្មោះកំណើត
ទិត គិតពីគ្រោះឃើញអម្ពហេតុ  កើតធម្មបង្វែគចេញបញ្ញា ។
សាមសិបប៉្លាយឆ្នាំជាកំណត់  ហៅវិត្តសិរីសោគរា
ឃុំខណ្ឌត្របែកក្នុងគាថា  រួមខែត្រព្រៃវែងស្រុកបាភ្នំ ។
ខ្ញុំមានសិស្សកុមារច្រើន  ស្រដីជាស់តឿនវាមិនចាំ
បានជាគិតលើកល្បើកក្រិត្យក្រម  ឲ្យរៀនចិតខំកុំឲ្យធ្វេស ។

ហៃអស់ពួកក្មេងកុមារា ចាំទុករាល់គ្នាកុំប្រហែស
ប្រតិបត្តិតាមបែបយ៉ាងន័យនេះ អ្នកកុំសន្តិះនឹងបេះបាន ។
ភ្ញាក់ឡើងពីព្រឹកនឹកបំណោះ ដែលខ្លួនរៀនបេះចាំប៉ុន្មាន
ទន្ទេញឲ្យស្ទាត់មាត់កុំខាន ដ្បិតទើបនឹងបានរៀនថ្មីៗ ។
ហើយឲ្យអ្នកផ្ទៀតរៀនអក្សរ អក្ខរាឲ្យល្អរៀនសិដី
នព្វន្តខ្មែរបិនឲ្យស្ទាត់ដៃ លោកិយនេះគ្រាន់ប្រឡំគេ ។
ហើយឲ្យអ្នកផ្ទៀតរៀនបាឡី នោះទើបគប្បីកុំទំនេរ
មេសូត្រឲ្យស្ទាត់ចាំមាត់ទេ ដល់បាទៅប្រែងាយអាចារ្យ ។
បើប្រែរួចហើយទៅដល់ស្ពាន កុំខ្ជិលប្រាស់ប្រាណបោះសាស្ត្រា
ពីដៃហើយដេកធ្មេចនិទ្រា មិនត្រូតត្រាការវិជ្ជាខ្លួន ។
បំណាំវិភត្តុបទបច្ច័យ អាចារ្យប្រាប់ន័យចាំឲ្យមួន
តោងអានរំឭកមើលថៃខ្លួន បើប្អូនភ្លេចស័ព្ទសួរគ្នាឯង ។
ញាប្អូរប្រតិបត្តិសួរអាចារ្យ វិបត្តិអក្ខរាឲ្យជាក់ស្តែង
សូមទានករុណាប្អូរសម្តែង ឬថ្លែងប្រោសប្រាប់តទៅទៀត ។
អាចារ្យសម្តែងប្រាប់សិស្សថា អក្ខរៈមាលាតាមដោយហេតុ
នឹងប្រើអក្សរតាមសង្កេត រៀបរយតាមភេទចាំឲ្យជាក់ ។

របៀបប្រើពាក្យក្នុងលោកិយ ប្រើឲ្យគប្បីតាមអក្ខរៈ
លោកយកប្រកបនឹងតួស្រៈ ជាពាក្យទីឃៈរស្សៈខ្លី ។
ទីឃៈលោកប្រើពាក្យយ៉ាងវែង រស្សៈនោះឯងប្រើពាក្យខ្លី
ឯស្រៈមាននៅក្នុងបាឡី នោះមានប្រាំបីតួអក្ខរ ។
បើពាក្យណាសុទ្ធបាឡីបំ លោកយកមកផ្សំនឹងពាក្យប្រែ
ដូចជាពាក្យថាអ្នករៀនស្នេហ៍ នោះត្រូវការមេព្រោះហេតុកាម ។
ពាក្យមួយលោកថាធ្វើគ្រូពេទ្យ ក្នុងអាណាខេត្រសត្វប្រែតប្រាំ
ពាក្យថាកិលេសវិសេសសាំ ព្រះតេជះចាំព្រះមហាបេរ ។
យ៉ាងនេះយកស្រៈ(េ)មកប្រើ ដាក់តាមពាក្យស្មើដូចពាក្យខ្មែរ
បាអានសំនៀងឲ្យបង្វែរ ជាពាក្យស្រៈ(ែ)វិញណាបា ។
ដ្បិតពាក្យស្រៈ(ែ)យ៉ាងនេះនៃ នៅក្នុងបាឡីគ្មានឡើយណា
មានតែស្រៈ(េ)អក្ខរា នេះលោកពោលថាប្រើខុស(ែ)។
ហេតុនោះបានលោកយកមកប្រើ តាមបែបបទស្មើភាសាប្រែ
យក (េ) នេះឯងតាងស្រៈ (ែ) ចាំឲ្យជាប់ថៃណាចៅណា ។
ឯរឿងបទស្រៈឧទាហរណ៍ ដែលត្រូតអក្សរមេ- កកា
ទុកសម្រាប់ប្រើក្នុងភាសា ក្រុងកម្ពុជាធិបតី ។

ចូរបាអានឲ្យប្រុងប្រយ័ត្ន　　កុំឲ្យបង់បាត់បែរសេចក្តី
អានកុំបំភ្លាត់បំភ្លៃស្តី　　តាមន័យពាក្យឃ្លាងឃ្លាយរមុខ ។
ចូរបារាំងទាំងតួខ្យល់　　ប្រុងប្រយោគដល់ហោយទំនុក
ប្រយ័ត្នកុំអានឲ្យទង្គុក　　ប្រលួសទៅមុខហួសមិនត្រូវ ។
សេចក្តីពាក្យណាមើលមិនបំ　　កុំហ៊ានបន្លំខ្លួងទៅ
ចូរបាបង្អាក់ឈប់ចាំនៅ　　ទៅសួរលោកគ្រូសន្សំមថ្លែង ។
កុំគិតបិត្តព្រើលខ្ចប់តែផ្តាស　　ទៅគិតអៀនខ្មាសនឹងគ្រូឯង
មិនហ៊ាននឹងសួរនឹងសម្តែង　　ថ្លែងសួរពីរឿងហេតុនានា ។
យ៉ាងនេះដូចមានក្នុងបាឡី　　ឫរាណលោកស្តីៗគ្នា
ខ្មាសគ្រូបាធ្យាយគ្មានវិជ្ជា　　ខ្មាសភរិយាពុំមានកូន ។
ខ្មាសមហាក្សត្រខាតយសយាន　　ខ្មាសធ្វើសីលទានគ្មានបុណ្យជូន
ខ្មាសធ្វើការងារសាបស្នាត់សូន្យ　　ខ្មាសញាតិបងប្អូនគ្មានភ្ញៀវឡើង ។
ខ្មាសខំកំដរខានប្រើការ　　ខ្មាសស៊ីអាហារពោះផិតស្ដើង
ខ្មាសបុណ្យយសស័ក្តិពុំបានច្រើន　　ខ្មាសពួកអ្នកយើងខានធ្វើបុណ្យ ។
ខ្មាសបាវភ្នាក់ងារគ្មានអាជ្ញា　　ខ្មាសពាក្យមោសាលក់ខាតទុន
ខ្មាសអន្តេវាសិកខានដើរមុន　　ខ្មាសអ្នកមានគុណខានធ្វើការ ។

ខ្មាសកូនខានស្តីប្រៀនប្រដៅ ខ្មាសអ្នកព្រៀងក្រោថយអំណាច
ខ្មាសពាលល្ងង់ខ្លៅមានគេខ្លាច ខ្មាសបណ្ឌិតប្រាជ្ញពេញព្រៀលធំ ។

ពាក្យចាស់ពីព្រេងតែងប្រឌិត មានមកមែនពិតដោយនិយម
ពាក្យនេះមានមកពីបរម បុរាណចាស់ទុំថាដូច្នេះ ។
ធម្មតាឯបិតុគ្រូអាចារ្យ តាំងនមស្ការឲ្យសិស្សបេះ
ពុំមានលាក់លៀមទុកបំណោះ បង់ឲ្យសិស្សបេះសព្វសេចក្តី ។
មួយទៀតរឿងដែលនឹងសិក្សា បំណោះវិជ្ជាក្នុងលោកិយ
លោកថាប្រកបដោយអង្គបី នោះគឺស្មារតីនឹងប្រាជ្ញា ។
ព្យាយាមជាទីគំរប់បី ប្រែជាសេចក្តីគឺឧស្សាហ៍
រីឯស្មារតីគឺសញ្ញា កំណត់កត់ត្រាការអ្វីៗ ។
ប្រាជ្ញាវាងវៃតាមបញ្ញត្តិ ជាអ្នកអារកាត់សព្វសេចក្តី
ទៅខាងបរលោកឬលោកិយ កែខ្លួនឲ្យបានស្អាតល្អ ។
បើបានគ្រប់ព្រមទាំងអង្គបី ប្រាជ្ញារៀនអ្វីសោតពុំក្រ
សម្បត្តិក្នុងខ្លួនទាំងបីប- រិបូណ៌បានល្អជាអ្នកបេះ ។
រីឯស្មារតីគឺចេតសិក ឲ្យចាំរំឭកនឹកជម្រិះ
កំណត់បំណាំចាំបំណោះ បរិបូណ៌បានបេះស្របរិយា ។

ទោះបីបើមានប្រាជ្ញាច្រើន ថាបើចំរើនកោសល្លា
កំជិលខ្ជិលក្រៃមហិមា ពុំអាចធ្វើជាអ្នកចេះបាន ។
ថាហែអស់អ្នកពួកទារក ចូរឲ្យចាំទុកក្នុងអង្គប្រាណ
ឧស្សាហ៍ព្យាយាមយកឲ្យបាន ទុកជាច្បាប់កាន់រក្សាខ្លួន ។
មួយទៀតឯអ្នករៀនព្រះត្រៃ- បិដកថាថ្លៃតាមចំនួន
លោកថាប្រកបដោយអង្គ ៤ នោះគឺ សុ ចិ បុ លិ ចាំ ។
សុ ប្រែថាឲ្យប្រឹងស្តាប់គេ ចិ គិតគាញ់គ្រូវខំចំណាំ
បុ ឲ្យសាកសួរតាមលំនាំ លិ គឺឲ្យចំឡងដកទុក ។
ធម្មតាអ្នករៀនរឿងបាឡី គឺព្រះត្រៃបិដកជាមុខ
ចូរបាទប្រឹងសរសេរទុក ក្រែងភ្លេចទៅមុខបានមើលសព្វ ។
ថាបើប្រកបដោយអង្គ ៤ បានគ្រប់ចំនួនដោយអណ្តាប់
សិក្សារៀនសូត្រក៏ចេះឆាប់ និងបានជាបណ្ឌិតវោហារ ។
ថាបើបាឃ្លាតប្រាសចាកជួន ពីអង្គក្នុងខ្លួនបួនប្រការ
នោះឯងពុំបានជាអាចារ្យ រៀនដល់ចាស់ណាក៏ពុំចេះ ។
ព្រះពុទ្ធដីកាព្រះអង្គត្រាស់ ទ្រង់ថ្លែងប្រកាសទុកដូច្នេះ
កុមារអ្នកខំប្រឹងត្រេកត្រេះ គិតរករៀនរះអស់វិជ្ជា ។

ឯបំណេះសិល្បសាស្ត្រសព្វ　　បើបានបេះចប់គ្រប់ហើយណា
មិនបាច់នឹងព្រួយអង្គអាត្មា　　ទៅរកកាប់ឆ្កាភ្ជួរស្រែព្រៃ ។
ហាបើនឹងទៅទីស្ថានណា　　នឹងមានឈ្មោះនាមប្រាកដល្បី
ពុំបាច់នឹងនឿយព្រួយស្តាយវៃ　　ដើរតាមក្រោយគេទេណាចៅ ។
ឬមួយនឹងទៅផ្គាប់ផ្គុនស្ដេច　　នោះឯងមិនបាច់ទៅហាលក្ដៅ
ករុណាកាន់ទ្រង់ប្រោសប្រាណចៅ　　ឲ្យបាសស័ក្ដិទៅជាអគ្គហាន ។
ទោះបីក្រខ្សត់អត់ញាតិផៅ　　គង់តែគេហៅរករាប់អាន
ស្រឡាញ់ទុកដូចជាសន្តាន　　គ្រាន់បានពឹងពាក់គ្រាមានទុក្ខ ។
ធម្មតាវិស័យរៀងបំណេះ　　បើបាបានបេះច្រើនគ្រប់មុខ
ទោះបីបើនឹងមានទោសទុក្ខ　　គង់តែបានសុខស្រួលក្សេមក្សាន្ត ។
បំណេះវិជ្ជាលោកថែងចាត់　　ទុកជាសម្បត្តិសំបូណ៌បាន
ទោះបីក្រខ្សត់អតប៉ុន្មាន　　គង់តែបាបានគ្រាន់អាស្រ័យ ។
សម្បត្តិនៅស្ថាននាលោកិយ　　មាសប្រាក់ប្រក្រតីនៅសព្វថ្ងៃ
សឹងតែប្រកបទៅដោយភ័យ　　បាត់បង្សៀតនៃជាអនិច្ចំ ។
រីឯសម្បត្តិគឺបំណេះ　　បើបាបានបេះដោយកំឡាំង
ផាប់វែងផិរាបយាវជីវ័ង　　សឹងទៀងបិត្តតាំងដល់ខ្លួនស្លាប់ ។

ពុំដែលមានអ្នកណាជា អាចធ្វើវិជ្ជាឲ្យអន់អ័ប្ប
ទោះបីដល់ភ្លើងប្រល័យកប្ប ក៏ពុំអាចឆាបឆេះអន្តរាយ ។
ហៃហៃអស់ពួកកុមារា ចូរបានឧស្សាហ៍ខំខ្វល់ខ្វាយ
សង្កេតកំណត់កុំឲ្យម៉ាយ តាមពាក្យបរិយាយយើងពណ៌នា ។
រីឯវិជ្ជានាលោកិយ ប្រយោជន៍សិរីសួស្តីជា
នឹងជួយឲ្យបានទ្រព្យនានា ក្រេមក្សាន្តសុខក្នុងលោកនេះ ។
រីឯវិជ្ជាគឺព្រះត្រៃ- បិដកថ្លាថ្លៃកុំសង្ខិះ
ប្រយោជន៍ទាំងនៅក្នុងលោកនេះ ដរាបដល់ទិសទិព្វលោកនាយ ។
ជាស្បៀងជាប់ស្បៀងរូបអាត្មា គាំអង្គរូបាបាកទុក្ខសោក
ទៅកាន់ខេមស្ថានបរមោក្ខ និព្វានស្ថានលោកជាអវសាន ។
◎ ឥឡូវបញ្ឈប់ស្លេះបរហ អក្ខរមាលាប៉ុណ្ណេះបាន
និយាយអំពីក្មេងគ្រប់ប្រាណ ប្រដៅទូន្មានតទៅទៀត ។
មនុស្សយើងត្រូវខំរៀនបំណោះ ឲ្យបានចាំបេះមិនបង្អៀត
បញ្ញាណាក្រយើងកែឆ្លៀត ប្រៀតយកសេចក្តីឲ្យងាយស្តាប់ ។
គ្នាជាអ្នកល្ងង់ចូលមកសួរ អ្នកប្រាប់ឲ្យគួរតាមសណ្តាប់

ធម៌អាចិណ្ណាក្របាថ្លែងប្រាប់ សារស័ព្ទតាមធម៌តាមសេចក្ដី ។
នឹងមានកិត្តិសព្ទសូរពីរោះ នឹងមានកេរ្តិ៍ឈ្មោះខ្ពស់ឧត្ដម
នឹងមានប្រាជ្ញាពីលោកិយ នឹងមានសិរីសួស្ដីប្រាណ ។
យកចិត្តទុកដាក់នឹងបំណោះ អ្នកកុំប្រហែសធ្វេសគិតខាន
ខ្វះបរិយាមួយដូចខាតច្រើន បាទំក្រវើនណាអ្នកណា ។
នឹងបានភ្លឺច្បាស់សព្វសេចក្ដី ភ្លឺដូចរស្មីសែងសុរិយា
ភ្លឺច្បាស់ត្រចះនឹងនេត្រា ភ្លឺថ្លាដួងចិត្តឥតសង្ស័យ ។
តែបានរៀនច្រើនកើតបំណោះ តែពេះការច្រើនជាបច្ច័យ
តែខំរៀនសូត្រារាល់ខែថ្ងៃ ដូចផ្លែឡូងពេជ្រលេចពន្លឺ ។
បើមានបំណោះពេះវិជ្ជា បើនឹងស្ដីថាច្រើនគេឮ
បើប្រកបការគេជួយធ្វើ បើមានជម្ងឺជួយភ័ក្ដី ។
បើបានពេះហើយនឹងមានឈ្មោះ សូរសព្ទពីរោះខ្ពស់ឧត្ដម
មានពាក្យសរសើរពីលោកិយ ដល់បរលោកទៃសុខក្សេមក្សាន្ត។
បើបារៀនសូត្រខំខ្មីឃ្មាត ខ្នះខ្នែងសង្វាតកុំឲ្យខាន
ឲ្យខាតវេលាវិជ្ជាប្រាណ ចិត្តត្រេកកំសាន្តតាមទំនើង ។

កុំនិយាយគ្នាណាអារ៉ាំ ឲ្យខាតវិជ្ជារបស់យើង
បើគេនិយាយបាញ្ញើឆ្មើង កុំតតបឡើងជាប់សំដី ។
ដោះឡើងដើរចេញទៅរករៀន បំណោះរៀនតាមសេចក្តី
ដែលត្រូវការរៀនវិជ្ជាអ្វី តែជាប់និយាយខានរៀនសូត្រ ។
មួយទៀតកុំបារៀនចិត្តឈ្លោះ ប្រកែកទ្រគោះរៀនឲ្យស្លូត.
សំដីគេលើសបាកុំស្រែក រុតរះបង់ឈ្លះឥតអំពើ ។
រស់តែចិត្តត្រូវបាធ្យាយ ជំនុំអភិប្រាយរកសើរើ
ឃើញទោសហើយផ្លាស់ខំដំណើរ អ្នកណាគេប្រើឲ្យឈ្មោះល្អ ។
ធម្មតាជាអ្នករៀនសិស្សសេក កុំរៀនកាចពេកណាអារ៉ាំ
គួរខ្លាចរំពាត់គួររាំងរា ចិត្តកាចនោះណាគួរទៀយណាយ ។
មួយទៀតរឿងល្បែងលេងមិនសុខ ច្រើនតែមានទុក្ខបៀតបៀនកាយ
លោកថាលេងច្រើនៗឈ្លោះហើយ តែរេងរៀយៗត្រូវរំពាត់ ។
អ្នកអើយធម្មតាកើតជាមនុស្ស ឲ្យដឹងគាប់ខុសទើបគេរាប់
កុំរៀនធ្វើល្មើសលើសនឹងច្បាប់ ប្ដូរស្ដាប់ពាក្យនេះចាំទុកទៅ ។
គំនិតសេកសិស្សអ្នកនៅវត្ត ប្រុសប្រាណប្រតិបត្តិឲ្យត្រឹមត្រូវ

កោតខ្លាចលោកគ្រូដាងម៉ែឳ   ចូលទៅប្រតិបត្តិកុំឲ្យអាក់ ។
បាបៀកម្ហូបស្លាម្ហូបបារី   ប្រគេនហើយខ្ចីរៀបរួសរាក់
ថែទាំដាំទឹកក្ដៅត្រដាក់   ទុកដាក់របស់តាមរបៀប ។
បើលោកហៅប្រើការអ្វី ៗ   រវៀសរួសដៃជាប្រញាប់
យកចិត្តទុកដាក់ជាដរាប   លោកប្រាប់យើងធ្វើតាមព្រះទ័យ ។
ផ្ដាប់គ្រូមិនសួរមានគ្រោះខ្លួន   បើផ្ដាប់ឲ្យមួនកុំសង្ស័យ
ខុសពីរបីដងលោកអភ័យ   បើមានបំណាំទុកឲ្យស៊ុំ ។

  ◎ ឥឡូវបញ្ឈប់រឿងទារក   នឹងលើកស្នេះទុកតសេចក្ដី
ពីត្រឹមណោះទៅលើករឿងថ្មី   ទុំគ្មានប្រុសស្រីគ្រប់រាល់ខ្លួន ។
នឹងថ្លែងពីរូបយើងរាល់គ្នា   កើតក្នុងសាស្នាគិតឲ្យមួត
បើមិនប្រយ័ត្នខ្លាចក្រែងប្អូន   សោះសូន្យមិនកើតឥតអំពើ ។
បំណាច់កើតទាន់ក្នុងសាស្នា   គួរគិតប្រាជ្ញាកុំពព្លើ
យកចិត្តទុកដាក់ធុរះជឿ   ក្រែងឥតអំពើរបងរូបកាយ ។
ខំស្វែងរករៀនធម៌បរមត្ថ   ប្រុងចិត្តប្រយ័ត្នគិតឲ្យឆ្ងាយ
ជីវិតយើងនេះនឹងអន្តរាយ   សុទ្ធសឹងតែស្រាយឥតខ្លឹមសារ ។

ឥតមានអ្វីយកជាទីពឹង   ពិតជាពុំពឹងស្លាប់ថ្ងៃណា
ហេតុដ្បិតរូបនេះអនិច្ចា   ជាអនត្តាពុំឃ្លៀងឃ្លាត ។
ហេតុដូច្នោះឯងប្រុសស្រី   កើតក្នុងលោកិយគួរខំឃ្នាត
រក្សាសីលទានខំសង្វាត   ចិត្តកុំប្រមាទដូចពណ៌នា ។

មានមកក្នុងច្បាប់នេះស្រាប់ហើយ   មិនមានខុសឡើយរៀងរាល់ឃ្លា

សំគាល់ចាំទុកទៅមុខជា   គ្រឿងអាវុធការសត្រូវ ។
អ្នកខំសំគាល់ធម៌សុខុម   ធ្វើជាអារម្មណ៍ចាំទុកទៅ
រាល់រូបមុខជាមិនវែងត្រូវ   ការស្លាប់នោះនៅរាល់រូបពិត ។
អ្នកអើយអ្នកខំត្រិតត្រៀងផ្ចាត់   កុំថាតែចាស់ស្រេចនៅចិត្ត
សព្វថ្ងៃចិត្តយើងគួរពិនិត្យ   ដ្បិតចិត្តបុណ្យបាបប្រឡំគ្នា ។
ចិត្តណាខិលខូចបណ្ដេញចេញ   កុំឲ្យវាឃ្នាញ់ក្នុងរូបា
វានាំឲ្យទុករូបវេទនា   កើតទុក្ខកាលណាវារត់ហោល ។
រូបយើងសព្វថ្ងៃចិត្តធំណាស់   ធំជាប់បង្អស់ជាបង្គោល
អាខ្លះជាភ្លើងតែងដុតរោល   អាខ្លះពាលពោលឲ្យវង្វេង ។
អាខ្លះវាធ្វើឲ្យធុញថប់ . បុណ្យសីលទានស្អប់គ្មានកោតក្រែង

ខ្លះតាំបំផ្លាញឫក្សខ្លួនឯង    ឲ្យធុញរង្វៀងនឹងកាមគុណ ។
ខ្លះវាតាំលួចប្រពន្ធគេ    អាខ្លះបង្វៃរឲ្យលួចប្លន់
អាខ្លះកាប់ចាក់មិនគិតគន់    អាខ្លះលោភលន់បោកប្រាស់គេ ។
ហៃអស់មហាជនទាំងឡាយអើយ,    បើដូច្នេះហើយចូរអ្នកគ្នេរ
អ្នកទុករក្សាមិនបានទេ    ល្មមអ្នកវាយដេរបណ្ដេញចេញ ។
វានៅវាតាំបំផ្លាញរូប    អ្នកអើយកុំឱបកុំស្រឡាញ់
ទាត់ចោលឲ្យឆ្ងាយពីខ្លួនចេញ, តែអ្នកស្រឡាញ់ខូចខ្លួនហើយ។

# ពិធីអាពាហ៍ពិពាហ៍មង្គល

## រៀបមង្គលការ បែបលើកត្រៃ

មានរបៀបរៀបមង្គលការ ១ បែបទៀត ជារបស់កើតមានមកតាំងពីបុរាណកាលមកដែរ តាមសំដីដែលអ្នកស្រុកហៅថា "ការលើកត្រៃ" ក៏មាន "ការវេរភត្ត" ក៏មាន ៗ មូលហេតុដែលកើតមានរបៀបការបែបនេះឡើងមកពីអ្នកទាំងសងខាងជាអ្នកទ័លក្រ ពុំនោះសោតអ្នកទាំងសងខាងជាសម្មាទិដ្ឋិ ជាអ្នកបាំសីលរក្សាធម៌តាមបែបព្រះពុទ្ធសាសនា ជាអ្នកខ្លាចបាបខ្ពើមបាប មកពិចារណាឃើញថា ការដែលរៀបមង្គលការតាមទំនៀមទម្លាប់បូរាណនោះ មានទាក់ទាមដោយផ្លូវបាបកម្មនឹងការឥតប្រយោជន៍ជាច្រើន ដូចយ៉ាងការសម្លាប់សត្វយកមកស្លៀងគ្នា ការស្លៀងសុរាគ្នា អំពាលនេះជាការដែលមានទោស, ការឡើងអ្នកតាម្ចាស់ស្រុក ការសែនដល់ក្រុងពាលី ការពលិការដល់ទេវតា អំពាលនេះជាដើមជាការឥតប្រយោជន៍ បើជាឧបាសកឧបាសិកា អាចនឹងជាប់ឬសៅហ្មងសរណគមន៍

ក៏បាន តាមអាការនៃទឹកចិត្តដែលខ្លួនរាប់អានទីងផ្ញើទៅ ។ អ្នកដែលជាឧបាសកឧបាសិកា ត្រូវលះវៀរអំពើបាបទាំងពួង ត្រូវមានទឹកចិត្តមូលមួយបំពោះគោរពរាប់អានជឿតែក្នុងព្រះពុទ្ធ-ព្រះធម៌ ព្រះសង្ឃប៉ុណ្ណោះ មិនត្រូវឲ្យមានចិត្តបែកខ្ញែករាយមាយទៅគោរពរាប់អានជឿវត្ថុដទៃឲ្យស្មើឬឲ្យលើសព្រះពុទ្ធ - ព្រះធម៌ ព្រះសង្ឃ ទៅ ខនេះសូម្បីសាសនាដទៃក៏ប្រដៅឲ្យគោរពរាប់អានជឿតែក្នុងកំលុងសាសនានោះ ៗ ដូចគ្នា គឺកើតមកជាកូនអ្នកណា ត្រូវរាប់អានគោរពអ្នកនោះឲ្យធ្ងន់ជាងគេ ។

១ ទៀត សេចក្ដីយល់ឃើញរបស់បុគ្គលជំពូកនោះថាការដែលរៀបឲ្យកូនមានប្ដីប្រពន្ធ ហៅថា "មង្គលការ" តាមផ្លូវព្រះពុទ្ធសាសនា ដែលនឹងហៅថាដូច្នោះបាន លុះតែការនោះគ្មានទោស បើការនោះប្រកបដោយទោសនឹងហៅដូច្នោះពុំបានដោយអាងរឿងមង្គល ៣៨ ប្រការ ដែលមានមកក្នុងមង្គលសូត្រ ក៏សុទ្ធតែឲ្យលះវៀរការបាបការឥតប្រយោជន៍ផ្សេង ៗ មានមិនគប់ពាល គប់តែបណ្ឌិតជាដើម ។ ដើម្បីនឹងបំពេញកិច្ចនោះឲ្យចូលក្នុងផ្លូវមង្គលមែន ៗ ឲ្យសមតាមឈ្មោះដែល

ហៅ នឹងឲ្យសមតាមភាពខ្លួនដែលជាឧបាសកឧបាសិកា គេទើបកាត់ចោលរបៀបដែលមានទោសនឹងឥតប្រយោជន៍នោះ ៗ ចេញ បំបែរកិច្ចនោះឲ្យចូលក្នុងពិធីសង្ឃជាធំទៅវិញ បានកាត់ចោលទំនៀមទម្លាប់បុរាណជាច្រើនប្រការ គឺ: សុរា, សត្វមានជីវិត, ភ្លេង, ច្រៀងរាំ, ការមើលឫក្ស, ការតាំងអ្នកមហា, ការសែនដូនតា, ការសែនអ្នកតាម្ចាស់ស្រុក, ការសែនក្រុងពាលី, ការពលិការទេវតា, ការសែនក្បាលជណ្ដើរ, ការរៀបផ្លែឈើ, ការជុំពេលា, ការយកពេលា, ការដោតផ្កាស្លា, ការសំពះផ្កាស្លា, បង្វិលពពិល, រាំបើកបាយសី, ការគោះបង់រង, រាំសាកន្ទេល, លេងភ្លេងលត់បន្ទុះ, អំបាលនេះគ្មាន ៗ នៅមានតែការបែបបួរ, ការដណ្ដឹង, ការជូនរបស់បញ្ចុំចិត្ត, ការបង្គាប់ឲ្យធ្វើផ្ទះជាដើម, ការជូនពេលា, ការសូត្រមន្ត ថែមការថ្វាយបង្ហាន់នឹងត្រៃចីវរដល់សង្ឃ, វណ្ដាប់ខាន់ស្លា, ផ្កាស្លា, ការផ្ទុំដំណេក, ទាំងអំបាលនេះនៅមាន ៗ

បណ្ដាកិច្ចការនឹងគ្រឿងភ័ស្តុភារបណ្ណាការ អំបាលដែលជានៅធ្វើដូចរាយឈ្មោះមកខាងលើនោះ ប្រការខ្លះក៏នៅធ្វើ

តាមរូបដើមទាំងស្រុងក៏មាន ប្រការខ្លះក៏ត្រូវកាត់ត្រូវកែទៅ មិនបានគង់វង់នៅតាមប្រវេណីដើមទាំងមូលក៏មាន ដូចជានឹងបានពណ៌នាតទៅដោយលំដាប់ ។

## ១— ការចែចូវ

របៀបចែចូវតាមទំនើបថ្មីមានតែ ១ ជើង អ្នកចែចូវត្រូវមានភស្តុភារ គឺស្លាម្លូ បន្តិចបន្តួច ហៅរបស់កំដរដៃទៅផងតាមទំនៀម កាលទៅដល់ហើយ គប្បីនិយាយស្ទាបស្ទង់ថា សូមលោក- អ្នកអភ័យទោស ដ្បិតលោក- អ្នកឈ្មោះនោះមានពឹងពាររកខ្ញុំឲ្យមកសូមជំរាបសួរអំពីកូនស្រីលោក- អ្នកនេះ ជាមានទាក់ទិនទៅឯណាហើយ ឬនៅទំនេរនៅឡើយ សូមទានប្រសាសន៍ជាដំណឹង ។

បើគេមិនប្រុងនឹងឲ្យ គេនឹងតបថា មានទាក់ទិនទៅហើយ ឬថាកូនខ្ញុំនៅក្មេងណាស់ មិនទាន់គិតនឹងទុកដាក់ឲ្យមានគូស្រករនៅឡើយ សូមកុំឲ្យលោក- អ្នកឯណោះទៅមកឡើយ ។

បើគេប្រុងនឹងឲ្យ គេនឹងតបថា មិនមានទាក់ទិនក៏ដូចជាទាក់ទិនទៅហើយ បើអ្នកចង់ជ្រាប ឧស្សាហ៍អញ្ជើញទៅមកគង់ជានឹងជ្រាប ។ ប៉ុណ្ណោះឈ្មោះថា ស្រេចការចែចូវហើយ ។

## ២ — ការដណ្ដឹង

*ជើងដំបូង*

របៀបដណ្ដឹងតាមទំនៀមនេះមាន ២ ជើង គឺដណ្ដឹងដោយអ្នកផ្ញើរស្រី ១ ជើង ដណ្ដឹងដោយអ្នកមហា ១ ជើង គ្រឿងភ័ស្ដុភារបណ្ណាការត្រូវមានតាមសមគួរ គឺគ្រឿងស្លាគ្រប់មុខ, ផ្លែឈើផ្សេងៗ, នំផ្សេងៗ រៀបដាក់តោកជាគូៗ ដូចសព្វដង ។ ជើងដំបូងនេះត្រូវបាត់ឲ្យអ្នកផ្ញើរស្រី ៣ នាក់ទៅដណ្ដឹង អ្នកផ្ញើរនិយាយដណ្ដឹងត្រង់ៗ តែម្ដង មិនបាច់និយាយវាសវាងយ៉ាងទំនៀមបុរាណ គឺថា សូមជំរាបអស់លោកមេបា សូមបានជ្រាប ដ្បិតអ្នកសាមីដើមការឈ្មោះនោះ បានពឹងពារកខ្ញុំទាំង ៣ នាក់ ឲ្យមកក្រាបបង្គំសម្ពន្ធមេត្រី ដោយសូមដណ្ដឹងនាង

ឈ្មោះនោះជាកូនលោកមេបា ឲ្យជាភរិយាឯាយឈ្មោះនោះ ជាកូនអ្នកសាមីដើមការ បើលោកមេត្តាឲ្យទាន នឹងបានលើកគ្រឿងបណ្ណាការជូនពីសា ។

មេបាត្រូវតបថា ការនេះយើងជាមេបាក៏មិនបានទំលក្រអ្វីដែរ ក៏ប៉ុន្តែយើងទុកដាក់តែម្តងពុំបាន ដ្បិតអ្នកជាអ្នកផ្ញើរនេះជាស្ត្រីស្រដីការធំពុំជាប់ស្រេច ក្រែងទទួលការផ្ដុកផ្ដាល់អំពីយើងជាមេបាពុំបាន (បើពុំដែលស្គាល់សាមីខ្លួនកូនប្រុសត្រូវថា) ១ ទៀត យើងមេបាពល់ត្នាពុំដែលឃើញរូបឆោម នៃសាមីខ្លួនកូនប្រុសនោះឯង ដូច្នេះសូមអ្នកទៅជំរាបអ្នកសាមីខ្លួនដើមការ ឲ្យពឹងរកបុរសដែលមានសតិបញ្ញាស្គាល់ការរាក់ជ្រៅឲ្យមកនិយាយការនឹងយើង ហើយទើងឲ្យនាំខ្លួនកូនប្រុសមកឲ្យយើងស្គាល់ផង ។

ប៉ុណ្ណោះហើយ អ្នកផ្ញើរត្រូវលើកគ្រឿងបណ្ណាការជូនទៅមេបា ហើយត្រឡប់មកវិញ ។

## ៣ — ការដណ្តឹង

### លើកទី ២

#### ជូនរបស់បញ្ចាំចិត្ត

កាលឲ្យអ្នកផ្សំទៅដណ្តឹងដឹងទំរោយដូច្នោះហើយ ក្នុងឱកាសណាមួយ អ្នកសាមីដើមការត្រូវរៀបរណ្តាប់គ្រឿងបណ្ណាការផ្សេង ៗ នំផ្សេង ៗ រៀបដាក់តោកជាគូ ៗ តែឲ្យមានមុខរបស់នឹងចំនួនឲ្យច្រើនជាងជើងមុន នឹងរបស់បញ្ចាំចិត្ត ជាគ្រឿងមាសគ្រឿងពេជ្រ, សំពត់, អាវ ក្រមា នឹងគ្រឿងស្លា ១ គ្រឿងទៀតរៀបដាក់រង ១ ស្រេចហើយចាត់ឲ្យអ្នកផ្សំ ៣ អ្នកមហា ៣ នាក់ ឲ្យនាំទៅកាន់ត្រកូលខាងស្រី ព្រមទាំងឲ្យនាំសាមីខ្លួនកូនប្រុសទៅផង ។

ការដណ្តឹងក្នុងវារៈទី ២ នេះសូមឲ្យជ្រាបថា របៀបពាក្យដែលអ្នកផ្សំនិយាយក្តី ដែលអ្នកមហានិយាយក្តី ការពិនិត្យរូបឆោមកូនប្រុសក្តី ការជូនបណ្ណាការក្តី រមែងទៅតាមទំនៀមទម្លាប់បូរាណដោយច្រើនដូចមានពោលហើយក្នុងរឿងការតាមទំនៀម ប្លែកតែបែបនេះ មិនប្រើសុរា សត្វមានជីវិត អ្នក

មហាទី ១ មិនបាច់ពាក់អាវផាយ អ្នកមហាទី ២ មិនបាច់មាន ដបសុរានឹងពែងសុរាប៉ុណ្ណោះ ។

កាលពួកមេបាពិនិត្យរូបកាយកូនប្រុសរួចហើយ ព្រមព្រៀងឲ្យកូនហើយ នឹងទទួលគ្រឿងបណ្ណាការហើយ លំដាប់នោះអ្នកមហាត្រូវជំរាបមេបាសុំឲ្យបង្គាប់ពីរឿងធ្វើផ្ទះ នឹងភស្តុ-ភារបណ្ណាការដែលនឹងរៀបការហើយទៅថ្ងៃមុខ តើត្រូវមានអ្វីខ្លះ ។ ពួកមេបាត្រូវបង្គាប់ទៅតាមធនធានរបស់អ្នកសាមីដើមការ បើត្រូវឲ្យធ្វើផ្ទះក៏បង្គាប់ពីរឿងធ្វើផ្ទះទៅ បើមិនត្រូវការឲ្យធ្វើផ្ទះទេ ក៏ត្រូវបង្គាប់តែគ្រឿងបណ្ណាការទៅ តាមទំនៀមដែលគេធ្លាប់បង្គាប់មកហើយដូច្នេះ ។

៤ — គ្រឿងបណ្ណាការ

១- ត្រៃបីរ

២- ខាន់ស្លា

៣- ផ្កាស្លា ៣ ។

ឯត្រៃបីរនោះ គេបង្គាប់យក ៤ ត្រៃក៏មាន ៦ ត្រៃក៏មាន ៨ ត្រៃក៏មាន ១០ ត្រៃក៏មាន បង្គាប់ឲ្យជូនត្រៃប៉ុន្មាន ត្រូវ

និមន្តព្រះសង្ឃប៉ុណ្ណោះរូប ។ តែបើជាអ្នកទីទ័លណាស់ គេបង្គាប់ឲ្យមានតែត្រៃ ១ ក៏មាន ប្តូនកាលឲ្យមានតែស្បង់មួយ ៗ តាមចំនួនព្រះសង្ឃក៏មាន ប្តូនកាលគ្មានសោះ គ្រាន់តែវេរបង្ហាន់សង្ឃក៏មាន ។ ឯខាន់ស្លាត្រូវមានជាដរាប ព្រោះមានក្នុងច្បាប់បញ្ញត្តិទុកថា ដែលនឹងទុកជាប្រពន្ធដែលត្រឹមត្រូវតាមច្បាប់បាន លុះតែមានខាន់ស្លាតាមទំនៀមស្រុក មកដល់សម័យនេះ លោករាប់ការបុះនាមក្នុងសៀវភៅអាពាហ៍ពិពាហ៍ផង ។ ផ្កាស្លាជារបស់សម្រាប់បាចឲ្យពរ ត្រូវមានដែរ ។ បំណែកឯអាហារលៀងភ្ញៀវនោះត្រូវមានជាធម្មតា តែគេហាមមិនឲ្យយកសត្វរស់មកសម្លាប់ធ្វើម្ហូប ត្រូវទិញជ្រូវសាច់សត្វដែលគេសម្លាប់ស្រាប់សឹងមានលក់នៅតាមផ្សារ ហើយគេមិនបង្គាប់ថា របស់នេះត្រូវមានប៉ុណ្ណោះ របស់នោះត្រូវមានប៉ុណ្ណោះទេ គេគ្រាន់តែប្រាប់ចំនួនថា ភ្ញៀវមានប្រហែលប៉ុណ្ណោះនាក់ ភ្ញៀវខាងប្រុសមានប៉ុន្មាន អ្នកសាមីដើមការត្រូវគិតលៃលករកមកឲ្យខាងតែគ្រប់គ្រាន់ ទាំងបង្ហាន់ព្រះសង្ឃក៏ត្រូវគិតរួមជាមួយគ្នានោះផង ។

ការចែចូវក្តី ការដណ្តឹង រហូតដល់គ្រឿងបណ្ណាការនឹងរបៀបកិច្ចការទាំងពួងក្តីដែលទៅជាការសង្ខេបដូច្នេះបាន មកពីអ្នកម្ចាស់ការទាំងសងខាង បានដឹងន័យគ្នាទៅវិញទៅមក ដោយខាងស្រីបានបន្ទយបន្ធូរពាក្យឲ្យខូរខ្វាយទៅថា "បើអ្នកណាមកដណ្តឹងកូន កាលឃើញថាត្រូវដិងត្រូវផ្តិតគ្នាហើយ នឹងមិនបាច់ឲ្យរៀបចំធំដុំទេ" ដូច្នេះ ព្រមទាំងប្រឹក្សាគ្នាក្នុងពេលដែលដណ្តឹងព្រមព្រៀងគ្នាជាស្រេចដូច្នោះ ចំណែកឯខាងប្រុសវិញ បើជាអ្នកសម្មាទិដ្ឋិក ហើយត្រូវការរៀបមង្គលការតាមរបៀបនេះ សោត គេរមែងជ្រើសរើសដណ្តឹងតែក្នុងត្រកូលសម្មាទិដ្ឋិកដូចគ្នាឲ្យល្មមតែនិយាយគ្នាបាន ។

## ៥— ផ្ទឹមពេលា

កាលដល់ឱកាសណាមួយដ៏សមគួរហើយ អ្នកសាមីដើមការត្រូវកំណត់ពេលាជូនទៅខាងស្រី សុំអនុញ្ញាតរៀបមង្គលការកូន ។ បើមិនមានធុរៈជាទមួន់ទេ មេបាខាងស្រីត្រូវអនុញ្ញាតឲ្យគេ ។ កាលព្រមព្រៀងគ្នានឹងរៀបមង្គលការហើយមុននោះ ៨ ថ្ងៃ ត្រូវប្តឹងមន្ត្រីអត្រានុកូលដ្ឋានឲ្យបេញប្រកាសផង ។

## ៦ – ផ្តើមបង្គលការ

កាលដល់កំណត់ថ្ងៃនោះហើយ អ្នកសាមីដើមការ ត្រូវដឹកនាំភ័ស្តុភារបណ្ណាការអំបាលនោះទៅឯផ្ទះដែលនឹងរៀបការ ដើម្បីនឹងធ្វើមង្គលការតទៅ របៀបធ្វើមង្គលការបែបនេះគេធ្វើយ៉ាងយូរត្រឹម ២ ថ្ងៃគឺ ថ្ងៃផ្តើមមង្គលការ នឹងថ្ងៃមង្គលការ ។ ថ្ងៃដំបូងវេលារសៀល គេរៀបចំរើនបរិត្តនៅផ្ទះការ អ្នកសាមីដើមការត្រូវយកត្រៃមកដំកល់ដាក់លើតោកឬជើងពាន ហើយរៀបជាជួរតាមមុខព្រះសង្ឃ នឹងផ្កាស្លាទាំង ៣ ក៏រៀបដាក់ជើងពានទាំងខ្វះ យកមកចូលក្នុងពិធីសូត្រមន្តនេះដែរ នឹងត្រូវមានទឹកអប់ដែលអប់ដោយគ្រឿងក្រអូប ១ ផ្តិល យកមកដាក់ត្រង់មុខលោកដើមអាសនៈ ។ ព្រះសង្ឃដែលនឹងនិមន្តមកត្រូវគិតតាមចំនួនត្រៃ ។ កាលព្រះសង្ឃមកចំរើនបរិត្ត សាមីខនកូនប្រុសស្រីត្រូវរៀបចំស្លៀកពាក់តែងកាយតាមសមគួរ គឺស្លៀកពាក់របស់ថ្មី ៗ មិនបាច់រើសព័ណ៌ កូនប្រុសមិនបាច់ពាក់អាវផាយ កូនស្រីមិនបាច់ពាក់ស្បៃនឹងរបៃ កូនប្រុសត្រូវស្លៀកបងក្បិនតាមធម្មតា កូនស្រីស្លៀកសំពត់សិទ្ធប្រេក់បាន បង

ក្បិនក៏បាន ហើយចូលទៅស្ដាប់ធម៌ លោកដើមអាសន៍ត្រូវរលាស់ប្រស់ទឹកមន្តឲ្យកូនប្រុសស្រី ។

## ៧ — លៀងអាហារភ្ញៀវ

កាលព្រះសង្ឃបំរើនបរិត្តរួចហើយ ដល់វេលាព្រលប់ត្រូវលៀងអាហារភ្ញៀវដែលអញ្ជើញមកក្នុងឱកាសមង្គលការនេះ អាហារដែលលៀងភ្ញៀវគ្រប់ពេល សម្រេចដោយកប្បិយ-មំសៈ គឺសាច់សត្វដែលគេសម្លាប់ទុកស្រាប់សឹងមាននៅតាមផ្សារ, ក្នុងឱកាសមង្គលការបែបនេះ នឹងប្រាសចាកសំឡេងជ្រូកមាន់ទាជាដើមស្រែក ដោយត្រូវគេសម្លាប់យកសាច់មកលៀងភ្ញៀវ នឹងប្រាសចាកទឹកស្រវឹង ត្រឡប់ជាមានទឹកតែមកជំនួស ។ ពួកភ្ញៀវកាលពិសាររួចហើយ ត្រូវចងដៃមញ្ញាប់ព្រលឹងដោយប្រាក់នឹងរបស់ទ្រព្យផ្សេង ៗ តាមទំនៀម តែការខ្លះអ្នកសាមីដើមការគេហាមមិនឲ្យភ្ញៀវចងដៃក៏មានដែរ ។

## ៨ — មង្គលការ

បាចផ្កាស្លា-ជូនប្រាក់ខាន់ស្លា-ថ្វាយបង្គាន់-ថ្វាយត្រៃ

វេលាព្រឹកឡើងក្នុងរោងម៉ោង ៧ ព្រះសង្ឃដែលនិមន្តមកបំពេញបរិត្តពីម្សិលមិញ និងពួកមេបាចាស់ទុំទាំងខាងប្រុសខាងស្រីត្រូវមកឲ្យជុំគ្នា ដ្បិតវេលានេះជាវេលាមង្គលធំ សាមីខ្លួនកូនប្រុសស្រីត្រូវចេញមកអង្គុយទន្ទឹមគ្នានៅទីចំពោះមុខព្រះសង្ឃកាលជួបជុំគ្នាដូច្នោះហើយ មាតាបិតាឬអាណាព្យាបាលទាំងខាងកូនប្រុសទាំងខាងកូនស្រី ត្រូវថ្លែងបាឋកថាប្រកាសប្រាប់ឲ្យសាមីខ្លួនកូនប្រុស-ស្រី និងពួកញាតិជ្រាបទួទៅ តែត្រូវមាតាបិតាឬអាណាព្យាបាលខាងកូនប្រុស ប្រកាសឡើងមុនដូច្នេះ ។

ឱកាសនេះយើងខ្ញុំទាំងប្ដីទាំងប្រពន្ធ សូមថ្លែងឲ្យសាមីខ្លួនកូនប្រុស- ស្រី និងបណ្ដាញាតិមិត្រទាំងឡាយជ្រាបទូ-ទៅ ដ្បិតពីថ្ងៃមុនយើងខ្ញុំបានពឹងពាររកអ្នកផ្ដើមហាឲ្យមកសូមដណ្ដឹងនាងឈ្មោះ..... នោះ ជាបុត្រីលោក-អ្នកឈ្មោះ.....នេះ ឲ្យជាភរិយាឈ្មោះនាយ....នេះ ជាបុត្ររបស់យើងខ្ញុំ នោះលោកអ្នកឈ្មោះ.....នោះក៏បានអនុញ្ញាតតាមដែលសុំ ឱកាសនេះបានព្រមព្រៀងគ្នាទាំងសងខាង រៀប

មង្គលការផ្សំផ្គុំឲ្យនាយ ..... នោះនឹងនាងនោះជាប្ដីប្រពន្ធនៃគ្នានឹងគ្នាតាមប្រវេណីលោក តាំងពីវេលានេះជាដើមទៅ ដោយអំណាចគុណព្រះរតនត្រ័យ ដែលយើងគោរពរាប់អានសព្វថ្ងៃ សូមឲ្យកូនប្រុស-ស្រីគូនេះ បានន្ធូវសេចក្ដីសុខ សេចក្ដីចំរើនតទៅ ។

លំដាប់នោះមាតាបិតាឬអាណាព្យាបាលខាងកូនស្រីត្រូវថ្លែងឡើងដូច្នេះ "ឱកាសនេះយើងខ្ញុំទាំងប្ដីប្រពន្ធ សូមថ្លែងឲ្យសាមីខ្លួនកូន ស្រី-ប្រុស នឹងបណ្ដាញាតិមិត្តទាំងឡាយជ្រាបទូទៅ ដ្បិតពីថ្ងៃមុនលោកអ្នកឈ្មោះ......នោះ បានពឹងពររកអ្នកផ្លូវចោមហាឲ្យមកស្ដីដណ្ដឹងនាងឈ្មោះ...នេះជាបុត្រីយើងខ្ញុំ ឲ្យជាភរិយាឈ្មោះនាយនោះជាបុត្ររបស់លោកអ្នកនោះ យើងខ្ញុំព្រមដោយមេត្តាតូចធំក៏បានអនុញ្ញាតតាមដែលសុំ ឱកាសនេះបានព្រមព្រៀងគ្នាទាំងសងខាង រៀបមង្គលការផ្សំផ្គុំឲ្យនាង......នោះនឹងនាយ......នោះជាប្រពន្ធជាប្ដីនៃគ្នានឹងគ្នាតាមប្រវេណីលោក តាំងពីវេលានេះជា

ដើមទៅ ដោយគុណព្រះរតនត្រ័យដែលយើងគោរពរាប់អាន សព្វថ្ងៃ សូមឲ្យកូនស្រី- ប្រុសគូនេះ បាននូវសេចក្ដីសុខ សេចក្ដីចំរើនតទៅ ។

កាលថ្ងៃងបារកបោរួបហើយ ត្រូវនាំគ្នាសុំសីល ៗ រួច ហើយព្រះសង្ឃត្រូវសូត្រធម៌ឲ្យសាធុការពរ គឺត្រូវសូត្រធម៌ពុទ្ធ- គុណា- ធម្មគុណា- សង្ឃគុណា- ពហុទេវា- អាកាសដ្ឋា- ជយន្តោ សព្វពុទ្ធា- ភវតុ ។ សាមីខនកូនប្រុស- ស្រី ត្រូវបួលដាក់បាត្រ ដោយចាប់វែកមួយជាមួយគ្នាដួសបាយដាក់ទៅ ។ កាលព្រះ សង្ឃសូត្រមកដល់ធម៌ជយន្តោ ត្រូវប្រគេនផ្កាស្លា ១ ទៅលោក ឲ្យលោកបាចឲ្យពរកូនប្រុស-ស្រី ។

កាលព្រះសង្ឃសូត្រចប់ហើយ មាតាបិតានឹងពួកមេបា ចាស់ទុំត្រូវយកផ្កាស្លា ១ មកបែកគ្នាបាចនឹងឲ្យសព្ទសាធុការ ពររៀងខ្លួន ។ រួចកិច្ចនេះហើយត្រូវប្រគេនចង្ហាន់ដល់ព្រះសង្ឃ ការថ្វាយចង្ហាន់នេះ ប្តូនកាលគេលើកប្រគេនទៅតែម្តងក៏មាន ប្តូនកាលគេសូត្របាឡីរោរផង រួចហើយលើកប្រគេនទៅក៏មាន

សាមីខ្លួនកូនប្រុស-ស្រី ត្រូវចូលទៅប្រគេនដោយខ្លួនឯង ។

កាលព្រះសង្ឃឆាន់ហើយ ត្រូវប្រគេនត្រៃចីវរ ការប្រគេនត្រៃចីវរនោះ ប្លួនកាលគេលើកប្រគេនទៅតែម្តងក៏មាន ប្លួនកាលគេសូត្របាឡីវេរផង រូបហើយលើកប្រគេនទៅក៏មាន កូនប្រុសស្រី ត្រូវចូលទៅប្រគេនដោយខ្លួនឯងម្នាក់ ១ ត្រៃ សល់អំពីនោះត្រូវមាតាបិតាឬពួកញាតិប្រគេនតទៅ ។ កាលគេប្រគេនរូបហើយ ព្រះសង្ឃត្រូវសូត្រធម៌អនុមោទនាទានតាមសមគួរ ។

ស្រេចកិច្ចនោះហើយ ត្រូវរៀបអាហារលៀងភ្ញៀវ កូនប្រុសត្រូវបំរើភ្ញៀវប្រុស កូនស្រីត្រូវបំរើភ្ញៀវស្រី ចាំថែមថយរបស់ដែលខ្វះខាត ។ ពួកភ្ញៀវកាលពីសារូបហើយ អ្នកណាដែលមិនទាន់បានចងដៃបញ្ជាប់ព្រលឹងដោយរបស់ទ្រព្យពីវេលាមុន ក៏ត្រូវយកមកបញ្ជាប់ព្រលឹងក្នុងវេលានេះ ។

វេលាល្ងាចក្នុងថ្ងៃនោះរវាងម៉ោង ២ ទៅម៉ោង ៣ ប្លួនកាលអ្នកខ្លះ គេមានការនិមន្តព្រះសង្ឃ ១ រូបមកសំដែងធម៌

ទេសនា ១ កណ្ឌទៀតផង ។ ព្រះសង្ឃអ្នកសំដែងត្រូវជ្រើសរើសយកធម៌ណាដែលជាអនុរូបដល់កិច្ចនោះ តាមរបៀបដែលលោកធ្លាប់ទេសនាមកហើយ លោកជ្រើសសំដែងអំពីកិច្ចដែលមាតាបិតាត្រូវសង្គ្រោះដល់បុត្ត-ធីតា មានប៉ុន្មានស្ថាន កិច្ចដែលបុត្ត-ធីតាត្រូវសង្គ្រោះមាតាបិតាវិញ មានប៉ុន្មានស្ថាន កិច្ចដែលស្វាមីត្រូវសង្គ្រោះដល់ភរិយា មានប៉ុន្មានស្ថាន និងកិច្ចដែលភរិយាត្រូវសង្គ្រោះដល់ស្វាមី មានប៉ុន្មានស្ថាន តាមសេចក្តីដែលមានមកក្នុងសិង្គាលោវាទសូត្រ និងសំដែងអំពីបុត្តទារសង្គហមង្គល (ការសង្គ្រោះដល់ប្រពន្ធកូន) ដែលមានមកក្នុងមង្គលសូត្រជាដើម ។ សាមីខ្លួនកូនប្រុស-ស្រី ត្រូវចេញមកស្តាប់ធម៌ទេសនានោះ ។

៩ — ពិធីជំរុំជំណោក

ដល់វេលាយប់ក្នុងវាងម៉ោង ៨ ទៅម៉ោង ៩ ត្រូវរៀបផ្សំដំណេក តែតាមបែបនេះគ្មានការសែនជំរាបជូនតាទេ មានតែការបញ្ចុកទឹកដូង បញ្ចុកបេកទុំ និងផ្លែព្រៃដោយផ្សេង ៗ ហើយ

ប្រាប់ឲ្យកូនប្រុសស្រីដេកទន្ទឹមគ្នា គឺប្រុសដេកខាងស្ដាំ ស្រីដេកខាងឆ្វេង ហើយថយចេញមកវិញ ។

ការរៀបជូនកូនប្រុស-ស្រីទៅសុំពរអំពីគ្រូអាចារ្យឯវត្តក្ដី ការទៅប្ដឹងមន្ត្រីអត្រានុកូលដ្ឋានឲ្យចុះបញ្ជីអាពាហ៍ពិពាហ៍ក្ដី រមែងមានតាមទំនៀម ។៚

# បញ្ជីរឿង

ទំព័រ


១ — ខេមរខេមសរណកថា លទ្ធិឥសលាម ព្រះមហាពិទូរក្រសេម រៀបរៀង (ត). ១២១

២ — លោកន័យ ពាក្យកាព្យ . . . . . . . . . . . . . . . . . . . . ១៣៣

៣ — សុភាសិត ប្រកបនិទាន . . . . . . . . . . . . . . . . . . . . ១៥៣


# រូបក្រៅរឿង


១ — រូបភាពក្រុងជាគន (ភូមា) . . . . . . . . . . . . . . . . . . . . ១១៩

២ — រូបភាពវត្តអានន្ទ នៅក្រុងជាគន . . . . . . . . . . . . . . . . . . ១៣១

# TABLE DES MATIÈRES


| | Pages |
|---|---|
| I. Khema-Khema Saranakatha ou Religions, refuge des hommes | 121 |
| II. Lokaneya | 133 |
| III. Conte cambodgien inédit: Proverbe du prix de 30 onces d'argent | 153 |


## HORS TEXTE:


| | |
|---|---|
| I. Pagode d'ananda Paya à Pagan Birmanie. On y trouve des images représentant la vie du Bouddha au complet. . | 119 |
| II. Une vue de Pagan ville aux 5.000 pagodes — Birmanie. . | 131 |



រូបភាពក្រុងបាគន ដែលគេឲ្យឈ្មោះថា «ក្រុង ៥.០០០ វត្ត»
នៅស្រុកភូមា ក្រុងនេះកាល ព.ស. ១.៥៥០ ជាទីថ្កើងណាស់ ។

ខេមាខេមសរណាកថា

# ព្រះមហាពិទូរ ក្រសេម គន្ធរបនបណ្ឌិត្យ

រៀបរៀង (គ)

លទ្ធិឥស្លាម លទ្ធិនេះឧបត្តិឡើងក្នុងប្រទេសអារ៉ាប់ ព្រះមុហាម៉ែទជាតិអារ៉ាប់កើតក្នុងត្រកូលជាន់ទាប នៅស្រុកមាកៈហ៍ កាល គ.ស. ១១១៣ តាមប្រវត្តិថា ជាមហាទូតទទួលទេវឧង្ការចុះមកប្រកាសលទ្ធិសាសនា ប្រដៅមនុស្សទាំងឡាយជំនួសព្រះធំបំផុតដ៏មាននាមថា អាលោះហ៍ សឹងស្ថិតនៅឯឋានសួគ៌ជាអាចិណ្ណ ព្រះមុហាម៉ែទជារូបសរណៈ ព្រោះមានរូបប្រាកដ ព្រះអាលោះហ៍ជាអរូបសរណៈ ព្រោះមិនប្រាកដរូប ។

កាលមុហាម៉ែទអាយុបាន ២៥ ឆ្នាំ បាននាងគឌីយាស់ស្រីមេម៉ាយជាភរិយា ជាអ្នកយកចិត្តទុកដាក់គិតអានរឿងលទ្ធិមានសេចក្ដីយល់ឃើញថា ជនជាតិអារ៉ាប់មិនគួរនឹងសំពះបូជាគោរពរូបដែលសាងឡើង តាមគតិថ្មី គឺមិនគួរនឹងសាងរូបដំណាងរបស់លោកដែលជាទីគោរពនៃខ្លួន ទុកគោរពបូជានិយាយដោយខ្លីគឺមិនត្រូវធ្វើដោយដៃខ្លួនឯងហើយសំពះខ្លួនឯងដូចយ៉ាងពុទ្ធសាសនិកជនសាងព្រះពុទ្ធរូបទុកបូជាគោរព គួររកគតិលទ្ធិដទៃដែលបរិសុទ្ធវិសេសជាងនេះដ៏មាននៅក្នុងប្រទេសអារ៉ាប់ក្នុងវេលានោះ មកជាសរណៈ ទើបចេញចាកគេហស្ថាន

ទៅរកទីវិវេក ដើម្បីសេចក្ដីស្ងប់ស្ងាត់កាយចិត្ត នឹងបានសំឡឹងមើលធម៌ដ៏ល្អបរិសុទ្ធ ខណៈដែលកំពុងតែសំភីរកធម៌ ក៏ប្រាកដឃើញជារូបទេពបតី ឈ្មោះយិបរ៉ាអិល បុះមកត្រដាងលាប្រម្ងរលិក្ខិតឲ្យមុហាម៉ទអាន តែមុហាម៉ទអានមិនបានទេពបតីក៏ត្រាស់ផ្ទួនៗថា "អានបុះៗ" មុហាម៉ទអានម្ដងទៀតក៏អានបានមួយរំពេចតាមទេពឧង្ការ ក្នុងលិក្ខិតនោះសំដែងអំពីអនន្តសក្តានុភាពនៃព្រះជាម្ចាស់អ្នកសាងសកលចក្រវាឡ និមិត្តរឿងនេះជាហេតុ ធ្វើឲ្យមុហាម៉ទករញ្ជ្រួលរោលរែកក្នុងចិត្តយ៉ាងខ្លាំង ដោយបំណងយកហេនន្ទរជាព្រះ ដ្បិតឃើញស្រមោលស្រពេចស្រពិលចូលមកជិតណាស់ហើយ តមកបាននិមិត្តមួយយ៉ាងទៀត ដែលជាទីពេញចិត្តមុហាម៉ទយ៉ាងបំផុត គឺទេពបតីយិបរ៉ាអិលត្រាស់ថា "មុហាម៉ទចូរក្រោកឡើង, ចូរត្រៀបទៅប្រដៅលទ្ធិធម៌ ប្រកាសកិត្តិគុណរបស់ព្រះម្ចាស់សួគ៌បុះ" ព្រះមុហាម៉ទក៏អស់សង្ស័យ សំគាល់ក្នុងចិត្តថា ព្រះជាម្ចាស់សួគ៌ទ្រង់ជ្រើសរើសខ្លួនឲ្យជានៈបីនៃមនុស្សជាតិ ដើម្បីនឹងផ្សាយទិព្យលិក្ខិតតាមទេពឧង្ការដល់មនុស្សទិករ,

ទិព្យលិក្ខិតនោះមានសេចក្ដីប្រដៅឲ្យប្រជាជនលះលែងបូជារូបគោរពយ៉ាងគតិថ្មីចេញ ឲ្យបេះបូជាព្រះជាម្ចាស់ដែលពិតដ៏ជាលទ្ធិបុរាណនោះវិញ លទ្ធិនេះហៅដោយឈ្មោះ "ឥសល៉ាម" ប្រែថា ព្យាយាមដើម្បីដល់ព្រះអាលោះហ៍ កាលមុហាម័ទប្រកាសលទ្ធិធម៌ដល់មនុស្សនិករក្នុងប្រទេសអារ៉ាប គ្រានោះទំរាំតែផ្តួលឲ្យលើកលែងរាប់អានគតិបូជារូបគោរព ដែលមហាជនធ្លាប់រាប់អានមកអំពីដើមបាន ក៏តោងប្រទះនឹងការបំរូងបំរាសទទឹងមុខស្អកស្អាញយ៉ាងខ្លាំង ទាល់តែទ្រាំនៅស្រុកមិនបាន តោងភៀសខ្លួនចេញចាកស្រុកមាក:ហ៍ ត្រណាត់ត្រណែងទៅពឹងពួនលាក់ខ្លួនក្នុងដែនដងព្រៃរហូតវេលាជាច្រើនឆ្នាំ, ជាសំណាងរបស់គាត់ វេលាក្រោយបានត្រឡប់ចូលស្រុកវិញក៏បានជាក្សត្រិយ៍សោយរាជ្យមានអំណាចលើស្រុកមាក:ហ៍ បានសំដែងអធ្យាស្រ័យជាអ្នកមានចិត្តទូលាយអើពើនឹងអ្នកទាំងពួង លះបង់នូវសេចក្ដីព្យាបាទបានដោយពើកទោសឲ្យសត្រូវ លទ្ធិឥសល៉ាមដែលនឹងផ្សាយទៅបាន ក៏ដោយអាស្រ័យព្រះមុហាម័ទទ្រង់នៅអំណាចពេញទី ដោយធ្វើសង្គ្រាមក្របែល

ពួកសត្រូវខ្លះឲ្យលំទៅជាច្រើនលើក នឹងវាយយកប្រទេសដទៃ ៗ មកជាស្រុកចំណុះទៀត ហើយបង្គាប់ឲ្យកាន់សាសនារបស់ខ្លួន អ្នកស្រុកដែលពាលហាញ់ ក៏តោងញ៉មចុះចូលរាប់អានលទ្ធិឥសលា៉ម ។

តមកលទ្ធិនេះក៏បែកញែកគ្នាជាច្រើននិកាយ ទាំងអស់ ៧៣ និកាយ ដោយហេតុផ្តើមអំណាចគ្នាខ្លះ ដោយមានសេចក្តីឃើញខុសគ្នាខ្លះ ក្នុង ៧៣ និកាយ មាននិកាយ ១ ឈ្មោះ សុនី មានមហាជនរាប់អានក្រាស់ក្រៃនជាងនិកាយដទៃ ៗ គណៈឥសលា៉មដែលនៅក្នុងស្រុកខ្មែរក៏ប្រើនតែសុនីនិកាយ សុនី ប្រែថា អ្នកកាន់តាមគម្ពីរដើម របស់ដើមបញ្ញត្តិដូចម្តេចក៏រាប់អានប្រព្រឹត្តតាមយ៉ាងនោះ ។

តាមយោបល់នៃលទ្ធិឥសលា៉មថា អ្នកដែលរាប់អានត្រូវឲ្យមានសទ្ធាសេចក្តីជឿក្នុងព្រះអាលោះបា៍ នឹងការប្រតិបត្តិប្រកបផង តែដែលរាប់ថាជាអង្គសំខាន់ក្នុងលទ្ធិនេះ ត្រូវបណ្តុះសទ្ធាឡើងក្នុងទី ៤ ស្ថាន គឺ:

១– ជឿព្រះជាម្ចាស់ថា មានតែ ១ ព្រះអង្គ គឺ ព្រះអាឡោះហ៍ គ្មានព្រះដទៃទៀតជាពីរ ព្រះអង្គទ្រង់នូវមហានុភាពជាវិភូទេព មានព្រះបញ្ញាធិគុណ គឺ ទ្រង់នូវព្រះបញ្ញាញាណជ្រៅជ្រះសុខុមជាយ៉ាងក្រៃពេក មានព្រះទយាធិគុណ គឺជាអ្នកប្រកបដោយមហាករុណាជាយ៉ាងក្រៃពេក ជាអ្នកសាងលោកនឹងបណ្ដាធាតុវត្ថុផ្សេង ៗ ឲ្យកើតឡើង ទ្រង់ជាឥស្សរៈក្នុងលោកតែ ១ ព្រះអង្គ, ការសំដែងសទ្ធាឲ្យលើកចង្អុលដៃឡើងព្រមទាំងឧទានវាចាថា "ឡាឥឡាហា ឥលល្លាហ៍" ប្រែថា គ្មានព្រះដទៃទៀត មានតែព្រះអាឡោះហ៍ ១ អង្គប៉ុណ្ណោះ ហើយថែមខាងចុងទៀតថា "មុហោម៉ទរ៉ស៊ូលល្លាហ៍" ប្រែថា ព្រះមុហាម៉ទជាអ្នកជំនួសព្រះជាម្ចាស់

២– ជឿក្នុងទេពបរិវាររបស់ព្រះអាឡោះហ៍

៣– ជឿក្នុងគម្ពីរកុរ៉ាន (ឬហៅថា កុរអ៊ាន) ដែលព្រះបាទយិបរ៉ាអ៊ិល ទេពបតីនាំយកមកប្រទានឲ្យព្រះមុហាម៉ទជាបរិច្ឆេទ ៗ លុះព្រះមុហាម៉ទទំលាយខន្ធហើយ ពួកសិស្សសាវករួបរួមបួលពួកតាមលំដាប់មុនក្រោយ ដើមចុង ជាគម្ពីរ ១ ទុកត

មក, ក្រៅពីគម្ពីរកុរ៉ាននៅមានឱវាទផ្សេង ៗ ដែលចេញពីព្រះឱស្ឋមុហាម័ទទៀត រួមជាគម្ពីរ ១ ហៅថា កម្ពីរសុណា រាប់អានថាជាគម្ពីរត្រឹមត្រូវស័ក្តិសិទ្ធស្មើនឹងគម្ពីរកុរ៉ានដែរ (បែបយ៉ាង អដ្ឋកថាព្រះត្រៃបិដក) តែនិកាយចៅសេនបដិសេធគម្ពីរនេះមិនរាប់អានផង

៤— ជឿក្នុងអ្នកជំនួលព្រះអាឡោះហ៍ ឬនៈបី, ពួកឥស-ឡាមរាប់អានប្រោហ្វេតដ៏មានចែងក្នុងគម្ពីរប៊ីព្លើសថាជា នៈបី រាប់អានព្រះយេស៊ូជានៈបីដែរ សូម្បីព្រះសមណគោតមក៏ថាជាព្រះនៈបី, ឯព្រះមុហាម័ទពួកឥសឡាមរាប់អានថាជាមហានៈបីធំជាងនៈបីដ៏មានមកហើយទាំងអស់ ។

នៅមានឧបដិបត្តិ ៤ យ៉ាងទៀតជាសំខាន់ គឺៈ

១— ការជំរះលាងកាយ នឹងសូត្រមន្ត

២— ចាំសីល គឺក្នុង ១ ឆ្នាំមានការចាំសីល ៣០ ថ្ងៃ ត្រ-ណមសីល គឺវៀរចាកបរិភោគអាហារ - ផឹកទឹក - លេបទឹកមាត់ លាបផាត់គ្រឿងក្រអូប មេថុនធម្ម ឬប្រព្រឹត្តទៅដើម្បីរាគៈ

រហូតវេលាតាំងតែព្រះអាទិត្យឧទ័យឡើងទៅទល់នឹងអស្តង្គត គឺវៀរតែក្នុងវេលាថ្ងៃ

៣– ទាន បរិច្ចាគទ្រព្យ ឬអាហារ គ្រឿងប្រើប្រាស់ ចេញធ្វើបុណ្យ

៤– ការនមស្សការ គឺការទៅស្រុកមាកៈហ៍ ដើម្បីនមស្សការស្ថានទីដ៏ស័ក្តិសិទ្ធិ អ្នកដែលនៅឆ្ងាយៗ ដូចយ៉ាងចាម-ជ្វា នៅក្នុងប្រទេសកម្ពុជា ក៏តាំងខំឃ្លាតទៅនមស្សការទីនោះ ដោយចូលចិត្តថាជាបុណ្យកុសលមួយយ៉ាង ។

ក្នុងលទ្ធិឥស្លាម ហាមមិនឲ្យធ្វើរូបតំណាងទុកបូជាគោរពថែមទាំងណែនាំថា បើបានទំលាយរូបគោរពរបស់សាសនាដទៃចោល ដូចយ៉ាងទំលាយព្រះពុទ្ធរូប រាប់ថាជាបុណ្យកុសលយ៉ាងធំ ហេតុនោះក្នុងវិហាររបស់ពួកគេះ ទើបគ្មានរូបព្រះជាម្ចាស់របស់គេសោះ ធ្វើវិហារទុកសម្រាប់តែចូលប្រជុំសូត្រមន្តឬធ្វើពិធីឯណានីមួយ ។ លុះមកដល់ពុទ្ធសករាជ ១១៧៥ ព្រះមុហាម័ទក៏ក្ស័យជន្មាអស់សិខារ ដោយជម្ងឺគ្រុន

ពិស ប្រមូលអាយុបាន៦៣ឆ្នាំ ។ ហេតុដែលនាំលទ្ធិព្រហ្មញ្ញ លទ្ធិសាសនាព្រះពុទ្ធ លទ្ធិជេន លទ្ធិគ្រិស្ត លទ្ធិឥស្លាម មក ពោលក្នុងទីនេះ ដោយឃើញថាជាលទ្ធិធំៗ មានប្រជុំជនរាប់ អានច្រើន តែជាសរណៈក្រេមឬមិនក្រេមនោះ សូមឲ្យអ្នក កាន់សរណៈពិចារណាមើល ។



រូបភាពវត្តអានន្ទ នៅបាគន (ភូមា) សាងពី ព.ស. ១៦៣៤ ក្នុងរជ្ជកាល
ស្តេចកិយ៍ងសិទ្ធានៅទីនេះមានរូបភាពរចនារឿងពុទ្ធប្រវត្តិ មានពួកពុទ្ធបរិសទ្យមកគោរពបូជារាល់ឆ្នាំ ។

# លោកន័យ

(ច)

បុរោហិតស្តាប់ អ្នកផងប្រាយប្រាប់ ឆ្លាស់ឆ្លើយថាហៃ អ្នកអើយប្រស្នា នេះជាក្រក្រៃ ឥតអ្នកឯទៃ នឹងអាចដោះបាន ។ កុំថាតែយើង ជាមនុស្សបបើង ថ្វីជាតិសាមាន្យ(១) ទោះទាំងទេវតា នៅនាសួគ៌ឋាន សឹងឆ្លើយពុំបាន អាថ៌នេះកម្រ ។ ធម្មតាអ្នកមាន បារមីថ្កើងថ្កាន ពីព្រេងនាយម បើមានប្រស្នា គេរកកម្រ ឲ្យទៅសឹងរ ជាងាយវិញខ្វី ។ បើនឹងបិត្តា ឲ្យអាថ៌ប្រស្នា ទៅគេងាយក្តី ប្រែជាក្រលន់ ហេតុបុណ្យបារមី បានសាងអំពី មុនមកច្រើនគ្រា ។

បទពំនោល

នេះបទពំនោលក្សត្រា ស្តាប់ពាក្យព្រាហ្មណា ថ្លៃព្រោះទ្រង់ព្រះក្រោធក្រៃ ។ ថាម្នាលគ្នាយើងទីទៃ ប្រស្នានេះនែពីក្មេង ៧ ឆ្នាំគត់ ។ នឹងរកពុំយល់ប្រាកដ គ្នាយើងឥតបទកំណៅល្ងង់ឥតភ័ស្តុ(២) ។ ថាបើប្រស្នាអ្នកបាស់ សំរឹងក្រ

---

១ សំ. សាមាន្យ; ម. សាមញ្ញ "ដែលជាធម្មតា, ជាសាធារណ" ។ ២ សំ. វស្តុ > ពស្តុ, ក្លាយមកជា ភ័ស្តុ; ម. វត្ថុ ។

ណាស់ ឥតអ្នកឯណាដោះបាន ។ ពីនេះទៅមុខឲ្យខាន
តែថ្ងៃផ្សិតមាន រវល់នឹងធ្វើរាជការ ។ យប់នៅទំនេរអាសារ
គួរគិតពិហារ· ណានៃវិតក្កបញ្ហា ។ អស់មុខមន្ត្រីសេនា
ក្រួញក្រាបសិរសា ទទួលព្រះបន្ទូលថ្លៃ ។ ចាប់ដើមអំពី
សម័យ នោះវៀរតែថ្ងៃ ធ្វើការរាជការប្រក្រតី ។ លុះចូល
សន្ធិយារាត្រី ឮស្គរភេរី ហើយសឹងនាំគ្នាមកជុំ ។ លើព្រះ
រាជរោងជំនុំ រកអាថ៌សុខុម ដូចជាពិរាត្រី ។ គិតពុំយល់
អាថ៌សេចក្ដី ដូចជាប្រាំបី ថ្ងៃទើបបុរោហិតា ។ ឡើងគាល់
ព្រះបាទក្សត្រា ហើយក្រាបទូលថា បពិត្រអង្គអម្ចាស់ថ្លៃ ។
ប្រស្នានេះអាថ៌ក្រៃក្រៃ មានតែធនញ្ជ័យ កុមារអាចឆ្លើយសារ
សង ។ ធម្មតាអ្នកប្រាជ្ញសឹងលង់ នឹងប្រស្នាល្បង ដូច្នេះទើប
ដឹងគំនិត ។ ស្ដេចស្ដាប់ពាក្យបុរោហិត ថាអើគាប់ពិត នោះ
ទើបព្រះអង្គឲ្យធ្វើ ។ ព្រះបន្ទូលទើបត្រាស់ប្រើ បង្គាប់ទៅលើ
អមាត្យជំនិតក្សត្រា ។ ឲ្យនាំព្រះរាជអាជ្ញា ចេញទៅដល់
មហា· សេដ្ឋីធនញ្ជ័យឲ្យយក ។ អស់ក្មេង ៥ រយចូលមក
ហើយត្រាស់ឲ្យយក ធនញ្ជ័យកុមារមកផង ។ អមាត្យក្រួញ

ក្រាបរាប់រង បង្គំបីដង ទទួលព្រះបន្ទូលថ្លៃ ។ ក្រាបលាចេញទៅរៃៗ ដល់ស្រុកធនញ្ជ័យ សេដ្ឋីក៏ឈប់នៅក្រៅ ។ ប្រើតែកូនក្មួយចូលទៅ ប្រាយប្រាប់ដោយនូវ ដំណើរតាំព្រះអាជ្ញា ។ សេដ្ឋីស្តាប់ហើយម្ទីម្នា យកតោកមៀនហ្វា តាំងយូបិទមាសកំពូល ។ ចេញទៅទទួលព្រះបន្ទូល ហើយតាំបរបួល មកដល់សាលាជំនុំ ។ សេដ្ឋីក្រាបថ្វាយបង្គំ បីដង ហើយសុំ បើកមើលដឹងសព្វសេចក្ដី ។ ស្រេចទើបធនញ្ជ័យសេដ្ឋី ឲ្យហៅពោធិ- សត្វនូវអស់ក្មេងមកប្រាប់ ។ ថាដ្បិតទ្រង់ព្រះបង្គាប់ មកជាប្រញាប់ ឲ្យយកឯងចូលទៅ ។ ព្រះពោធិសត្វបមពៅ ឆ្លើយថាខ្ញុំទៅ តាមដូចព្រះរាជអាជ្ញា ។ គឺមោះវង់រកប្រស្នា ការគួរសមជា ជង្វាយថ្វាយមហាក្សត្រក្សាន្ត ។ ថ្ងៃនេះឈប់ស្លេះបង្ហាន ព្រឹកស្អែកទើបបាន ទៅថ្វាយបង្គំក្សត្រា ។ អមាត្យវិលវឹងម្ទីម្នា ចូលទូលក្សត្រា តាមដូចពាក្យចៅធនញ្ជ័យ ស្ដេចស្ដាប់ជ្រាបហើយក្សត្រថ្លៃ បន្ទូលថាហៃ អស់មុខមន្ត្រីយោធា ។ នូវអស់ព្រាហ្មណ៍ព្រឹទ្ធហោរា ស្អែកបួរនាំគ្នា មកជុំលើរាជរោងរ័ត្ន ។ កាលក្រោយអាជ្ញា

ទៅហ៊ុត់ ទើបពោធិសត្វ ឲ្យប្រាមប្រាប់អស់សេដ្ឋី ។ ឲ្យរក ដង្វាយបក្រី លុះព្រឹកឡើងថ្មី ទើបអស់សេដ្ឋីទាំងឡាយ ។ អ្នកខ្លះយកត្បូងពិទាយ ពិទូរ្យរត្នរាយ ខ្លះយកមុក្តាផ្លេក រត្ន[១] ។ ខ្លះយកឥន្ទនិលមរកដ ខ្លះយកបុស្សរត្ន បទុមរាគ ពេជ្ររត្នថ្លៃ ។ សឹងត្បូងរត្នមានដំឡៃ ប្រឹងប្រៀបដោយដៃ គួរជាដង្វាយក្សត្រា ។ កាលនោះទើបធនញ្ជ័យមហា- សេដ្ឋី បវរា ដណ្ដឹងព្រះពង្សពោធិ ។ ថាហៃកូនស្ងួនពិសី យើង យកទ្រព្យអ្វី គួរជាដង្វាយក្សត្រា ។ ពោធិសត្វឆ្លើយរឹងឋា បពិត្របិតា ប្ដូរអ្នកយកកែវមណីជោតិ៍ ។ មួយនោះធំប៉ុនផ្លែ ត្នោត ជាដង្វាយសោត សមគួរជាបណ្ណាការ ។ សេដ្ឋីស្ដាប់ ពាក្យកុមារ ប្លូលបិត្តត្រអាល ឲ្យយកកែវមណីជោតិ៍ថ្លៃ ។ ដំកល់លើពានមាសមៃ ទើបចៅធនញ្ជ័យ ឯងឲ្យដំណឹងបិតា ។ នាំអស់សេដ្ឋីទាំងឋា- រយរៀបយាត្រា ទៅដល់ព្រះរាជរោង រម្យ ។ ឱនអង្គក្រាបថ្វាយបង្គំ មហាក្សត្រឧត្ដម ហើយថ្វាយ ដង្វាយដោយគួរ ។ ស្ដេចយល់ហើយទ្រង់ព្រះស្រួល បើក

---

១ ម. ផលិក ។

បន្ទូលសួរ ថាហែមហាសេដ្ឋី ។ ឯណាកូនប្រុសពិសី នៅចាំ
រង់អ្វី ឥឡូវកាលណានឹងមក ។ សេដ្ឋីស្តាប់ស្តេចសួររក ទូល
ថាខ្ញុំយក មកតាមជាក្រោយខ្ញុំហ្វាត់ ។ កាលនោះឯពោធិសត្វ
មហាបុរសរ័ត្ន នូវក្មេងទាំង ៤ រយផង ។ សឹងស្លៀកសសុទ្ធ
ឥតហ្មង ស្តាយឈៀងសផង ហើយកាន់ប្រទីបមាសមៃ ។
មានជងគ្រាន់គ្រប់នៅដៃ សព្វគ្រូទីទៃ ទើបចូលទៅគាល់
ក្សត្រា ។ រូបរៀបប្រទីបសុវណ្ណា អុចថ្វាយរាជា ស្រេចហើយ
ទើបថ្វាយបង្គំ ។ អង្គុយកណ្តាលជំនុំ ឥតភ្លឹកបារម្ភ បីដូច
កេសររាជសីហ៍ ។ ឯអស់ព្រាហ្មណ៍ត្រិទូមន្ត្រី យល់រូបពោធិ-
សត្វសឹងមានចិត្តស្ញែងស្ញប់ ។ ព្រះបាទធនញ្ជ័យកោរព្យ
រាជយល់ហើយសព្វ- ព្រះទ័យត្រេកសោមនស្សា ។ មានព្រះ
បន្ទូលត្រាស់ថា ធនញ្ជ័យអើយបា បាអុចប្រទីបហេតុអ្វី ។
កាលនោះព្រះពង្សពោធិ លើកអញ្ជលី ប្រណម្យហើយទើប
ទូលថា ។ បពិត្រខ្ញុំព្រះករុណា អុចប្រទីបជា បណ្ណាការ
ថ្វាយបក្រី ។ កាលណោះអស់មុខមន្ត្រី សឹងសើចពោធិ-
សត្វកងរំពងអឹងអាប់ ។ ថាចៅធនញ្ជ័យឥតស័ព្ទ ឥត

សារពុំគាប់ ស្រដីពុំគួរពេកក្រៃ ។ ទើបស្តេចបន្ទូលថាហៃ
នែចៅធនញ្ជ័យ ចៅអ្នកប្រទីបនេះថ្វាយ ។ ដោយមាន
អត្ថាធិប្បាយ ម្តេចប្ដូរនិយាយ ប្រាប់អញឲ្យបានដឹងរ៉ា ។
ទើបពោធិសត្វទូលថា បពិត្ររាជា កំពូលឥស្សរថ្លាថ្លៃ ។
ពន្លឺប្រទីបនេះនៃ គឺភ្លើងវិស័យ អាចឲ្យគុណច្រើនប្រការ ។
ទោះនូវបំអិនអាហារ ត្រីសាច់សព្វសា- រពើដាំទឹកក្តីណា ។
ទោះនូវបន្លោរងា ទោះនូវអុជជា ពន្លឺនោះសឹងជាហោង ។
សឹងអាចសម្រេចកិច្ចផង អំបាលនេះហោង មួយនីវឹង
អណ្តាត ។ ប្រទីបនេះកិច្ចជាអាទ៍ ហេតុនោះអមាត្យ មន្ត្រី
ផងសើចមើលងាយ ។ ទោះឲ្យគុណគេសម្លាយ អ្នកផង
ទាំងឡាយ មើលងាយផ្សិតតូចតិចក្រៃ ។ ហេតុឥតពំនាក់
អាស្រ័យ ឥតអ្នកដទៃ ស្រករកំដរជាគ្នា ។ មហារាជខ្ញុំនឹង
ឧបមា អ្នកមានប្រាជ្ញា មានយសសន្ធានថ្លៃក្តី ។ បើខ្សត់
ហើយសឹងអប្រិយ៍ ដូចកល់អគ្គី អ្នកផងមើលងាយដូច្នេះ ។
មហារាជរីភ្លើងតូចនេះ ថាបើនឹងឆេះ ផ្ទះផ្លាញអស់ទ្រព្យ
អន្តរាយ ។ ទោះបីនៅព្រៃហោនឆ្ងាយ អ្នកផងទាំងឡាយ

សឹងខ្លាចអំណាចបេស្តា ។ នេះដូចអ្នកមានប្រាជ្ញា ហើយមានសក្តា មានទ្រព្យសម្បត្តិច្រើនក្រៃ ។ ទើបអស់អ្នកផងដទៃ កោតខ្លាចសព្វថ្ងៃ ឧបមាបីដូច្នោះហោង ។ មួយទីរឹងភ្លើងផង ច្រើនតិចក្តីហោង ឥតឧសសម្រាប់ខ្យល់ផាត់ ។ ឥតមានមនុស្សផ្លុំបង្កាត់ សឹងរលត់បាត់ ពុំឃើញរស្មីឡើយហោង ។ គួរនាដូចកល់អ្នកផង ខ្វះមានក្តីហោង ឥតយសមានយសសក្តា ។ បើឥតទ្រព្យធនឥតគ្នា ឥតវេលាផា កំឡាំងឡើយសឹងសូន្យបាត់ ។ ឧបមាដូចអគ្គីថ្លាត់ ទើបពោធិសត្វ សំដែងសូត្រជាគាថា ៖

តេជសាអសហា- យោសមត្ថា- បិកិករិស្សតិ ។
និវាជលអគ្គិ និវោធតិ សយំឯវិជនា ។

អធិប្បាយបន្ថែថា អ្នកមានបេស្តា ឥតមិត្រសំឡាញ់ពេល ។ ដូចភ្លើងឆេះឡើងឥតខ្យល់ នឹងអាប់ពុំឃើញរស្មីអណ្តាតភ្លើងឡើយ ។ ទោះនៅគ្រងញាតិជាត្រើយ មិត្រសំឡាញ់ហើយ សឹងតែអាស្រ័យសម្បត្តិ ។ ទើបបួលចិត្តមូលពុំខ្វាត់ ហើយពោធិសត្វ អ្នកសូត្រជាគាថាទ្វេ ៖

ធនាហីនបជ្ជេ  មិត្តោបុត្តេ ទារសហោទរា ។

លោកេមហាសខា  វត្តំអត្ថា  តមត្ថសេវន្តិ ។

អធិប្បាយបទបាឡី ថាប្រិពន្ធបុំ កូនចៅញាតិមិត្រក្តី ណា ។ សឹងស្អប់អ្នកឥតទ្រព្យ បិត្តបង់ស្នេហា នឹងអ្នកមានទ្រព្យសម្បត្តិ ។ នាក្នុងលោកិយនេះឋាត់ មានតែសម្បត្តិជាមិត្រសំឡាញ់អ្នកផង ។ មួយសោតបើប្រាជ្ញាបង់ យសស័ក្តិក្តីហោង បើឥតសម្បត្តិជាត្រើយ ។ ប្រាជ្ញាពុំបរិបូណ៌ឡើយ បើបានយសហើយ ពុំមានសុខក្នុងចិត្ត ។ មិនតែលោកិយឡើយណា ទោះនឹងប្រាជ្ញា ប្រាជ្ញាសារពេជ្រតាញាណ ។ បើឥតទ្រព្យនឹងឲ្យទាន សឹងតែពុំបាន ដូចក្តីប្រាជ្ញានោះនែ ។ ស្តេចស្តាប់ចូលព្រះហឫទ័យ សោមនស្សក្រៃ ឲ្យសាធុការមហិមា ។ យតមត្ថំសេត្ថា សត្វារីអាចឯណានោះសោតពុំច្បាស់ ។ លុះព្រះអង្គស្តេចបានត្រាស់ ជាសម្តុន្ធ័ស្ស ទើបស្តេចទេស្នាប្រាប់ប្រាយ ។ ថាហៃភិក្ខុផងទាំងឡាយ ស័ត្វនោះឮសាយ ទូទាំងផ្ទៃរោងរាជា ។ លំដាប់នោះទើបក្សត្រា បន្ទូលត្រាស់ថា ហៃចៅធនញ្ជ័យកុមារ ។

អញទុកចៅជាអាចារ្យ ចូលចៅឆ្លើយអាថ៌ សេចក្ដីវិតក្កបញ្ហា ។ ទើបពោធិសត្វទូលថា បពិត្រក្សត្រា កុំស្ដេចបន្ទូលប្រើខ្ញុំ ។ សូមត្រាស់ប្រើលោកចាស់ទុំ អ្នកប្រាជ្ញបុរម- បូរាណគឺបុរោហិត ។ ដ្បិតខ្ញុំនៅក្មេងពេកក្ដាត់ ទឹកដោះនៅមាត់ ពុំគួរនឹងឆ្លើយប្រស្នា ។ ទើបពុទ្ធព្រាហ្មណ៍ឆ្លើយថា យើងចាស់ពិតណា គឺមោះយើងខ្លៅឆ្ងាយឆ្ងល់ ។ យើងគិតហើយយើងពុំយល់ ចៅក្មេងយោបល់ ប្រាជ្ញាចៅឈ្លាសវាងវៃ ។ យើងទន្ទឹងចៅសព្វថ្ងៃ ចង់ដឹងអាថ៌នៃ បំឡើយចៅឆ្លើយប្រស្នា ។ ព្រះពោធិសត្វថ្លៃថ្លា ស្ដាប់ហើយទូលថា បពិត្រសម្ដេចភូមី ។ ខ្ញុំនឹងសំដែងអាថ៌វិ- តក្កបញ្ហានី តទៅតាមព្រះអាជ្ញា ។ រីឯវិតក្កបញ្ហា នេះគឺធម្មា ពីពុទ្ធឱស្ឋប្រពៃ ។ ហានខ្ញុំអង្គុយនេះនៃ យល់ទាបពេកក្រៃ ពុំគួរនឹងព្រះធម្មា ។ ទើបស្ដេចឲ្យក្រាលអាសនា ទែនទិព្វក្រឡា- ទីតាំងក្រោមស្វេតឆត្រ ។ អញ្ជើញពង្សពោធិសត្វ ឲ្យឡើងគង់ហ្វាត់ លើគ្រែទែនទិព្វបញ្ចង់ ។ ព្រះពោធិសត្វឡើងគង់ ស្រេចទើបព្រះអង្គ ក្រាបទូលព្រះបាទក្សត្រា ។ បពិត្រវិតក្កបញ្ហា ទាំងបួននេះណា មានអាថ៌

កំបាំងជ្រាលជ្រៅ ។ ១ នោះគឺអាបិរណ្តៅ ១ ផ្លែរពៅ ១ គឺស្រី មានគភ៌ណា ។ ១ នោះគឺពុកបង្កា សូមទានក្សត្រា ព្រះអង្គ ទ្រង់ព្រះសណ្ដាប់ ។ ខ្ញុំនៅសំដែងប្រាយប្រាប់ អញ្ជើញស្តេច ស្តាប់ ឲ្យជ្រាបក្នុងព្រះបិន្ត ។ រឺអាបិកំបាំងបញ្ហា ទោះភូមិ ឯណា មួយគេជីកជារណ្ដៅ ។ ហើយបារដីឡើងទុកនៅ យកសសរទៅ បញ្ឈរក្នុងរណ្ដៅនោះ ។ យកដីនោះឯងលុប បុះ យកឈើស្រិបុស ឲ្យណែនប្រែជាមិនពេញ ។ លុះ យកដីឯទៀតវិញ ដាក់បុះបំពេញ នោះទើបពេញណែនពេក ក្រៃ ។ លើសនឹងពីដើមនោះនៃ បពិត្រក្សត្រថ្លៃ នេះហោង ដូចនាយកពល ។ មានទាំង ៧ ដំកល់ មានរាជការដល់ សេនាបតីមកបែក ។ សត្តគុម្ព ១ បំណែក ជាពីរបំបែក ហើយទើបសេនាបតី ។ ដំកល់សត្តនាយកខ្មី គ្រប់គុម្ពះគឺ ជាទ្វេសត្តនាយកនោះ ។ ប្អូនដណ្ដាប់ដំពូកស្មោះ ដោយនៅ កិច្ចនោះ កើតនាយកពលទាំងឡាយ ។ យល់ហាក់ច្រើនសាយ អំពាយ គឺមោះកើតក្លាយ ប្រែរិលជាតិចវិញនៃ ។ មានតែ ចាប់ស្រុកដទៃ មកហ៊ាយក្សត្រថ្លៃ បំពេញនគរទើបពេញ ។

ដូចកាលអំពីដើមវិញ ភូមិរាបនោះមិញ ឧបមាដូចរាជធានី ។ រណ្តៅដូចខែត្របុរី នាអ្នកជីកដី នោះសោតគួរនាដូចកល់ ។ សេនាបតីបែកពល ផ្ទុកដីសោតសល់ ដូចពលជំពូកដោយមុខ ។ សសរនោះដូចនាយក នាស្រីបុះបុក បីដូចព្រះរាជអាជ្ញា ។ បៀតបៀនអស់រាស្ត្រប្រជា នគរឯណា មួយបើច្រើនមានអ្នកធំ ។ ពុំគិតបុះបូលជំនុំ ដោយនៅក្រិត្យក្រម គន្លងនៃព្រះមហាក្សត្រ ។ នគរនោះសឹងសូន្យបាត់ ទើបពោធិសត្វសំដែងជាបទគាថាៈ

នេត្តារោពហុលា យត្ថទេសា បណ្ឌិតមានិតំ ។
សព្វេមហន្តត្តំ មិប្បេន្តិកតំ តេសំវិនស្សន្តិ ។

អធិប្បាយបទបាឡី បាយបែងសេចក្តី ថាប្រទេសឯណា ។ មួយច្រើនស្តេចច្រើនអាជ្ញា ដណ្តើមបង្ជា ធំហើយនឹងវិនាសពិត ។ ដូចកល់មានព្រះអាទិត្យ ទាំង ៧ រើត យើងផងវិនាសសោះសា ។ កំបាំងវិតក្កបញ្ញា គឺអាបិប្រស្នា រណ្តៅអំបាលនេះហោង ។ បពិត្រក្សត្រថ្លៃថ្លាស់ប្លង់ រពៅមានទង ប៉ុនខ្សែគោធំទេណា ។ មានផ្លែធំក្រៃមហិមា

អាស្រ័យទងវា មិនដាប់ខ្ជាប់ក្រៃកន្លង ។ ១ នីទោះបីដាប់ទង រីផ្លែផ្កាផង សឹងស្ងួតវិនាសសោះសា ។ រីផ្លែរពៅនោះណា នឹងឧបមា ដូចព្រះនគរក្សត្រថ្លៃ ។ សំបករពៅនោះនែ បីដូច វៃត្រផ្ទៃ- ក្រោមគ្រាប់រពៅដូចមាស ។ សាច់សោតដូចឈ្មួញ ទាំងផ្លាស សម្បុរដូចមាស គឺស្រីព្រះស្នំបំហុត ។ ស្លឹកត្រើយ ដូចព្រះរាជបុត្រ ទេពីប្រាកដ ផ្កានោះដូចព្រាហ្មណ៍ស្រមណ៍ ផង ។ រីទងរពៅនោះហោង ដូចក្សត្រច្បាស់ច្បង ពំនាក់នែ រាស្ត្រប្រជា ។ បើឥតនឹងស្តេចហើយណា រីអស់ប្រជា រាស្ត្រនូវ យោធាទាំងឡាយ សឹងតែវិនាសខ្ចាត់ខ្ចាយ ទ្រព្យធនអន្តរាយ ហេតុឥតស្តេចជាប្រធាន ។ នេះហោងឲ្យរកអ្នកមាន គុណ ទាំង ៥ បាន នោះទើបឲ្យនៅអាស្រ័យ រីអ្នកទាំង ៤ នោះនែ ពោធិសត្វថ្លៃ ស្ងូត្រជាគាថាឧត្តមោ :

ធនំសោត្ថិរញ្ញោ នទីវេជ្ជោ នត្ថិនសេវតិ ។

បន្ទែប្រែជាសេចក្តី ១ គឺសេដ្ឋី អ្នកមានសម្បត្តិទាំង ឡាយ ។ ១ គឺស្រមណ៍ព្រាហ្មណ៍សម្លាយ ហោរាប្រាជ្ញ ប្រាយ នូវបណ្ឌិតផងឯងនែ ។ មួយគឺព្រះមហាក្សត្រថ្លៃ

ប្រសើរគ្រងផ្ទៃ· ក្រោមក្រមរម្យរាជសីមា ។ មួយគឺស្ទឹងបឹងគង្គា មួយគឺពេទ្យា ប្រទេសឯណាមួយនៃ ។ បើគ្មានកុំឲ្យអាស្រ័យ នៅដល់១ថ្ងៃ ឲ្យរកប្រទេសទៀតនៅ ។ បពិត្រក្សត្រថ្លៃចមចៅ អាបិផ្ទៃរពៅ សូរេចអស់អាបិអភិ·ប្រាយ ។ មហារាជរីស្រីទាំងឡាយ សឹងតែហូបបាយអង្ករកន្លះនាឡី ១ ថ្ងៃ ។ កាលបើមានគ៌ភពេញផ្ទៃ រីឯបរិ·ភោគក្រៃ ឯគ៌ភនោះនឹងឧបមា ។ ដូចព្រះរាជឃ្លាំងក្សត្រាអាហារភោក្តា នោះដូចសួយរែសព្វថ្ងៃ ។ នាគ៌ភបំរើនក្នុងផ្ទៃ គឺលើកសួយរៃ ពុំតាមគន្លងបូរាណ ។ បើនឹងលើកសួយបង់បាន រាស្ត្រផងសព្វហ៊ាន នោះនឹងវិនាសសូន្យសោះ ។ ខ្ញុំពុំស្រដីទេនោះ មានធម៌បំពោះ ទូន្មានជាបទគាថា :

ជនស្សេរធុរា ន សេវិតា អធុរាធុរានិ
កស្សជនឥត្ថិ អធុរានិ បុរេហិនត្ថា

បន្ទែថាអ្នកឯណា បង់ក្តីវាចា គឺសួយរៃពីមុនមិញ ។ មកកាន់ក្តីឯទៀតវិញ បង់បានបំណិញ យកច្រើនក្រៃលែង

នឹងច្បាប់ ។ មួយនីវក្តីពុំគាប់ គិតវិលក្រឡាប់ ជាមានប្រ-
យោជន៍សោតសល់ ។ វក្តីមានប្រយោជន៍យល់ ដោយនូវ
យោបល់ ជាឥតប្រយោជន៍អាសារ ។ វក្តីទាំងពីរប្រការ បើមិន
ពិចារ- ណានឹងវិនាសសោះសា ។ ហេតុនោះអ្នកមានប្រាជ្ញា
ឲ្យពិចារណា ក្តីពីរនេះឲ្យអស់អាថ៌ ។ ប្រស្នាតែស្រីមានគ័ភ៌
អញខ្ញុំស្រាយសារ សូរេចអម្បាលនេះណា ។ ហនុលោមា
បញ្ហា គឺពុកបង្កា ៈគកោរគេឯកសព្វថ្ងៃ ។ វាជុះឡើងធាប់ពេក
ក្រៃ ពុំបាលឡើយនៃ វពោមបំពៀមនោះហោង ។ គេពុំដែល
ដកដល់ម្តង ពុំជុះវលង វែងលើសនឹងខ្នាតឡើយណា ។ ពោម
បំពៀមនោះឧបមា ដូចរាជអមច្ចា បំរើគាប់ព្រះហឫទ័យ ។
ជាខ្ញុំពីមុនមកនៃ មានអធ្យាស្រ័យ ទំនុកបម្រុងក្សត្រា ។
ហើយពុំដែលធ្វើឆន្ទា ភយាទោសា បៀតបៀនតែទ្រព្យអ្នក
ផង ។ វពុកបង្កានោះហោង ដូចក៏អ្នកផង ទើបចូលបំរើជាថ្មី ។
នោះត្រាស់ប្រើធ្វើអ្វី ៗ សឹងលើសអំពី បង្គាប់ហើយបៀតនិត្យា។
បង់បានទ្រព្យអ្នកនានា លោភលន់មហិមា ដូចពុកបង្កាជុះ
ធាប់ ។ មួយនីស្រដីឯច្បាប់ ឯអាមាត្យគាប់ នឹងក្សត្រិឥសូរ

សិរសា ។ ឲ្យផ្គាប់ដោយហេតុប្រាំប្រា ការកល ១ ណា គឺឲ្យ សុភាពពិតត្រង់ ។ មួយគឺឲ្យរិះគិតផ្ចង់ ចិត្តតាមបំណង់ ព្រះ រាជហឫទ័យក្សត្រា ។ មួយឲ្យមានពាក្យសត្យា មួយឲ្យឧស្សាហ៍ បំរើកុំខ្ជិលអៀនប្រៀន ។ មួយឲ្យសំដែងរបៀន សិល្ប សាស្ត្រដែលរៀន សារពើបំណោះអ្វីៗ ។ មួយសោតធម៌លោក ស្រដី នឹងបងមេត្រី យកចិត្តអ្នកណាលោភលន់ ។ លោក ថាឲ្យឲ្យទ្រព្យធន បើយកចិត្តអ- ន្ធពាលមានៈរឹងត្អឹង ។ ឲ្យអត់ ឲ្យឱនកុំខឹង កុំតបបើនឹង យកចិត្តនៃអ្នកចន្ទា ។ បើយកនឹង កលប្រាជ្ញា រិះគិតបរហា ឲ្យទាន់ហើយគិតកោតខ្លាច ។ បើនឹង យកចិត្តអ្នកប្រាជ្ញ នៅក្សត្រធិរាជ ឲ្យមានពាក្យពិតពុំឃ្លាត ។ ទោះនៅជឹងពុតអាមាត្យ ដឹងកាលព្រះបាទ អម្ចាស់ក្សត្រប្រើ នោះនៃ ។ បង់ដឹងពុតញាតិទីទៃ ដឹងកាលមានភ័យ អំពើអំពល់ ព្រួយចិត្ត ។ ទោះនៅបង់ដឹងពុតមិត្រ សំឡាញ់ស្នេហ៍ស្និទ្ធ ដឹងកាលមានក្តីទម្ងន់ ។ ទោះបង់ដឹងពុតប្រពន្ធ កាលឥតទ្រព្យ ធន ប្តីសល់លែងសម្បត្តិនោះនៃ ។ មួយសោតព្រះធម៌ថាថ្លៃ ថាបើហាលថ្ងៃ ប្រើប្រែខ្លួនឲ្យព្រះសូរ្យ ។ អាំងភ្លើងឲ្យប្រែផ្ទៃចូល

បំរើព្រះគ្រូ ណាជាម្ចាស់សិរសា ។ ប្រើមានពាក្យពិតសត្យា
ទោះនឹងប្រាថ្នា ប្រយោជន៍ទៅបរលោកនាយ ។ ឲ្យកាន់សីល
ធម៌ចែកចាយ ទានផងទាំងឡាយ វៀរអស់អំពើបាបបង់ ។
មួយសោតអ្នកណាចិត្តចង់ បំរើព្រះអង្គ ក្សត្រថ្លៃឥស្សរសិរសា ។
ដើមឡើយហាក់ព្រួយអង្គា បំណេរអនា- គតគាប់បានបុណ្យ
សោយសុខ ។ រីអ្នកខ្ជិលបង់ស្រណុក បំណេរទៅមុខ ជា
ទុក្ខនឹងព្រួយអង្គា ។ ដូចកល់រៀនសិល្បសាស្ត្រា ធម៌អាថ៌ក្ដី
ណា ដើមឡើយសង្វាតអស់អញ ។ បំណេរទៅមុខសុខវិញ
អ្នកធ្វើបាបមិញ ដើមឡើយយល់ហាក់ស្រណុក ។ អនាគត
ទៅសោយទុក្ខ នៅនានរក លំបាកពេកពន់មហិមា ។
លោមវិតក្កបញ្ហា គឺពុកចង្កា សូមបេអម្បាលនេះហោង ។

[illegible]

ស្ដេចស្ដាប់ពោធិ- សត្វឆ្លើយសារសង ប្រស្នាគួរគាប់ ដោយ
ច្បាប់ធម៌ផង ពីរោះក្នុង ព្រះអង្គសទ្ធា ។ ទ្រង់ព្រះអំណរ
ដោះគ្រឿងអម្ពរណ៍ ព្រះពស្ត្រភូសា អំពីព្រះអង្គ ស្ដេចទ្រង់បូជា

ពោធិសត្វមហា- បុរសរត្នថ្លៃ ។ ស្តេចបន្ទូលថា ធនញ្ជ័យ
អើយបា មានប្រាជ្ញាវៃ ឆ្លាស់ឆ្លើយបញ្ហា ប្រស្នានេះនៃ ពីរោះ
ពេកក្រៃ ដូចព្រះទេស្នា ។ ក្មេងឆ្នាំប្រាំពីល យើងគន់មើលពុំ
យល់ដូចជាបា មិនតែលោកិយ ទោះបីបូរា បុរាណនាយណា
ពុំដែលដូចបា ។ ទើបពោធិសត្វ ពន្លកពុទ្ធរ័តន៍ បុះបាក
អាស្នា មកថ្វាយបង្គំ ប្រណម្យក្សត្រា ហើយអ្នកក្រាបលា
វិលវឹងនាហេន ។ ឯអង្គព្រះបាទ ធនញ្ជ័យនរនាថ អធិរាជក្សត្រ
ក្សាន្ត យកអស់ទ្រព្យ បូជាប៉ុន្មាន ឲ្យនាំទៅហេន ព្រះពង្ស
ពោធិ ។ កាលនោះព្រះអង្គ អម្បូរពូជពង្ស សារពេជ្ជជិនស្រី
ទ្រង់ព្រះសទ្ធា មហិមាអស់ក្តី យកទ្រព្យអំពី មហាក្សត្រិបូជា ។
រិះគិតរួសរក ផ្តួលជាងផងមក ធ្វើជាសាលា ទានមួយនៅមុខ
ទ្វារស្រុកនោះណា ក្នុងមួយទិវា ឲ្យទានបួនដង ។

ទី ៩

សុភាសិតប្រកាំបដិនាន

ថ្ងៃ ៣០ ឧម្ពុំង

## រឿងពាក្យសុភាសិតថ្លៃ ៣០ ជម្លឹង

គឺរពឹសដៃផ្ទៃផ្អែត ១ ដេកយប់កុំនិយាយនឹងស្រី ១ ឃ្លានកុំអាលស៊ី ១ ពាក្យទាំងបីម៉ាត់នេះឮតែចាស់ទុំនិយាយប្រដៅកូនចៅតៗរៀងមក ថាកាលពីដើមមានមនុស្សមួយនាក់មានប្រពន្ធនៅផងគ្នា ប៉ុន្តែយើងពុំដឹងជានៅស្រុកណា ភូមិណាៗ

ថាអ្នកនោះឮគេរៀនរបៀនពូកែចង់រៀនណាស់ យកប្រាក់ ៣០ ជម្លឹងលាប្រពន្ធដើរទៅរករៀន ដើរពីស្រុកមួយដល់ខែត្រមួយ, ឮគេថាឯណារបៀនអាគមគាថាពូកែក៏ទៅរក ដល់គ្រូណាពូកែគេសូត្រឲ្យស្តាប់ធ្វើឲ្យមើលដូចម្តេច ក៏បេះតែមិនបូលចិត្ត លុះដើរឆ្ងាយទៅក៏បានជួបនឹងតាចាស់ម្នាក់ តាចាស់សួរថាឯងទៅណាក៏ដើរមកតែម្នាក់ឯងសូះស្វែងរកអ្វី ។

អ្នកនោះឆ្លើយថា ឱតាអើយខ្ញុំមកនេះដ្បិតឮគេរៀនរបៀនពូកែ បានជាខ្ញុំខំសង្វាតមក ក្រែងតាចេះដឹងប្រដៅចៅផង តាចាស់ឆ្លើយថាតាមានរបៀន ១ យ៉ាងថ្លៃ ៣០ ជម្លឹង បើអ្នកឯណាកាន់ជាប់ អ្នកនោះមិនដែលបង្យុតគង់បានដូចចិត្ត បើគិត

ដំណើរអ្វី ៗ ដោយរបៀនតានេះពូកែណាស់ អ្នកនោះថាតាសូត្រឱ្យខ្ញុំស្តាប់មើល បើខ្ញុំចូលចិត្តខ្ញុំយក តានោះសូត្រឱ្យស្តាប់ដូច្នេះ រពឹសដៃផ្ទៃផ្អែត, ដេកយប់កុំនិយាយនឹងស្រី, ឃ្លានកុំអាលសុំ, អ្នកនោះស្តាប់ហើយចូលចិត្ត ប្រគល់ប្រាក់ ៣០ ដម្លឹង ឱ្យទៅតាចាស់នេះ ហើយទន្ទេញរបៀនទាំងបីម៉ាត់នោះ ឯតាចាស់ឆ្លើយថា បើចៅកាន់បានរបៀនបីម៉ាត់នេះបានប្រាកដតាឱ្យ តាមិនយកថ្លៃទេ ហើយតាចាស់ប្រគល់ប្រាក់ឱ្យអ្នកនោះវិញ អ្នកនោះក្រាបលាតាចាស់នោះហើយវិលមកនគរវិញ ឯក្នុងមាត់ទន្ទេញតែពាក្យបីម៉ាត់នោះតាមផ្លូវមកពុំមានភ្លេច ។

លុះដើរឆ្ងាយបន្តិចមក ជួបនឹងសំពៅឈ្មួញមួយ អ្នកនោះក៏សុំដោយសារសំពៅនោះមកស្រុក ឯង្វៅនោះក៏គេព្រមឱ្យដោយសារ ឯអ្នកនោះចុះមកដល់នៅក្នុងសំពៅថ្ងៃណា ក៏ចេះតែទន្ទេញរបៀនបីម៉ាត់នោះ ។

ឯពាក្យរពឹសដៃផ្ទៃផ្អែតនោះ ចេះតែជួយលាងចៃទាំសំពៅជួសជុលដូចជារបស់ខ្លួន នាយសំពៅនឹកតែក្នុងចិត្តថា អ្នក

នេះតាំងតែចុះមកដោយសារសំពៅកាលណា ក៏ចេះតែធ្វើការដូចជារបស់ខ្លួន គិតហើយស្រឡាញ់ឲ្យរៀបបាយទឹក ឲ្យស៊ីតែរាល់ថ្ងៃរៀងមក ។

ឯអ្នកនោះក៏ពុំចេះខ្ជិល ចេះតែធ្វើការក្នុងសំពៅដូចជាកូនឈ្នួលឯទៀត ឯនាយសំពៅក៏នឹកតែក្នុងចិត្តថា បើកាលណាបានដល់ស្រុក នឹងចែករបស់ទ្រព្យឲ្យទៅនោះរកស៊ីតទៅ ។

លុះបើកសំពៅមកដល់កណ្ដាលស្រុកគេហើយ ក៏ឃើញព្រះវិហារចិនមួយ គេរៀបរណ្ដាប់ពោរពាសសុទ្ធតែបំណាំស្រាទុកគ្រាន់តែឲ្យយក្សភិមកស៊ី ។

ឯអ្នកសំពៅកាលដល់ព្រះវិហារនោះហើយ ចតឡើងទៅលេងឃើញប្រដាប់អស់បំណាំនោះហើយ ពុំមានមនុស្សក៏នាំគ្នាស៊ីផឹកស្រាស្រវឹង ដេកនៅក្នុងព្រះវិហារនោះទាំងអស់គ្នា នៅខានតែមួយនាក់នោះឯង មាត់ចេះតែទន្ទេញថា រពឹសដៃថ្លៃឆ្អែត, ដេកយប់កុំនិយាយនឹងស្រី, ឃ្លានកុំអាលស៊ី, គិតថាឥឡូវនេះបំណាំអស់នេះមានយ៉ាង បានជាគេរៀបទុកនៅនេះ ឥឡូវនេះអ្នក

ទាំងអស់នេះស៊ី គង់តែមានបើមិនខាន គិតហើយពុំហ៊ានស៊ីឡើងទៅនៅពួនលើធ្នឹមព្រះវិហារសំងាត់លបមើល ។

លុះដល់ថ្ងៃត្រង់យក្ខមកដល់ហើយខឹងណាស់ គិតថានរណាក៏ហ៊ានមកស៊ីបំណើអស់នេះ គេរៀបទុកឲ្យតែអញស៊ីផ្លូវនេះវាស៊ីហើយវាដេកនៅនេះ យក្ខគិតបោះដំបងទៅវាយឲ្យស្លាប់អស់មនុស្សដែលដេកទាំងអស់នោះទៅ ឯដំបងក៏វិលមកនៅខាងយក្ខវិញ ហើយយក្ខក៏កាប់ករស់មនុស្សទាំងនោះស៊ី ហើយយក្ខក្រលេកមើលក្រឡិចក្រឡឹម ។

ឯអ្នកនោះឃើញយក្ខភ័យណាស់ មាត់តែងទន្ទេញរបៀនបីម៉ាត់ហើយគិតថា បើអញស្រែក យក្ខឃើញអញ ហើយវាស៊ីអញទៀត គិតហើយលោតពីធ្នឹមស្រែករ៉ាស យក្ខភ័យរត់បោលដំបងទៅបាត់ ។ អ្នកនោះបានដំបងវាយឯងហើយក៏ដើរត្រឡប់មកនគរ ឯសំពៅក៏បោលនៅកំពង់ព្រះវិហារនោះឯង ។

បុរសនោះលុះដើរមកដល់ផ្ទះក្នុងវេលាយប់ យកដំបងទៅលាក់ក្រោមជណ្តើរ យកឬសង្កត់លើហើយឡើងដេក ប្រពន្ធ

សួរក៏មិនស្ដី ថាចាំព្រឹកសឹមនិយាយរឿងប្រាប់ ៗ ឥឡូវនេះមិនបានក្រែងខុសពាក្យគ្រូផ្ដាំ ។

ឯប្រពន្ធនោះកាលក្រោយប្ដីទៅនោះ នៅផ្ទះមានសហាយ ដល់យប់ប្ដីមកដល់ ក៏សហាយនោះវាមកលបស្ដាប់នៅក្រោមផ្ទះ វាចង់ដឹងរឿងហើយវាឲ្យមេស្រីសហាយវាសួរ ដំណើរដូចម្ដេចក៏មិននិយាយថាចាំព្រឹកសិន មេនោះបេះតែឱបអង្អែលទ្រាំពុំបាននិយាយប្រាប់ថា អញនិយាយនឹងឯងខុសគ្រូហើយ ដ្បិតគ្រូផ្ដាំថា ដេកយប់កុំនិយាយនឹងស្រី ឥឡូវនេះអញនិយាយខុសបណ្ដាំគ្រូហើយ មេនោះសួរថាអ្នកឯងទៅបានរបស់អ្វីខ្លះ ប្ដីថាបានតែរៀនបីម៉ាត់ហើយត្រឡប់មកវិញ ដល់កណ្ដាលផ្លូវបានដំបងវាយឯងទៀត ។

មេនោះសួរថាដំបងទុកឯណាឥឡូវនេះខ្ញុំចង់ឃើញ ប្ដីថា អញទុកក្រោមជណ្ដើរយកថ្មគ្រប ថាហើយដេកលក់ទៅ ។

ឯសហាយនោះលបស្ដាប់ឮហើយ ទៅក្រោមជណ្ដើរយកដំបងនោះទៅបាត់ ។

លុះព្រឹកព្រហាមឡើង ក៏ចៅនោះរត់កពីដេកហើយចុះទៅរកដំបងបាត់ពុំឃើញ ប្រាប់ប្រពន្ធថា អញប្រាប់ឯងមិនជឿ អញថាខុសត្រូវហើយឯងមិនជឿ បេះតែល្បងអញទាល់តែអញប្រាប់ ឥឡូវនេះមនុស្សភ្ញាក់លួចយកដំបងទៅបាត់ហើយ ឯប្រពន្ធឮហើយដឹងជាសហាយលួច មិនស្រដីជណ្ដាំបាយទឹកឲ្យស៊ី ៗ រួចហើយ ក៏បុរសយកខ្សែមកចងប្ដីដែលគ្រប់លើដំបងនោះ ទៅប្ដឹងមេស្រុកឲ្យជំនុំរកឲ្យ មេស្រុកពុំដឹងបើជំនុំដូចម្ដេចពីព្រោះប្ដីពុំបេះស្រដី គេស្រដីជេរថាអាក់ព្រើល ពីដូនតាមកនរណាដែលមានដំបងភិយឯង ហើយគេដេញបេញ ឯចៅនោះបេះតែអួសប្ដីទៅប្ដឹង តាំងតែពីមេស្រុកដល់ទៅក្រឡាហោមចៅហ្វាយគេបេះតែដេញ ខ្លះក៏មិនឲ្យចូល គេថាមនុស្សឆ្កួត ចៅនោះអួសប្ដីចូលដល់ស្ដេច ៗ មានព្រះបន្ទូលសួរសព្វគ្រប់ហើយមានព្រះបន្ទូលប្រាប់អស់នាម៉ឺន ថាមែន ៗ បានជាគេថា មានប្រឡាយបានទឹកហូរ មានសម្រាមបានផ្កេភិជុះ អស់នាម៉ឺនកុំថាវាឆ្កួត សេចក្ដីនេះមែនបានជាវាហ៊ានថា ។

ស្ដេចមានព្រះបន្ទូលថា ឈ្នើយវិលទៅផ្ទះចុះ កាលណាអញឲ្យទៅហៅសិមមក ។ បុរសនោះទទួលព្រះករុណាវិសេសហើយក្រាបថ្វាយបង្គំលាទៅផ្ទះវិញ ។

និយាយឯស្ដេចនោះ កាលក្រោយចៅនោះលាទៅ ទ្រង់ឲ្យប្រាមប្រាប់អស់រាស្ត្របុន្មាន ៗ ថាថ្ងៃស្អែកស្ដេចឲ្យអស់ម្ខាងបេញរាំ ឲ្យអស់រាស្ត្រមើលក្នុងបីថ្ងៃ ពុំមានឃាត់ខាំងមើលតាមចិត្ត នោះស្ដេចឲ្យរៀបល្ខោនលេង កាលណោះអស់រាស្ត្រសឹងតែចូលទៅមើលល្ខោន ហើយយាងចូលទៅក្នុងព្រះរាជដំណាក់រើសប្រេងមួយដបក្រអូបយ៉ាងឯក ដែលចំណាំតែសម្រាប់ស្ដេច អស់រាស្ត្រនាម៉ឺនពុំដែលមាន ហើយស្ដេចប្រើអាមាត្យម្នាក់ឲ្យយកទៅឲ្យបុរសនោះ ហើយប្រាប់ថាស្ដេចទ្រង់ព្រះរាជទានឲ្យអ្នកឯង នឹងប្រពន្ធអ្នកឯងលាប ប៉ុន្តែឲ្យអ្នកឯងទៅផ្ទះកុំទៅមើលល្ខោន ឲ្យតែប្រពន្ធទៅ ឯអាមាត្យយកទៅឲ្យហើយប្រាប់សព្វគ្រប់តាមបណ្ដាំស្ដេច ហើយវិលទៅទូលស្ដេចវិញ ឯបុរសនោះបានប្រេងហើយហៅប្រពន្ធមកហើយហុចប្រេងទៅឲ្យប្រពន្ធថា អម្ចាស់ជីវិតទ្រង់ព្រះរាជប្រទានប្រេងនេះ

មកថាដ្បិតអាណិតស្រឡាញ់ ឲ្យលាបទៅមើលល្ខោននឹងគេ ឥឡូវនេះអញឈឺក្បាល ឯងយកទៅលាបហើយទៅមើលនឹងគេចុះ ឯប្រពន្ធឮប្តីឲ្យទៅហើយឲ្យទាំងប្រេងទៅផងដូច្នោះក៏អរណាស់ ពុំបានដឹងកលជាគេនឹងចាប់ ហើយយកទាំងប្រេងទៅឲ្យសហាយលាបផង ហើយបណ្តើរគ្នាទៅមើលល្ខោនឈរទន្ទឹមគ្នា លុះបន្តិចស្តេចនោះធុំក្រអូបប្រេងនោះហើយខ្សឹបប្រាប់នាម៉ឺនមួយនាក់ថា ឯងទៅហិតមើលអស់មនុស្សប៉ុន្មានៗ ដែលមើលល្ខោន បើធុំក្លិនប្រេងក្រអូបយ៉ាងនោះប៉ុន្មាននាក់ ចូរនាំយកមកឲ្យអញជាដាច់ ។

នាម៉ឺននោះក្រាបថ្វាយបង្គំហើយទៅហិតមនុស្សផងពុំមានទៅឃើញប្រុសម្នាក់ ស្រីម្នាក់ឈរទន្ទឹមគ្នា លាបប្រេងក្រអូបទាំងពីរនាក់ ហើយនាំទាំងស្រីទាំងប្រុសយកទៅថ្វាយស្តេចៗឲ្យរាំរោងលែងរាំកាលណោះ ហើយស្តេចឲ្យទៅហៅបុរសនោះៗមកដល់ហើយសួរថា នេះជាប្រពន្ធឯងមែន អ្នកនោះក្រាបទូលថាមែន ហើយស្តេចមានព្រះបន្ទូលសួរទៅសហាយនោះថា ឯងបានទៅលួចដំបងរបស់ចៅនេះមែន

ចៅសហាយនោះទូលថាល្អចមែន ហើយឲ្យទៅយកដំបងនោះមក ហើយស្ដេចត្រាស់ឲ្យយកអាសហាយនឹងមេនោះទៅដាក់ប្រវាក់ធ្វើទោស បុរសនោះក្រាបថ្វាយបង្គំសូមទោស រួចហើយក៏ប្រគល់ផ្ទះសំបែងទាំងប្រពន្ធឲ្យទៅសហាយនោះវិញ ពុំមានខឹងផង ។

ឯអាសហាយនោះអរ ហើយសំពះសូមទោសទៅផ្ទះវិញ ឯដំបងបុរសនោះក៏ថ្វាយទៅស្ដេច ហើយក្រាបលាទៅទៀត ស្ដេចឃាត់ក៏ពុំព្រម នោះស្ដេចមានព្រះបន្ទូលថា ដំបងវាយឯងនេះថ្លៃណាស់ ឲ្យបើកឃ្លាំងមាស-ប្រាក់ឲ្យវាយកមាសប្រាក់តាមចិត្ត ឯបុរសនោះរើអស់ទាំងឃ្លាំងប្រាក់មាសអំបាលនោះ ទៅឃើញកាំបិតបន្ទោះ ១ ចាស់នៅក្រោមឃ្លាំង ហើយក៏យកកាំបិតនោះនឹងប្រាក់គ្រាន់តែស៊ីតាមផ្លូវដើរទៅ ហើយចូលទៅក្រាបលាស្ដេចដើរទៅទៀត ឯស្ដេចក៏ពុំមានព្រះបន្ទូលអ្វីអស់ នាម៉ឺនសឹងតែគ្នាតិះដៀលថាមនុស្សឆោត ប្រាក់មាសមិនយក ទៅយកឯកាំបិតស្នឹម បុរសនោះទូលលាហើយចេញដើរទៅ ។

បុរសនោះដើរចេញពីនគរនោះទៅក៏បានដល់ទៅនគរមួយដទៃទៀត ស្តេចនោះបួនថ្ងៃនោះ មានព្រះបន្ទូលបង្គាប់សេដ្ឋីមួយនាក់ថា ព្រឹកស្តេចនឹងទៅលេងព្រៃ ឲ្យមហាសេដ្ឋីនោះធ្វើរទេះមួយឲ្យយ៉ាងល្អ ឲ្យឆ្លាក់ក្បាច់លាបលនឲ្យហើយ ឲ្យទាន់ក្នុងពេលព្រឹកស្អែកនេះ បើធ្វើពុំទាន់យកទោសដល់ស្លាប់ រីឯមហាសេដ្ឋីនោះគិតធ្វើពុំទាន់ហើយពុំធ្វើរទេះ ធ្វើបុណ្យហើយធ្វើមឈូសវិញ ។

ថ្ងៃនោះ ទទួលបុរសនោះដើរទៅដល់ឃើញមហាសេដ្ឋីនោះកំពុងតែធ្វើបុណ្យក៏សួរគេថា បុះលោកមានការអ្វីក៏បានជាធ្វើបុណ្យហើយធ្វើមឈូសផងដូច្នោះ គេប្រាប់ថាស្តេចឲ្យធ្វើរទេះលាបលនឲ្យយ៉ាងល្អ ឲ្យទាន់ព្រឹកនេះ ស្តេចនឹងទៅលេងព្រៃ បើធ្វើពុំទាន់ស្តេចយកទោសដល់ស្លាប់ ។ ឥឡូវនេះមហាសេដ្ឋីគិតធ្វើពុំទាន់ដឹងខ្លួនជាស្លាប់ បានជាធ្វើបុណ្យធ្វើមឈូសវិញ ។

បុរសនោះឆ្លើយថា ក្រអ្វីប៉ុណ្ណោះ ឲ្យតែបាយខ្ញុំស៊ីខ្ញុំធ្វើឲ្យៗទាន់ព្រឹកនេះ ឯមហាសេដ្ឋីនោះលុះបានឮដូច្នោះហើយក៏អរ

ណាស់ ហើយក៏ឲ្យរៀបបាយទឹកឲ្យស៊ីឆ្អែត ហើយក៏ប្រគល់ឈើឲ្យធ្វើរទេះនោះ បុរសនោះក៏ធ្វើតែនឹងកាំបិតមួយដែលយកក្រោមឃ្នាំងនោះក្នុងយប់នោះហើយ ៗ លាបលនល្អ ព្រឹកឡើងអួសយកទៅថ្វាយស្ដេច ឯស្ដេចឃើញហើយក៏ឲ្យរៀបប្រដាប់ប្រដាទៅលេងព្រៃ ។ ឯមហាសេដ្ឋីនោះលុះរួចពីស្លាប់ហើយក៏នឹកក្នុងចិត្តថា អ្នកនេះមានគុណធ្ងន់ណាស់ ឥឡូវនេះនឹងរកអ្វីសងគុណឲ្យស្មើនោះគ្មាន មានតែកូនក្រមុំ ១ នោះល្មមឲ្យមានប្ដីឥឡូវនេះមានតែការឲ្យទៅអ្នកនោះ គិតហើយហៅមកការឲ្យ ។ លុះដល់ការរួចហើយ ក្នុងយប់នោះផ្សំដំណេក ក៏បុរសនោះគិតល្បួងចិត្តប្រពន្ធ ហើយធ្វើជាដឹកស្រោស្រវឹងហើយដេកទៅ លុះដល់យប់យូរបន្តិចក៏ធ្វើជាក្អួតប្រឡាក់ប្រពន្ធ ។ កូនសេដ្ឋីនោះលុះឃើញក្អួតប្រឡាក់ខ្លួនដូច្នោះហើយ ក៏ស្រែកឡើងក្នុងយប់នោះថា លោកឪពុករកប្ដីឲ្យខ្ញុំឥតមនុស្សប្រមឹកក្អួតប្រឡាក់អស់ហើយ ខ្ញុំទ្រាំមិនបានទេ ។ មហាសេដ្ឋីនោះឮកូនស្រែកពីប្ដីដូច្នោះហើយក៏ឃាត់ទៅថា កូនដេកទៅកុំស្រែដី ដ្បិតប្ដីស្រវឹងហើយ

គេមានគុណផង យាត់ដូចម្ដេចក៏កូននោះមិនមានស្ដាប់ វាថា បើឲ្យទៅផ្ដែផ្ដាខ្ញុំទ្រាំ ឯមនុស្សប្រមឹកខ្ញុំមិនទ្រាំទេ ។

លុះព្រឹកឡើង ចៅនោះរលឹកពីដេកឡើង ក៏ចូលទៅសេដ្ឋី ប្រគល់ជូនកូនឲ្យវិញ មិនព្រមយក ហើយថាមិនបានពាល់ដៃជើងផង ឯមហាសេដ្ឋីយាត់សុំទោសឲ្យកូន ក៏ចៅនោះពុំព្រមនៅ ពុំព្រមយក ហើយយកកាំបិតលាមហាសេដ្ឋីនោះទៅទៀត ។ ឯស្ដេចនោះលុះមកពីព្រៃក៏ឲ្យទៅរកជាងដែលធ្វើរទេះនោះពុំឃើញហើយក៏គិតស្ដាយ ឲ្យអស់នាម៉ឺនបាក់សំបុត្ររកគ្រប់ខេត្ត ក៏ពុំឃើញហើយស្ដេចនោះក៏ស្ងៀមនៅ ។

ឯបុរសនោះលាសេដ្ឋីដើរទៅឆ្ងាយហើយក៏បានដល់ទៅនគរមួយដទៃទៀត ឯស្ដេចក្នុងនគរនោះ ក្នុងមួយយប់ឲ្យនាម៉ឺនមួយទៅដេកវេនចៅហ្វាយាង យប់ៗស្ដេចនោះចេញកាប់តែរាល់ថ្ងៃ តាំងតែពីថ្ងៃដែលស្ដេចបង្គាប់មកនោះកាប់នាម៉ឺនអស់ជាច្រើន ។

លុះដល់ថ្ងៃបុរសនោះទៅដល់ ចូនថ្ងៃនោះត្រូវវេនចៅហ្វាទៅដេកឲ្យស្ដេចកាប់នោះ ចៅហ្វានោះធ្វើបុណ្យឲ្យទានក្នុងថ្ងៃនោះ

បុរសនោះទៅដល់ហើយក៏សួរគេថាលោកមានការអ្វី ក៏បានជាធ្វើបុណ្យឲ្យទាន ហើយអស់កូនប្រពន្ធយំតែរាល់គ្នាដូច្នោះ គេប្រាប់ថាស្តេចឲ្យទៅដេកវេនឲ្យស្តេចកាប់ស្លាប់នេះ បានជាលោកធ្វើបុណ្យមុនស្លាប់ ក៏បុរសនោះថា បើគេឲ្យបាយខ្ញុំស៊ីខ្ញុំទៅដេកឲ្យស្តេចកាប់ជួស នោះអ្នកអស់នោះឮដូច្នោះហើយ ក៏ដើរទៅជំរាបចៅហ្វា ៗ ក៏ឲ្យហៅទៅដល់ហើយ ចៅហ្វាឲ្យរៀបបាយទឹកឲ្យស៊ី ហើយសួរថាបើអ្នកឯងទៅដេកឲ្យស្តេចកាប់ជួសខ្ញុំ ៗ នឹងធ្វើបុណ្យឲ្យអ្នក ក៏បុរសនោះទទួលទៅដេកជួស ហើយសុំប្រដាប់គ្រឿងដែលចៅហ្វាពាក់នោះយកមកពាក់ហើយ ក៏លីកាំបិតបន្ទោះចូលទៅដេកនៅចុងរោង ចាំឲ្យស្តេចចេញមកកាប់ដល់ចុងរោងហើយ ក៏បុរសនោះពុំដេកឡើយ ចាំមើលស្តេច លុះយប់យូរបន្តិចស្ងាត់ ស្តេចក៏បើកទ្វារចេញមកទ្រង់កាន់ព្រះខ័នដើរចូលមកនឹងកាប់បុរសនោះ ឯបុរសនោះលុះឃើញស្តេចមកជិតហើយ ក៏ស្ទុះទៅចាប់ស្តេចនោះជាប់ហើយ ក៏ចាក់នឹងកាំបិតបន្ទោះពីរ-បីដងបង្ហួស ហើយសួរថានរណា ៗ ចូលមកទាំងយប់នេះ ស្តេចលោកមានព្រះបន្ទូលឲ្យអញចាំយាមក្នុងយប់នេះ ។

ថាហើយចាក់បង្គុសទៀត នោះស្តេចនោះថាទេអញទេ នរណា អញទេ អញជាស្តេច ស្តេចអីមកទាំងយប់នេះ អញមិនដឹង ស្តេចលោកឲ្យអញចាំព្រះរាជរោងក្នុងយប់នេះ ។

លុះបន្តិចក៏លុតជង្គង់ថ្វាយបង្គំស្តេចសូមទោស, ស្តេច ត្រាស់សួរថាចៅទៅឯណា, បុរសនោះថាខ្ញុំនៅផ្ទះសម្តេចចៅហ្វ៊ា ស្តេចនោះដឹងហើយទ្រង់ញញឹមៗចូលទៅក្នុងវិញ ។

លុះព្រឹកឡើង ក៏បុរសនោះលីកាំបិតចេញពីក្នុងវាំងមក ផ្ទះចៅហ្វ៊ាវិញ អ្នកផងឃើញហើយឆ្ងល់ ថាបុរសនោះ ទៅ ដេកឲ្យស្តេចកាប់ ម្តេចក៏បានជាមិនស្លាប់មកវិញ ។ ឯចៅ ហ្វ៊ាសួរ បុរសនោះជំរាបតាមដំណើរសព្វគ្រប់ហើយ ជំរាបតថា ស្តេចសព្វថ្ងៃនេះពុំមែនជាកាចទេ ដ្បិតស្តេចនោះនឹងរកមនុស្ស ប្រាជ្ញចេះដឹងក្នុងនគរនឹងរក្សាស្តេច អ្នកយាមទៅដេកលក់ស្តេច ទើបកាប់, បុះបើសត្រូវវាចូលទៅលុកស្តេច ហើយយើង ដេកលក់ នោះតើនឹងយ៉ាងណាទៅ, បុរសនោះនិយាយ រឿងប្រាប់សព្វគ្រប់ហើយ ទើបភ្ញាក់ខ្លួនរាល់គ្នា អស់នាម៉ឺន ក្រៃលែណាស់ទៅហើយ ។

សម្ដេចចៅហ្វាគិតថា  បុរសនេះមានគុណធ្ងន់ណាស់ មានកូនក្រមុំមួយ  ក៏ឲ្យធ្វើជាប្រពន្ធបុរសនោះ ។

លុះព្រឹកឡើងស្ដេចនោះឲ្យមកហៅបុរសនោះទៅហើយ ឲ្យធ្វើជាតាម៉ឺនធំរក្សានគរបន្ទាប់ស្ដេចតទៅ ។

ឯស្ដេចនោះជរាចាស់ទៅ  ពុំមានកូនប្រុសនឹងឲ្យសោយរាជ្យស្នង  មានតែកូនក្រមុំមួយ  ហើយក៏ប្រគល់កូននូវរាជសម្បត្តិ  ឲ្យបុរសនោះសោយរាជ្យជាស្ដេចតទៅ ។

រឿងនេះខ្ញុំមិនដឹងជានៅនគរណា

ប៉ុន្តែឮតែចាស់ៗនិយាយតៗមក ។

ចប់  រឿងនេះតែប៉ុណ្ណោះ